# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ភាគ ១

## ១. កូនជ្រូកច្រើន សុខភាពល្អ និងរឹងមាំ

## ២. បន្ទាត់សិប្បនិម្មិតលើជ្រូក

## ៣. រោគសញ្ញាជំងឺជ្រូក

## ៤. ការប្រើប្រាស់បសុឱសថ

## ៥. កែលំអជីវសុវត្ថិភាពនៅតាមភូមិ


កុម្ភៈ ២០១០

ឧបត្ថម្ភដោយៈ

គម្រោងចិញ្ចឹមសត្វកម្ពុជា
សហគមន៍អឺរ៉ុប

សហគមន៍អឺរ៉ុប

អង្គការស្បៀង និងកសិកម្ម
នៃអង្គការសហប្រជាជាតិ

# អារម្ភកថា

ស្ថិតក្នុងស្ថានភាពដែលប្រទេសយើងទទួលបានស្ថិរភាព សន្តិភាពនិងអភិវឌ្ឍន៍ក្រោមការដឹកនាំរបស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានបន្តយកចិត្តទុកដាក់ខ្ពស់ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិលើគ្រប់វិស័យ ដែលក្នុងនោះវិស័យកសិកម្មដើរតួយ៉ាងសំខាន់ និងជាអទិភាពនៅក្នុងយុទ្ធសាស្ត្រចតុកោណជំហានទី២ របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីជំរុញលើកកំពស់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ឆ្លើយតបទៅនឹងគោលដៅនេះក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវគោលនយោបាយ និងកម្មវិធីច្បាស់លាស់ក្នុងការ ធានាស្បៀងអាហារគ្រប់គ្រាន់ និងមានសុវត្ថិភាពដល់ប្រជាពលរដ្ឋគ្រប់រូប ការកាត់បន្ថយភាពក្រីក្រ បង្កើនប្រាក់ចំណូលគ្រួសារ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ នៅឆ្នាំ ២០០៨ វិស័យកសិកម្មបានចូលរួមចំណែក ៣៤ភាគរយ នៃផលិតផលក្នុងស្រុកសរុប។ តាមរបាយការណ៍របស់ធនាគារពិភពលោក បានឱ្យដឹងថាប្រសិនបើវិស័យកសិកម្មកើនឡើង ៤ភាគ-រយក្នុងមួយឆ្នាំ នោះអត្រាភាពក្រីក្រនឹងអាចធ្លាក់ចុះ ៣៤ ភាគរយ មកនៅត្រឹមតែ ២១ ភាគរយនៅឆ្នាំ ២០១៥។ អត្រាភាពក្រីក្របានធ្លាក់ចុះពី ៤៧ ភាគរយ នៅឆ្នាំ ១៩៩៣ មកនៅត្រឹមតែ ៣៥ ភាគរយ នៅឆ្នាំ២០០៤ និងថ្មីៗនេះ អត្រានេះបានបន្តធ្លាក់ចុះមកនៅត្រឹមតែ ៣០ ភាគរយ ប៉ុណ្ណោះនៅឆ្នាំ ២០០៧ នេះ។ លើសពីនេះ នៅពេលដែលមានវិបត្តិហិរញ្ញវត្ថុពិភពលោកចាប់តាំងពីឆ្នាំ ២០០៨ មក វិស័យសំខាន់ៗរបស់សេដ្ឋកិច្ចកម្ពុជា បានធ្លាក់ចុះដូចជា វិស័យសំណង់ ឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ ធ្វើឱ្យវិស័យកសិកម្មបាន និងកំពុងដើរតួនាទី យ៉ាងសំខាន់ចំពោះសេដ្ឋកិច្ចជាតិទាំងមូលដែលក្នុងនោះផ្នែកចិញ្ចឹមសត្វ បានរួមចំណែក ១៥.៨ភាគរយ នៃផលិតផលក្នុងស្រុកសរុប ដោយផ្តល់ជាកំលាំងអូសទាញសន្តិសុខស្បៀង និងប្រាក់-ចំណូលប្រចាំគ្រួសារ ជាពិសេសដល់ប្រជាកសិករនៅជនបទ។

បច្ចុប្បន្នមានប្រជាជនយើងប្រមាណ៨០ភាគរយ ប្រកបរបរកសិកម្ម ហើយដីស្រែប្រមាណជាង ៧០ ភាគរយ នៅតែត្រូវបានភ្ជួររាស់ដោយគោ ក្របី។ ជាទូទៅ ប្រជាជនយើងចិញ្ចឹមគោ ក្របី ជ្រូក មាន់ ទា ជាលក្ខណៈគ្រួសារ ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងគ្រួសារ និងបង្កើតប្រាក់ចំណូល។ គោក្របីជាទ្រព្យសម្បត្តិ និងជាមរតកសម្រាប់ចែកកូនចៅ ប្រើប្រាស់ជាកំលាំងអូសទាញ ភ្ជួររាស់ និងសម្រាប់លក់ដោះដូរនៅពេលត្រូវការថវិកាចាំបាច់។ ផលិតកម្មលក្ខណៈគ្រួសារបែបនេះ ជាផលិតកម្មផ្គត់ផ្គង់ខ្លួនឯង ដែលខ្វះការថែទាំ ផ្តល់ចំណីហើយជាទូទៅសត្វមានអត្រាស្លាប់ និងឈឺនៅមានកំរិតខ្ពស់ រួមជាមួយកត្តាផ្សេងទៀតដូចជា គ្មានការជ្រើស

រើសពូជ ការបង្កាត់ពូជត្រឹមត្រូវ និងជាពិសេសពុំបានគិតគូរអំពីប្រសិទ្ធភាពសេដ្ឋកិច្ច។ កត្តាទាំងនេះធ្វើឱ្យប៉ះពាល់លើជីវភាពជនបទយ៉ាងធ្ងន់ធ្ងរ និងសេដ្ឋកិច្ចជាតិ និយាយជារួមផលិតភាព និងប្រាក់ចំណូលទទួលបានពីការចិញ្ចឹមសត្វនៅទាបដែលពាក់ព័ន្ធទៅនឹងកង្វះដើមទុន បច្ចេកទេស និង ប្រព័ន្ធទីផ្សារពុំមានប្រសិទ្ធភាព។

ឆ្លើយតបទៅនឹងស្ថានភាពខាងលើនៅឆ្នាំ ២០០០ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ សហការជាមួយសហគមន៍អឺរ៉ុបបានធ្វើការសិក្សាលើចំណុចខ្លាំង និងចំនុចខ្សោយនៃ ការងារផលិតកម្ម និង បសុព្យាបាល ដើម្បីធ្វើអន្តរាគមន៍ និងលើកផែនការយុទ្ធសាស្ត្រនៅកម្ពុជា។ ឆ្លងតាមការសិក្សានេះ យើងបានរកឃើញនូវចំណុចមួយចំនួនដែលត្រូវអន្តរាគមន៍ដូចជា បង្កើនសមត្ថភាពមន្ត្រី នាយកដ្ឋាន និងការិយាល័យផលិតកម្ម និងបសុព្យាបាល តាមរយៈការធ្វើសមាហរន្តកម្មកម្មវិធីបណ្តុះបណ្តាលក្នុងតំបន់ បង្កើនសេវាសុខភាពសត្វនៅជនបទ ការទប់ស្កាត់ជំងឺ ការកែលំអពូជ និងចំណីសត្វ ការនាំសត្វចេញ-ចូលតាមច្រកព្រំដែន និងអនាម័យសាច់សត្វ និង ទីផ្សារ។

ក្នុងគោលបំណងដើម្បីជំរុញវិស័យចិញ្ចឹមសត្វឱ្យប្រសើរឡើង គម្រោងចិញ្ចឹមសត្វក៏បានទទួលការគាំទ្រហិរញ្ញប្បទានពីសហគមន៍អឺរ៉ុបក្នុងភាពជាដៃគូអភិវឌ្ឍន៍ជាមួយរដ្ឋាភិបាលកម្ពុជា។ ដោយមានការផ្តួច-ផ្តើមគម្រោង បានចូលរួមជំរុញការអនុវត្តន៍គោលនយោបាយ និងកម្មវិធីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានទឹកប្រាក់សរុបប្រមាណ ជាង៥លានអឺរ៉ូ មានរយៈពេល៥ឆ្នាំ ហើយបានចាប់ផ្តើមពីខែមេសា ឆ្នាំ២០០៥ រហូតដល់ ខែមីនា ឆ្នាំ២០១០ នៅក្នុងខេត្តគោលដៅចំនួន ៤ គឺខេត្តតាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង និង ពោធិ៍សាត់។ គោលបំណងសំខាន់បំផុតរបស់គម្រោង គឺបង្កើនប្រាក់ចំណូលរបស់ប្រជាកសិករតាមរយៈការកែលំអការចិញ្ចឹមសត្វ។ ដើម្បី សម្រេចបាននូវគោលបំណងនេះ គម្រោងអន្តរាគមន៍សកម្មភាពសំខាន់ៗចំនួន ៣ គឺ ១-ការកែលំអសេវាកម្មសុខភាពសត្វ ២-ការកសាងសមត្ថភាពបច្ចេកទេសមូលដ្ឋាននៅជនបទ និង ៣-លើកស្ទួយទីផ្សារសត្វនិងសមធម៌នៃប្រាក់ចំណូល។ គម្រោងចិញ្ចឹមសត្វបានធ្វើសកម្មភាពជាច្រើន និងទទួល លទ្ធផលជាផ្លែផ្កាទៅតាមគោលដៅគួរឱ្យកត់សម្គាល់ ដែលក្នុងនោះសកម្មភាពសំខាន់ៗរួមមានៈ ការបណ្តុះបណ្តាលរំលឹកភ្នាក់ងារសុខភាពសត្វភូមិ ការបង្កាត់សិប្បនិម្មិតគោនិង ជ្រូក ការកែលំអពូជមាន់ ការថែរក្សា កូនជ្រូក ការចាក់វ៉ាក់សាំង កម្មវិធីដំណាំចំណីសត្វ ការធ្វើបង្ហាញអំពីបច្ចេកទេស ចិញ្ចឹមសត្វ ការចងក្រង ក្រុមកសិករ និងការផ្សព្វផ្សាយជាខ្សែវីដេអូនូវបច្ចេកទេសចិញ្ចឹមសត្វជូនដល់កសិករនៅខេត្តគោល ដៅទាំង៤ នៃគម្រោង។

ភ្នាក់ងារសុខភាពសត្វភូមិជាភ្នាក់ងារឯកជន ជាអ្នកដែលនៅជិតបំផុតជាមួយកសិករ ដឹងអំពីសុខទុក្ខពីកសិករ ដើរតួនាទីជាអ្នកផ្សព្វផ្សាយកសិកម្មភូមិ និងជាពិសេសផ្តល់នូវសេវាកម្មផលិតកម្ម និងបសុព្យាបាលជាប្រចាំដល់កសិករដើម្បីជួយកែលំអការចិញ្ចឹមសត្វ និងលើកកម្ពស់ជីវភាពរបស់ពួកគាត់។ ឆ្លើយតបទៅនឹងតួនាទីដ៏សំខាន់នេះ គម្រោងចិញ្ចឹមសត្វកម្ពុជា-សហគមន៍អឺរ៉ុប បានបណ្តុះបណ្តាលរំលឹកភ្នាក់ងារសុខភាពសត្វភូមិបានចំនួនប្រមាណ១១៥០នាក់ នៅបណ្តាខេត្តគោលដៅលើម៉ូឌុលចំនួន១៩ទាក់ទងទៅនឹង បច្ចេក-ទេសចិញ្ចឹមសត្វ និងទីផ្សារសត្វ។ ម៉ូឌុលនីមួយៗបានរៀបចំឡើងដោយឆ្លើយតបនៅនឹងស្ថានភាពសុខភាពនិងការចិញ្ចឹមសត្វនៅជនបទ និងបានចូលរួមផ្តល់ជាគំនិត និងការកែលំអពីផ្នែកពាក់ព័ន្ធនានាក្នុងនោះមានមន្ត្រី សម្របសម្រួលគម្រោងមកពីនាយកដ្ឋាន និងការិយាល័យផលិតកម្ម និងបសុព្យាបាល ខេត្តគោលដៅក្រុម ការងារបច្ចេកទេសគម្រោង និងនាយកគម្រោង។ ឯកសារម៉ូឌុលនេះ បានយកទៅបង្រៀនដោយគ្រូបង្គោលនៃគម្រោង បន្ទាប់មកបានធ្វើការកែលំអឱ្យមានភាពសុក្រិតបន្ថែមទៀត បន្ទាប់ពីបានបង្រៀននិងអនុវត្ត ផ្ទាល់ដោយភ្នាក់ងារសុខភាពសត្វភូមិ។ ទន្ទឹមនឹងនេះដែរ គម្រោងបានរៀបចំនូវសៀវភៅបច្ចេទេសខ្នាតតូច នេះឡើងដើម្បីផលប្រយោជន៍បន្ថែមទៀត សម្រាប់ភ្នាក់ងារសុខភាពសត្វភូមិដែលទទួលការបណ្តុះបណ្តាលរំលឹកហើយ។

ដើម្បីឆ្លើយតបនឹងតម្រូវការមិនចេះឈប់ឈរក្នុងការពង្រឹងសមត្ថភាព បង្កើនការយល់ដឹង ក៏ដូចជាចែករំលែកបទពិសោធន៍ និងជាផលប្រយោជន៍យូរអង្វែងសម្រាប់ភ្នាក់ងារសុខភាពសត្វភូមិ កសិករ ភ្នាក់ងារផ្តល់សេវាកម្មបសុពេទ្យផ្សេងៗទៀត ហើយនិងជាឯកសារសិក្សាផ្សព្វផ្សាយបច្ចេកទេសមូលដ្ឋាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយគម្រោងចិញ្ចឹមសត្វកម្ពុជា-សហគមន៍អឺរ៉ុប និងបណ្តាផ្នែកពាក់ព័ន្ធផ្សេងទៀត ធ្វើការចងក្រងសៀវភៅខ្នាតតូចនេះ ក្នុងគោលបំណងរួមចំណែកលើកកម្ពស់ជីវភាពប្រជាកសិករ សុវត្ថិភាពស្បៀង និងកាត់បន្ថយភាពក្រីក្រស្របទៅតាមកម្មវិធី និងគោលនយោបាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជាគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១០

រ ដ្ឋ ម ន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# កូនជ្រូកច្រើន សុខភាពល្អ
# និងរឹងមាំ

ឧបត្ថម្ភដោយ:

គម្រោងចិញ្ចឹមសត្វកម្ពុជា
សហគមន៍អឺរ៉ុប

សហគមន៍អឺរ៉ុប

អង្គការស្បៀង និងកសិកម្ម
នៃអង្គការសហប្រជាជាតិ

# មាតិកា

ទំព័រ

**១- ការគ្រប់គ្រងមុនពេលកើតកូន** .................... ០១
**២- បញ្ហាសុខភាពរបស់មេជ្រូក** .................... ០២
២-១- គ្រុនក្តៅ .................... ០២
២-២- ការហូរឈាមតាមប្រដាប់បន្តពូជ .................... ០៣
**៣- ដំណើរការកើតកូនធម្មតារបស់មេជ្រូក** .................... ០៤
៣-១- សញ្ញាបង្ហាញពីការកើតកូន .................... ០៤
៣-២- ដំណើរការកើតកូនធម្មតា .................... ០៥
**៤- ការជួយសង្គ្រោះក្នុងករណីកើតកូនមិនធម្មតា** .................... ០៦
៤-១- ចាក់អុកស៊ីតុកស៊ីន .................... ០៦
៤-២- លូកដៃចូលតាមប្រដាប់បន្តពូជ .................... ០៦
៤-៣- កូនជ្រូកអាចកើតមកមានសុកស្រោបជាប់.................... ០៧
៤-៤- សុកមិនធ្លាក់ .................... ០៨
**៥- ការគ្រប់គ្រងកូនជ្រូកក្រោយពេលកើត** .................... ០៨
៥-១- ងូតសំងួត .................... ០៨
៥-២- ពិនិត្យមើលទងផ្ចិត .................... ០៨
៥-៣- បំបៅទឹកដោះដំបូង .................... ០៨
៥-៤- រៀបចំកន្លែងសំរាប់កូនជ្រូក .................... ០៩
**៦- ការកាត់បន្ថយអត្រាស្លាប់របស់កូនជ្រូកមុនពេលផ្តាច់ដោះ** .................... ០៩
៦-១- ធានាឱ្យមានទឹកដោះដំបូង (Colostrum) និងទឹកដោះសំរាប់បៅ .................... ០៩
៦-២- ព្យាបាលរាគបង្កឡើងដោយបាក់តេរីអ៊ីកូលី (E.Coli) .................... ១១

៦-៣- ការថែទាំ ..................................................... ១២

៦-៤- ការផ្តល់ថ្នាំបង្ការ ..................................................... ១៤

៦-៥- ជំងឺសំខាន់ៗរបស់កូនជ្រូក ..................................................... ១៥

**៧- ការផលិតកូនជ្រូកឱ្យបានធំ និងសុខភាពល្អនៅពេលផ្តាច់ដោះ** ..................................................... ១៧

៧-១- ការផលិតទឹកដោះល្អ ..................................................... ១៧

៧-២- ការផ្តល់ចំណីអាហារគ្រប់គ្រាន់ដល់មេជ្រូក ..................................................... ១៨

៧-៣- ការផ្តល់ចំណីកូនជ្រូក ..................................................... ១៨

# ១. ការគ្រប់គ្រងមុនពេលកើតកូន

មេជ្រូកនឹងកើតកូន បន្ទាប់ពីផើមរយៈពេលប្រហែល ១១៤ថ្ងៃ។ ការគ្រប់គ្រងមេជ្រូកមុនពេលកើតកូនមានសារៈសំខាន់ណាស់។

-ជៀសវាងកុំឱ្យមេជ្រូកមានស្ត្រេស : ផ្លាស់មេជ្រូកទៅទ្រុងថ្មី ( ទ្រុងសំរាប់បង្កើតកូន ) មួយអាទិត្យ មុនពេលកើតកូន។

មេជ្រូកគ្មានស្ត្រេស ទ្រុងគ្មានការរំខានពីសំលេង និងសត្វល្អិត មេជ្រូកនឹងកើតកូនដោយស្រួល ។



ចាក់ថ្នាំបំបាត់អង្កែដោយប្រើអ៊ីវែម៉ិចទីន (Ivermectine) ចាក់ក្រោមស្បែកក្នុងកំរិត១សេសេ ក្នុងទំងន់៣៣គីឡូក្រាម ឱ្យមេជ្រូក ២ អាទិត្យ មុនពេលកើត ។



- មេជ្រូកច្រើនតែបាត់បង់ការស៊ីចំណី ដែលជាហេតុធ្វើឱ្យមេជ្រូក ក្ទៀនលាមក នេះជាកត្តាចំបង បង្កបញ្ហាក្នុងពេលកើតកូន និងកំឡុងពេលបំបៅដោះ ។



ដើម្បីការពារកុំឱ្យមេជ្រូកក្ទៀនលាមក យើងត្រូវផ្តល់ចំណី ដែលមានបន្លែបៃតង ឱ្យបានច្រើន ២-៣ ថ្ងៃ មុនពេលកើត ។



➢ ដើម្បីកាត់បន្ថយការក្ទៀនលាមក បញ្ចូកតាមមាត់ប្រេងប៉ារ៉ាហ្វីន (Paraffin) ចំណុះ ៣០០ សេសេ ។

# ២. បញ្ហាសុខភាពរបស់មេជ្រូក

## ២.១ គ្រុនក្តៅ



បើមេជ្រូកមិនស៊ីចំណីទេ ត្រូវពិនិត្យមើលសីតុណ្ហភាពនៅពេលព្រឹក ។ អ្នកអាចកំណត់ថា ជ្រូកកើតជំងឺ ប្រសិនបើមេជ្រូកក្តៅខ្លាំងលើសពី ៤០ អង្សាសេ ។

មូលហេតុគ្រុនក្តៅ អាចបណ្តាលមកពីរលាកប្លោកនោម លាសដោះ និងខូកជើង។ ដូច្នេះយើងត្រូវ :

- ពិនិត្យមើល បើមានហូរខ្ទុះតាមប្រដាប់បន្តពូជ ។
- ពិនិត្យមើល សភាពរបស់កន្សោមដោះ ឡើងរឹង ឬអត់ ។
- ពិនិត្យមើលស្ថានភាពរបស់មេជ្រូក អាចក្រោកឈរបានដែរឬទេ ហើយវាមានដំបៅនៅលើក្រចក និង សន្លាក់ដែរ ឬអត់ ។

**ក្នុងករណីដូចខាងលើនេះ យើងត្រូវ :**

- ធានាថា មេជ្រូកអាចផឹកទឹកបានគ្រប់គ្រាន់ ។
- ពិនិត្យមើលថា មេជ្រូកមិនក្តៀនលាមកខ្លាំងក្លានោះទេ ។
- ចាក់ថ្នាំទ្រីមេតូព្រីម ជាមួយស៊ុលហ្វា (TMP+Sulfa) ឬអង់រ៉ូផ្លុកសាក់ស៊ីន (Enrofloxacine) ចំនួន ៣ ថ្ងៃ។ បរិមាណនៃការចាក់អាស្រ័យទៅនឹងក្រុមហ៊ុនផលិតថ្នាំ។

## ២.២ ការហូរឈាមតាមប្រដាប់បន្តពូជ

ការហូរឈាមដែលមានក្លិនស្អុយ និងកំដៅឡើងខ្លាំង ៣-៤ថ្ងៃ មុនពេលកើតកូនអាចជាសញ្ញានៃការងាប់កូនក្នុងពោះ។



យើងត្រូវព្យាបាលមេជ្រូកជាបន្ទាន់ ព្រោះកូនងាប់ក្នុងពោះ អាចបណ្តាលឱ្យមានជំងឺ ។

- ចាក់ ប្រូស្តាក្លង់ឌីន (Prostaglandin) ដើម្បីរុញកូនដែលងាប់ចេញមកក្រៅ ឧទាហរណ៍ដូចជា Suiprost ចាក់ ២ សេសេ ក្នុង ១ក្បាល។
- ចាក់ថ្នាំ អង់រ៉ូផ្លុកសាក់ស៊ីន (Enrofloxacine) ឬតេត្រាស៊ីគ្លីន (Tetracycline)។

# ៣. ដំណើរការកើតកូនធម្មតារបស់មេជ្រូក

## ៣.១ សញ្ញាបង្ហាញពីការកើតកូន

- ១០ ថ្ងៃ មុនកើតកូន : ប្រដាប់បន្តពូជហើមប៉ោង កន្សោមដោះរីកធំ និងឡើងរឹង ។



១០ ថ្ងៃមុនកើតកូន



- ៨ ទៅ១២ ម៉ោងមុនកើត : ទឹកដោះចាប់ផ្តើមចេញ ។

យើងច្របាច់ដោះមេជ្រូក ហើយឃើញមានចេញទឹកដោះ វាបញ្ជាក់ថាមេជ្រូកនឹងកើតកូនឆាប់ៗ ។



- ៣០-៥០ នាទីមុនកើត : មានហូរឈាមព្រឿងៗ ហូរទឹករំអិលចេញពីប្រដាប់បន្តពូជ និងមានអាចម៍ព្រៃ ។ ជារឿយៗ យើងឃើញមានស្នាមទឹកពណ៌ខ្មៅៗនៅជាប់គូទជ្រូក ។

## ៣.២ ដំណើរការកើតកូនធម្មតា

### ក- សាច់ដុំស្បូនចាប់ផ្ដើមកន្ត្រាក់ ហើយរុញកូនចេញពីស្បូន :



ភ្លាមៗបន្ទាប់ពីសាច់ដុំកន្ត្រាក់ កូនជ្រូកទី ១ កើតចេញមកក្រៅ



ការកើតចេញមកទាំងស្រុងរបស់កូនជ្រូក១ ប្រើរយៈពេលតិចជាង ១ នាទី



ក្នុងករណីនេះ ជួយទាញកូនជ្រូកកើតចេញកន្ទុយចេញ មកក្រៅមុនឱ្យបានរហ័ស ជៀសវាងការថប់ដង្ហើម



កូនកើតចេញមកក្រៅ



ទងផ្ចិតនឹងដាច់ នៅពេលកូនជ្រូកវារទៅ បៅដោះមេវា



ចន្លោះកើតកូនមួយទៅកូនមួយទៀត ប្រហែលពី ១៥ ទៅ ២០ នាទី

ខ- ធម្មតារយៈពេលកើតរវាងកូនជ្រូក ១ ទៅកូនជ្រូក ១ទៀត មានរយៈពេលពី ១៥-២០នាទី ហើយមិនអាចលើស ៣០នាទីឡើយ ។

គ- រយៈពេលកើតកូនសរុបមានប្រហែល ២ ម៉ោង ៣០នាទី ។

# ៤. ការជួយសង្គ្រោះក្នុងករណីកើតកូនមិនធម្មតា

ក្នុងករណីខ្លះ គេសំគាល់ឃើញថា ជ្រូកកើតកូនយូរខុសធម្មតា ។ ដូច្នេះយើងត្រូវជួយដូចខាងក្រោម:

**៤.១ ចាក់អុកស៊ីតុកស៊ីន (Ocytocine) :** នៅពេលមេជ្រូកអស់កំលាំង ស្បូនមិនសូវកន្ត្រាក់ ដូច្នេះត្រូវចាក់អុកស៊ីតុកស៊ីន ដើម្បីធ្វើឱ្យស្បូនជួយរុញកូនកើតចេញមកក្រៅ ។

ប្រសិនបើកូន១កើត ហើយរង់ចាំ៣០នាទី នៅតែមិនឃើញកូនបន្ទាប់កើត យើងត្រូវចាក់អុកស៊ីតុកស៊ីន ។ ២ ទៅ ៣នាទីក្រោយ កូនជ្រូកបន្ទាប់នឹងកើតចេញមក ។



## ៤.២ លូកដៃចូលតាមប្រដាប់បន្តពូជ

លូកដៃចូលតាមប្រដាប់បន្តពូជ ស្ទាបមើលថាតើកូនជ្រូកមានទីតាំងខុសធម្មតា កូនធ្លោសពេក ឬកូនងាប់ ។

លាងសំអាតដៃ ហើយលាបប្រេងរំអិល ដូចជាប្រេងប៉ារ៉ាហ្វីន ។ លូកដៃចូលក្នុងស្បូនថ្នមៗ និងប្រុងប្រយ័ត្ន ។



ប្រសិនបើកូនជ្រូកថ្លោសពេក លូកដៃចាប់ឆ្អឹងថ្គាម ឬប្រើខ្សែទាក់ធ្មេញមុខ ហើយទាញកូនជ្រូកចេញមកក្រៅ ។



ប្រសិនបើកូនជ្រូកមានទីតាំងខុសប្រក្រតី ត្រូវលូកបង្វិលវា ដូចជាទាញជើងមុខតំរង់ទៅមុខ ហើយត្រូវប្រុងប្រយ័ត្ន និងជៀសវាងកុំឱ្យដាច់ស្បូន ។



➢ ពេលលូកដៃជួយបង្កើតរួចរាល់ហើយ ត្រូវចាក់អង់ទីប៊ីយ៉ូទិច (ទ្រីមេតូព្រីមជាមួយស៊ុលហ្វា TMP+Sulfa) តាមសាច់ដុំ រយៈពេល៣ថ្ងៃ ។

## ៤.៣ កូនជ្រូកអាចកើតមកមានសុកស្រោបជាប់

ក្នុងករណីខ្លះ កូនចុងក្រោយដែលកើតមកស្រោបដោយសុក ដូចនេះយើងត្រូវជួយសង្គ្រោះ ដោយយកសុកចេញ កុំឱ្យកូនជ្រូកថប់ដង្ហើម ។



បើមិនជួយក្នុងកំឡុងពេលនេះទេ នឹងបណ្តាលឱ្យកូនជ្រូកងាប់ និងខាតបង់ថវិកា ។

**៤.៤ សុកមិនធ្លាក់** ៖ គឺជាមូលហេតុដ៏សំខាន់ ក្នុងការធ្វើឱ្យរលាកស្បូន។ បន្ទាប់ពីកើតកូនរួច ត្រូវពិនិត្យមើលឱ្យច្បាស់ថាសុកទាំងអស់បានធ្លាក់ ឬអត់។ ដើម្បីការពារបញ្ហានេះ បន្ទាប់ពីកើតរួចភ្លាម ត្រូវចាក់អុកស៊ីតុកស៊ីន ២ សេសេ ចាក់តាមសាច់ដុំ។

# ៥. ការគ្រប់គ្រងកូនជ្រូកក្រោយពេលកើត

## ៥.១ ជូតសំងួត និងសំអាតទឹករំអិលចេញពីមាត់ និងច្រមុះ។



- សំអាតមាត់ និងច្រមុះ ដើម្បីជួយឱ្យកូនជ្រូកដកដង្ហើមស្រួល។
- លើកជើងក្រោយយួរ ហើយយកដៃទះដងខ្លួន ឬទ្រូងថ្នមៗ ឱ្យទឹករំអិលចេញពីច្រមុះ។
- ជូតសំងួតកូនជ្រូក ដើម្បីការពារកុំឱ្យវារងា និងចុះខ្សោយ ។

## ៥.២ ពិនិត្យមើលទងផ្ចិត

បន្ទាប់ពីកើត ត្រូវពិនិត្យមើលទងផ្ចិត ព្រោះខ្លាចមានហូរឈាម ជាហេតុបណ្តាលឱ្យកូនជ្រូកបាត់បង់ឈាម។



ចងទងផ្ចិត លាងសំអាត និងសំលាប់មេរោគជាមួយទឹកអ៊ីយ៉ូឌីន (Iodine)



## ៥.៣ បំបៅទឹកដោះដំបូង

ជួយកូនជ្រូកឱ្យបៅទឹកដោះដំបូង **(Colostrum)** ព្រោះទឹកដោះដំបូងមានសារៈសំខាន់ក្នុងការជួយការពារជំងឺផ្សេងៗ។

ជួនកាល កូនជ្រូកមិនអាចបៅទឹកដោះដំបូងបានគ្រប់គ្រាន់ទេ ពីព្រោះក្បាលដោះមេជ្រូកធំពេក ឬដោយសារកូនជ្រូកខ្សោយ ។



## ៥.៤ រៀបចំកន្លែងសំរាប់កូនជ្រូក

រៀបចំសំបុក ឬកន្លែងដេក កុំឱ្យកូនជ្រូករងា ជាពិសេសនៅពេលយប់ ព្រោះវាបណ្តាលឱ្យកូនជ្រូកចុះខ្សោយ និងរាករូស ។

អាកាសធាតុត្រជាក់ និងមានខ្យល់ បណ្តាលឱ្យកូនជ្រូករងា និងបណ្តាលឱ្យ :



- បាត់បង់ថាមពល និងចុះខ្សោយ ហើយមិនអាចបៅទឹកដោះបានគ្រប់គ្រាន់ ។
- ចំណីអាហារឆ្លងកាត់ពោះវៀន មានសភាពយឺត ។ លក្ខណៈនេះអំណោយផលដល់ការលូតលាស់បាក់តេរីអ៊ីកូលី ដែលជាមូលហេតុបង្កឱ្យរាករូស ។
- ការរៀបចំសំបុក មានសារៈសំខាន់ណាស់ក្នុងការកាត់បន្ថយអត្រាស្លាប់ ក្នុងកំឡុងពេលប៉ុន្មានថ្ងៃដំបូងក្រោយពេលកើត ។

# ៦. ការកាត់បន្ថយអត្រាស្លាប់របស់កូនជ្រូកមុនពេលផ្តាច់ដោះ

## ៦.១ ធានាឱ្យមានទឹកដោះដំបូង (Colostrum) និងទឹកដោះសំរាប់បៅ

ទឹកដោះដំបូង មានសារៈសំខាន់ណាស់ ក្នុងការជួយកូនជ្រូក តែជួនកាលបន្ទាប់ពីកើតរួច មេជ្រូកខ្លះមិនអាចផលិតទឹកដោះបានទេ ដោយសារមានបញ្ហាផ្សេងៗដូចជាគ្រុនក្តៅ មិនស៊ីចំណី និងកន្សោមដោះឡើងរឹង ។ នេះជាជំងឺលាសដោះ រលាកស្បូន និងអត់ទឹកដោះ (MMA) ។ យើងត្រូវព្យាបាល

ជាបន្ទាន់ ព្រោះវាអាចបណ្តាលឱ្យកូនជ្រូកងាប់ ២-៣ថ្ងៃបន្ទាប់ ដោយសារអត់ទឹកដោះបៅ ។



កន្សោមដោះរឹង និងគ្មានទឹកដោះ ដែលកើតមានក្រោយពីកើតកូនរួច គឺជាជំងឺលាសដោះ រលាកស្បូន និងអត់ទឹកដោះ (MMA) ។

ព្យាបាល ជំងឺលាសដោះ រលាកស្បូន និងអត់ទឹកដោះ (MMA) ជាបន្ទាន់ :

- ចាក់អុកស៊ីតុកស៊ីន ( Ocytocine ) ចំនួន ០,៥សេសេតាមសរសៃវ៉ែនស្លឹកត្រចៀក ។
- ២-៣ វិនាទីក្រោយមកទឹកដោះនឹងចេញ បន្ទាប់មកចាប់កូនជ្រូកឱ្យបៅជាបន្ទាន់ ។ ចាក់ ១ថ្ងៃ ៣ដង រហូតទឹកដោះចេញធម្មតាវិញ ។
- ចាក់អង់ទីប៊ីយ៉ូទិច ឈ្មោះទ្រីមេតូព្រីមជាមួយស៊ុលហ្វា (Trimetoprim + Sulfa) រយៈពេល ៥ថ្ងៃ ចាក់សាច់ដុំ ។
- ប្រសិនបើកន្សោមដោះឡើងរឹង ត្រូវចាក់ដិចសាមេតាសូន ( Dexamethasone ) ចាក់សាច់ដុំ ។



ប្រសិនបើកំដៅឡើងលើសពី ៤០ អង្សាសេ ត្រូវចាក់អាណាហ្សាំង (Analgine) ឬកាល់ម៉ាហ្សាំង (Calmagine) ចាក់សាច់ដុំ ដើម្បីបញ្ចុះកំដៅ ។

## ៦.២ ព្យាបាលរាកបន្ទោរបង់ដោយបាក់តេរីអ៊ីកូលី (E.Coli)

- ➢ បើមានករណីរាករូសត្រូវព្យាបាលជាបន្ទាន់ ពីព្រោះបើកូនជ្រូករាកក្នុងរយៈពេលពី ២ ទៅ ៣ម៉ោង វាបណ្ដាលឱ្យខ្សោះអស់កំលាំង និងពិបាកជួយសង្គ្រោះណាស់ ។
- ➢ បើយើងពិនិត្យឃើញមានកូនជ្រូករាក ១ ទៅ ២ក្បាល ក្នុងមួយសំបុក ចាំបាច់ត្រូវព្យាបាលកូនជ្រូកទាំងអស់ ។
- ➢ ប្រសិនបើរាកកើតមានលើកូនជ្រូកអាយុ ១ថ្ងៃ នោះចាំបាច់ត្រូវពិនិត្យស្ថានភាពមេជ្រូក ដូចជាសីតុណ្ហភាពខ្ពស់ ស្ថានភាពកន្សោមដោះ និងការផលិតទឹកដោះមិនល្អ... ជាញឹកញយ ទឹកដោះជាមូលហេតុចំបងក្នុងការបង្កឱ្យរាក ។



- ព្យាបាលកូនជ្រូក : ចាក់អង់ទីប៊ីយ៉ូទិចដែលមានប្រសិទ្ធិភាពប្រឆាំងនឹងមេរោគអ៊ីកូលី ។ កូលីស្ទីន (Colistin) ជាអង់ទីប៊ីយ៉ូទិចដ៏ល្អបំផុត ។ ជាទូទៅកូលីស្ទីនប្រើរួមជាមួយនឹងអំពីស៊ីលីន (Ampicillin) ដូចជាប៊ីយ៉ូកូលីស្ទីន (Biocolistine) ឬ អំពីដិចសាឡោន (Ampi-dexalone) ។ ត្រូវចាក់ ២ដងក្នុងមួយថ្ងៃ នៅពេលព្រឹក និងល្ងាចរហូតដល់កូនជ្រូកជាសះស្បើយ ។
- ត្រូវពិនិត្យមើលថា កូនជ្រូកវាមិនរងា ព្រោះរងាជាមូលហេតុបង្កឱ្យរាកដែរ ។
- ព្យាបាលមេជ្រូក : ប្រើថ្នាំទ្រីមេតូព្រីមជាមួយស៊ុលហ្វា (Trimetoprim+Sulfa) ចាក់សាច់ដុំមួយថ្ងៃម្ដង ក្នុងរយៈពេល៣ថ្ងៃ ។

## ៦.៣ ការថែទាំ

➢ ការកាត់ធ្មេញកូនជ្រូក : ការកាត់ធ្មេញកូនជ្រូក ការពារកុំឱ្យកូនជ្រូកខាំដោះនៅពេលបៅ និង ជៀសវាងកុំឱ្យមានរបួសស្នាម ពេលវាខាំគ្នា ។



លាងសំអាតកន្ត្រៃ និង សំលាប់មេរោគដោយទឹកអ៊ីយ៉ូតឌីន (Idiodine) រួចកាត់ធ្មេញកូនជ្រូក ពាក់កណ្តាល ដោយមិនឱ្យប៉ះអញ្ចាញធ្មេញឡើយ ។ ការកាត់ធ្មេញនេះ ធ្វើឡើងមុនពេលកូនជ្រូកអាយុ ៣ថ្ងៃ ។



➢ ការកាត់កន្ទុយ : ការកាត់កន្ទុយ អាចកាត់បន្ថយការខាំកន្ទុយដោយកូនជ្រូកផ្សេងទៀត និង ការឆ្លងមេរោគតាមរយៈកន្ទុយ ។

- លាងសំអាតកាំបិត និងសំលាប់មេរោគដោយទឹកអ៊ីយ៉ូឌីន ។
- លាងសំអាតសំលាប់មេរោគលើកន្ទុយជាមួយនឹងទឹកអ៊ីយ៉ូឌីន ។
- កាត់កន្ទុយពាក់កណ្តាល ឬរហូតដល់ ៣ ភាគ ៤ នៃប្រវែងកន្ទុយសរុប បន្ទាប់មកលាបទឹកអ៊ីយ៉ូឌីនត្រង់កន្លែងកាត់ ។



- **ការក្រៀវ :** យកល្អក្រៀវកូនជ្រូកឈ្មោល នៅពេលវាមានអាយុពី ៧ ទៅ ១០ថ្ងៃ។



ពងស្វាសធម្មតា

ពងស្វាសមានលក្ខណៈធម្មតា ទើបអាចក្រៀវបាន។ ប្រសិនបើពងស្វាសមានបញ្ហាអ៊ែកនី (ក្លូន) មិនត្រូវក្រៀវទេ ព្រោះវាអាចបណ្តាលឱ្យគ្រោះថ្នាក់។



ជ្រូកមានបញ្ហាអ៊ែកនី (ក្លូន)

- **បច្ចេកទេសក្រៀវ :**



លាងសំអាតស្បែកពងស្វាស និងសំភារៈចាំបាច់ដែលប្រើសំរាប់ក្រៀវ ដោយទឹកអ៊ីយ៉ូឌីន។

ប្រើកាំបិតមុតស្រួច វះបញ្ឈរពាក់កណ្តាលស្បែកពងស្វាស ដោយវះផ្ទាល់លើស្បែកពងស្វាសនីមួយៗ។





ច្របាច់ពងស្វាសឱ្យលៀនចេញក្រៅ ហើយទាញចេញ។

កាត់បំពង់ភ្ជាប់ពងស្វាស ឱ្យបានខ្លីដែល
អាចធ្វើទៅបាន ។





បាញ់ទឹកអ៊ីយ៉ូឌីន ចូលត្រង់កន្លែងវះ ។

- កូនជ្រូកដែលទើបក្រៀវអាចហើមត្រង់មុខរបួស ២ ទៅ ៣ថ្ងៃ ហើយក្រោយមកវានឹងជា ស្បើយ ។ ប្រសិនបើការក្រៀវមិនបានល្អ ឬកូនជ្រូកដែលក្រៀវហើយដេកក្នុងភក់ឬកន្លែងកើ វាអាចបណ្ដាលឱ្យមេរោគឆ្លងចូលបាន ។



- ក្នុងករណីមានជំងឺ គេសង្កេតឃើញមាន ៖ កន្លែងវះមានសភាពហើម ឈឺចាប់ខ្លាំង និងក្ដៅ ហើយកូនជ្រូកមិនស៊ីចំណី ។
- ព្យាបាលដោយអាម៉ុកស៊ីលីន (Amoxcilline) និងរក្សាកូនជ្រូកនៅកន្លែងស្ងួតល្អ ។

## ៦.៤ ការផ្ដល់ថ្នាំបង្ការ

ការផ្ដល់ថ្នាំបង្ការ ក្នុងគោលបំណងដើម្បីឱ្យកូនជ្រូកជៀសផុតនូវបញ្ហាមួយចំនួនដូចជា ការឆ្លងមេរោគ កង្វះជាតិដែកដែលធ្វើឱ្យស្លេកស្លាំង និងការពារជំងឺរាក ។

➢ អាម៉ុកស៊ីលីន (Amoxcilline) : ចាក់នៅពេលកូនជ្រូកមានអាយុ ២៤ម៉ោង ដើម្បីការពារការឆ្លងជំងឺតាមទងផ្ចិត ដែលបង្កឡើងដោយពួកស្ត្រិបតូកុកកូស (Streptococcus)។ ស្ត្រិបតូកុកកូស បង្កឱ្យមានជំងឺមេរោគក្នុងឈាម រលាកសន្លាក់ និងរ៉ែកនី (ក្លន)។

➢ ជាតិដែក : ចាក់លើកទី១ នៅពេលកូនជ្រូកអាយុ ២ថ្ងៃ ដើម្បីការពារការស្លេកស្លាំង ហើយចាក់រំលឹកលើកទី ២ ពី ៧-១០ ថ្ងៃក្រោយពីចាក់លើកទី១។

➢ តុលត្រាស៊ុលរីល (Toltrazuril) ផ្ដល់ឱ្យនៅពេលកូនជ្រូកមានអាយុ ៣ថ្ងៃ ដើម្បីការពារជំងឺកុកស៊ីដ្យូស៊ីស (រាគពណ៌ប្រផេះ) ដែលច្រើនកើតមាននៅពេលកូនជ្រូកមានអាយុពី ៧ ទៅ ២០ថ្ងៃ។ កូនជ្រូកដែលកើតជំងឺនេះ មិនងាប់ទេ តែពួកវាស្គម ហើយមិនកើនទំងន់។



តុលត្រាស៊ុលរីល (អង់ទីកុក (Anticoc)) ប្រើសំរាប់ការពារការរាកដោយកុកស៊ីដ្យូស៊ីស តែមិនអាចព្យាបាលជំងឺនេះបានទេ។ ថ្នាំព្យាបាលដែលមានប្រសិទ្ធិភាព គឺ ស៊ុលហ្វា ៣៣ (Sulfa 33) ប្រើរហូតដល់សត្វបាត់រាគ។



## ៦.៥ ជំងឺសំខាន់ៗរបស់កូនជ្រូក

➢ **មេរោគក្នុងឈាម (Septicemia)** : បណ្ដាលឱ្យងាប់ភ្លាមៗ បង្កឡើងដោយពួកស្ត្រិបតូកុកកូស។ គេអាចព្យាបាលដោយប្រើអង់ទីប៊ីយ៉ូទិច ឈ្មោះអាម៉ុកស៊ីលីន (Amoxcillin)ឬឡាំងកូមីស៊ីន (Lincomycin)។

➢ **រលាកសន្លាក់ (Arthritis)**: បង្កឡើងដោយពួកស្ត្រិបតូកុកកូសដែរ។ ដើម្បីជៀសវាង ការឆ្លងមេរោគស្ត្រិបតូកុកកុស យើងត្រូវការពារកុំឱ្យមានស្នាមដំបៅ និងធ្វើការសំលាប់មេរោគឱ្យបានល្អនៅលើផ្ចិត ពេលកាត់ធ្មេញ និងកាត់កន្ទុយ។ កំរាលទ្រុងត្រូវសមស្រប ជៀសវាងសើក ឬដាច់ជង្គង់។



កំភាលទ្រុងមិនល្អ អាចបណ្តាលឱ្យដាច់រលាត់ជើង នៅពេលកូនជ្រូកលូនទៅបៅមេវា ដែលជាមូលហេតុធ្វើឱ្យមេរោគស្រ្តិបតូកុកកូស ជ្រាបចូលតាមកន្លែងដាច់រលាត់ និងបង្កឱ្យមានជំងឺរលាកសន្លាក់ និងពិការជើង ។

ព្យាបាលដោយប្រើអង់ទីប៊ីយ៉ូទិច ដូចជា អាម៉ុកស៊ីលីន (Amoxcillin) ឬឡាំងកូមីស៊ីន (Lincomycin) ។



- **ជំងឺរលាកស្បែក (Dermatitis):** ជំងឺរលាកស្បែកនេះ បង្កឡើងដោយពួកស្តាហ្វីឡូកុកកូស (Staphylococcus) ។ ជំងឺនេះបណ្តាលឱ្យកូនជ្រូកខ្លះឈឺ តែមិនបណ្តាលឱ្យឆ្លងរាលដាលទេ ។ វាមិនបណ្តាលឱ្យកូនជ្រូកងាប់ទេ តែស្ថានភាពកូនជ្រូកពេលផ្តាច់ដោះពុំសូវល្អ ។

ការព្យាបាលដោយប្រើអង់ទីប៊ីយ៉ូទិច មិនសូវមានប្រសិទ្ធិភាពទេ ។ ការបាញ់ថ្នាំសំលាប់មេរោគ ដែលមានកំហាប់ទាប ជាដំណោះស្រាយមួយ ។



ជាទូទៅជំងឺរលាកស្បែក ចាប់ផ្តើមចេញពីផ្នែកជុំវិញមុខ ឬជើង បន្ទាប់មករាលដាលដល់ស្បែកត្រង់ ចំហៀងពោះ និងចន្លោះជើង ហើយវាប្រែពណ៌ទៅជាពណ៌ត្នោតបន្តិចម្តងៗ រហូតដល់ពេញខ្លួនទាំងមូល ។ ស្បែកចាប់ផ្តើមជ្រីវជ្រួញទីងរបកជាផ្ទាំងធំ ដែលមានសភាពដូចខ្លាញ់រងើម ។

- **ការក្អក (Coughing) :** បាក់តេរី ដូចជាពួកអាក់ទីណូបាក់ស៊ីលីស (Actinobacillus) អេម៉ូហ្វីលីស (Heamophilus) ក្នុងករណីស្រួចស្រាវ អាចបង្កឱ្យកូនជ្រូកងាប់យ៉ាងលឿន ទោះបីកូនជ្រូក មើលទៅមានស្ថានភាពប្រក្រតីក៏ដោយ ។ ក្នុងករណីមិនស្រួចស្រាវ វាអាចបណ្តាលឱ្យគ្រុនក្តៅខ្លាំង ក្អក និងហើមសួត (ពិបាកដកដង្ហើម) ។

ការព្យាបាលត្រូវធ្វើឡើង ជាបន្ទាន់ ដោយប្រើអង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacine) ឬ ហ្វ័រហ្វេនីកុល (Florfenicol) ។ ថ្ងៃដំបូងត្រូវចាក់ក៏រិតថ្នាំទ្វេដង ។

# ៧. ការផលិតកូនជ្រូកឱ្យបានធំ និងសុខភាពល្អនៅពេលផ្តាច់ដោះ

## ៧.១ ការផលិតទឹកដោះល្អ

- បរិមាណទឹកដោះច្រើន និងគ្រប់គ្រាន់ ធ្វើឱ្យកូនមានសុខភាពល្អ និង លូតលាស់រហ័ស ។
- កន្សោមដោះ និងក្បាលដោះត្រូវមានស្ថានភាពល្អ ។ ប្រសិនបើក្បាលដោះដំបៅ ឬធំជាងមាត់កូនជ្រូក នោះធ្វើឱ្យកូនជ្រូកពិបាកបៅ ។



- ក្បាលដោះល្អ
- កន្សោមដោះមានទឹកដោះពេញ

- ការព្យាបាលជំងឺលាសដោះក្រោយពេលកើត ធ្វើឡើងឱ្យបានឆាប់រហ័ស ដើម្បីជួយឱ្យមេជ្រូកអាចផលិតទឹកដោះសំរាប់កូនបាន ។



ជំងឺលាសដោះ

- មេជ្រូកមិនស៊ីចំណី ភ្នែកឡើងក្រហម សីតុណ្ហភាពលើសពី ៤០ អង្សាសេ ។
- ដើម្បីធ្វើរោគវិនិច្ឆ័យ យើងត្រូវស្ទាបកន្សោមដោះ ដើម្បីរកមើលកន្លែងហើមនិងឡើងរឹង ។



កន្សោមដោះ ស្វិតគ្មានទឹកដោះ បន្ទាប់ពីលាសដោះ

ព្យាបាល :

- ចាក់អុកស៊ីតុកស៊ីន ដើម្បីជំរុញការបញ្ចេញទឹកដោះ ( ប្រើ ០,៥ សេសេ ចាក់តាមសរសៃវ៉ែន) ។
- អង់ទីប៊ីយ៉ូទិច : ទ្រីមេតូព្រីម / ស៊ុលហ្វា (Trimetoprim/sulfa) ឬអង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacine) ចាក់ ១ដង ក្នុង ១ថ្ងៃ ។ ក្នុងករណីស្រួចស្រាវខ្លាំង គេត្រូវចាក់ព្យាបាល ២ ដងក្នុងមួយថ្ងៃ ។
- ប្រសិនបើកន្សោមដោះឡើងរឹង ចាក់ដិចសាមេតាសូន (Dexamethasone) ។

## ៧.២ ការផ្តល់ចំណីអាហារគ្រប់គ្រាន់ដល់មេជ្រូក

ដើម្បីផលិតទឹកដោះឱ្យបានគ្រប់គ្រាន់សំរាប់ចិញ្ចឹមកូន មេជ្រូកត្រូវការទឹកប្រហែល ៤៥ លីត្រក្នុងមួយថ្ងៃ និងចំណីអាហារគ្រប់គ្រាន់ ។

នៅពេលមេជ្រូកផលិតទឹកដោះគ្រប់គ្រាន់ យើងអាចឃើញកូនថ្លោសល្អ ហើយពួកវានៅស្ងៀម ។ កន្សោមដោះមេមានសភាពល្អនិងពេញដោយទឹកដោះ ។



សំខាន់បំផុតនោះ ត្រូវបង្កើនបរិមាណចំណី ហើយត្រូវផ្តល់ឱ្យវាស៊ីឱ្យបាន ៣ ដង ក្នុង ១ថ្ងៃ ។

ការផលិតទឹកដោះត្រូវការចំណីដែលមានប្រូតេអ៊ីនខ្ពស់ : ចំណីអាចលាយជាមួយសារធាតុ ដែលមានប្រូតេអ៊ីនខ្ពស់ ដូចជាសណ្តែកសៀងជាដើម ។

ក្នុងកំឡុងពេលផលិតទឹកដោះ គេចាំបាច់ត្រូវលាយសារធាតុបន្ថែមដូចជាប្រេមិច ដែលមានសារជាតិរ៉ែ និងវីតាមីន (Mineral+Vitamins) ក្នុងរបបចំណីអាហាររបស់មេជ្រូក ។

## ៧.៣ ការផ្តល់ចំណីកូនជ្រូក

- នៅពេលកូនជ្រូកមានអាយុ ៣ អាទិត្យ មេជ្រូកមិនអាចផលិតទឹកដោះឱ្យបានគ្រប់គ្រាន់ទេ ជាពិសេសនៅពេលកូនជ្រូកមានបរិមាណច្រើនពី ៨ ទៅ ៩ក្បាល ក្នុងមួយសំបុក ។

➢ បន្ថែមចំណីពិសេស (ស៊ីភី ឬបេតាក្រូ) សំរាប់កូនជ្រូកនៅសប្តាហ៍ចុងក្រោយមុនផ្តាច់ដោះ (នៅពេលកូនជ្រូកមានអាយុ ៣អាទិត្យ) ដើម្បីជួយឱ្យវាលូតលាស់លឿន កើនទំងន់ និងមានកំលាំងខ្លាំងនៅពេលផ្តាច់ដោះ ។



- ចំណីសំរាប់កូនជ្រូកមានតំលៃថ្លៃ ដូចនេះយើងត្រូវប្រុងប្រយ័ត្នកុំខ្ជះខ្ជាយ ។
- យើងត្រូវផ្តល់ក្នុងបរិមាណតិចតួច តែច្រើនដងក្នុងមួយថ្ងៃ ។
- កូនជ្រូកមួយក្បាល ស៊ីចំណីអស់ប្រហែល ៣០០ក្រាម (៣ខាំ) ក្នុងកំឡុង១អាទិត្យមុនពេលផ្តាច់ដោះ ។

# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# បង្កាត់សិប្បនិម្មិតលើជ្រូក

ឧបត្ថម្ភដោយៈ

គម្រោងចិញ្ចឹមសត្វកម្ពុជា
សហគមន៍អឺរ៉ុប

សហគមន៍អឺរ៉ុប

អង្គការស្បៀង និងកសិកម្ម
នៃអង្គការសហប្រជាជាតិ

# មាតិកា

ទំព័រ


**១- តើអ្វីទៅជាការបង្កាត់សិប្បនិម្មិត? ............ ០១**

១-១- មជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិត ............ ០១

១-២- ការផលិតទឹកកាម ............ ១០

១-២-១- ការបង្ហាត់ជ្រូកបា ............ ១០

១-២-២- ការយកទឹកកាម ............ ១៤

១-២-៣- ការរៀបចំទឹកកាមយកទៅបង្កាត់ ............ ១៧

១-៣- ការបង្កាត់សិប្បនិម្មិត ............ ២៤

១-៣-១- សេចក្ដីផ្ដើម ............ ២៤

១-៣-២- ដំណើរការបង្កាត់ ............ ២៥

១-៤- សារៈប្រយោជន៍ការបង្កាត់សិប្បនិម្មិត ............ ៣១

១-៤-១- គុណភាពសេនេទិច ............ ៣១

១-៤-២- សុវត្ថិភាព ............ ៣៥

១-៤-៣- សេដ្ឋកិច្ច ............ ៣៨

១-៤-៤- គុណភាពទឹកកាម ............ ៣៩

**២- ដំណើរការបន្តពូជ** ........................................ ៤០

២-១- ភាពពេញវ័យ/ការបង្កាត់លើកដំបូង ........................................ ៤០

២-២- ការបង្កកំណើត ........................................ ៤០

២-៣- ការដាក់បាអត់ជាប់បណ្ដាលមកពីបា ........................................ ៤១

២-៤- បច្ចេកទេសជំរុញឱ្យមេឆាប់រកឈ្មោល........................................ ៤៤

**៣- សន្និដ្ឋាន** ........................................ ៤៦

# បង្កាត់សិប្បនិម្មិតលើជ្រូក

## ១. តើអ្វីទៅជាការបង្កាត់សិប្បនិម្មិត?

ការបង្កាត់សិប្បនិម្មិត គឺជាការបញ្ចូលទឹកកាមទៅក្នុងស្បូនមេជ្រូក នៅពេលមេរកឈ្មោលដោយប្រើឧបករណ៍សិប្បនិម្មិត ។

ការប្រមូលទឹកកាមនៅមជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិត ធ្វើឡើងដោយបុគ្គលិកមានបទពិសោធន៍ ហើយត្រូវបានរក្សាទុកក្នុងកម្រិតធានានូវសុវត្ថិភាព កំហាប់ និងគុណភាពរបស់ស្ពែម៉ាតូស៊ូអ៊ីត (មេជីវិតឈ្មោល)។ ការបង្កាត់សិប្បនិម្មិតគឺជាបច្ចេកទេសសាមញ្ញ ប៉ុន្តែត្រូវការក្បួនច្បាប់តឹងរ៉ឹង និងមានសំភារៈគ្រប់គ្រាន់ ។

## ១.១. មជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិត

### ក- <u>ទ្រុងជ្រូកបា</u>

ទ្រុងសម្រាប់ជ្រូកបាមានសារៈសំខាន់ណាស់ ដូចនេះជ្រូកបាត្រូវការទ្រុង :

- ទំហំពី ៦ ទៅ ៩ ម៉ែត្រការ៉េ ក្នុងមួយក្បាល
- ត្រូវមានទីធ្លាសមស្របដែលអាចឱ្យជ្រូកបាដើរបានស្រួល ដើម្បីជៀសវាងភាពស្លឹកស្រពន់ និងក្តៀន
- ត្រូវការពារកម្តៅ តែមានខ្យល់ចេញចូល និងមានពន្លឺគ្រប់គ្រាន់ ហើយការរក្សាឱ្យសីតុណ្ហភាពទាបគឺមានសារៈសំខាន់ណាស់សម្រាប់ការផលិតទឹកកាម ព្រោះថាពងស្វាសនៅក្រៅខ្លួនសត្វ។ បើសីតុណ្ហភាពបរិយាកាសខាងក្រៅខ្ពស់ធ្វើឱ្យជ្រូកមិនអាចផលិតស្ពែម៉ាតូសូអ៊ីត (មេជីវិតឈ្មោល) បានល្អទេ ។



ទ្រុងសមស្របសម្រាប់ជ្រូកបា នៅមជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិត (ខេត្តតាកែវ)



ទ្រុងតូចចង្អៀតៈ ជ្រូកបាមិនអាចធ្វើចលនាបាន



ពងស្វាសនៅខាងក្រៅខ្លួន ដូចនេះត្រូវរក្សាសីតុណ្ហភាពឱ្យនៅត្រជាក់



ទ្រុងគ្មានម្លប់ធ្វើឱ្យជ្រូកក្តៅខ្លាំង ហើយមិនអាចផលិតទឹកកាមបានល្អ



ទ្រុងមានម្លប់ ធានាបាននូវការផលិតទឹកកាមបានល្អ

## ខ- វិធានការអនាម័យ

ទឹកកាមជ្រូកបាត្រូវបានប្រើប្រាស់បង្កាត់ជាមួយមេជ្រូកជាច្រើន ដូច្នេះត្រូវប្រាកដថា មានសុខភាពល្អ។ ជំហានដំបូង ត្រូវការពារជ្រូកបាទប់ទល់កុំឱ្យឆ្លងជំងឺតាមមធ្យោបាយផ្សេង ដូចនេះត្រូវអនុវត្តវិធានការអនាម័យឱ្យបានត្រឹមត្រូវ ដូចជាៈ

- ធ្វើរបងមិនឱ្យអ្នកក្រៅចេញ-ចូលសេរី
- ចំពោះបុគ្គលិកដែលដើរបង្កាត់ច្រើនកន្លែង ត្រូវមុជទឹកសម្អាតខ្លួន ហើយស្លៀ សំលៀកបំពាក់របស់កសិដ្ឋាន និងត្រូវជ្រលក់ជើងក្នុងទឹកសម្លាប់មេរោគ។



វិធានការអនាម័យដោយមានរបង ការពារកុំឱ្យអ្នកក្រៅចេញ-ចូលសេរី



បន្ទាប់ពីមុជទឹករួចត្រូវផ្លាស់សំលៀកបំពាក់



ការសម្លាប់មេរោគលើស្បែកជើងមុនពេលចូលទ្រុងជ្រូកបា

គ- ជ្រូកបា ៖

ក្នុងមួយសប្តាហ៍ ជ្រូកបាមួយក្បាលផលិតទឹកកាមបានពី ៣០-៤០ កម្រិត ហើយបង្កាត់បានពី ១៥-២០ មេ ។ ដូចនេះត្រូវធានាថាបាមានសុខភាពល្អ នឹងត្រូវ ៖

- ជ្រើសរើសពីជ្រូកពូជល្អ
- ជាជ្រូកដែលសមស្របសម្រាប់ចិញ្ចឹមយកសាច់ លូតលាស់លឿន និងមានខ្លាញ់តិច
- មានពងស្វាសល្អ ។



ជ្រូកបាក្មេង ២ ក្បាល ពូជ ម៉ាក់ស្ទ័រ



ជ្រូកបានេះមិនអាចបង្កើនផលិតកម្មជ្រូកបានទេ



ពងស្វាសដែលល្អ



រលាកពងស្វាស
ដោយប្រូសសេឡូស៊ីស ធ្វើឱ្យបាមិន
ត្រឹមតែផលិតទឹកកាមមានគុណភាព
អន់ទេ ហើយថែមទាំងជាអ្នកចម្លង
ជំងឺផងដែរ ។



បានេះផលិតទឹកកាមបាន

តែត្រូវត្រួតពិនិត្យរាល់ថ្ងៃ

## ឃ- ការផ្តល់ចំណីដល់ជ្រូកបា ៖

- ដើម្បីធានាការផលិតទឹកកាមឱ្យបានល្អ ជ្រូកបាត្រូវតែមានស្ថានភាពដងខ្លួនល្អ
- ជ្រូកបាមិនត្រូវធាត់ពេកទេ ព្រោះជៀសវាងបញ្ហាជើង និង ធានាឱ្យបាអាចលោតពាក់មេបាន
- ជាទូទៅ ចំណីសម្រាប់ជ្រូកបាដូចគ្នានឹងចំណីរបស់មេជ្រូកផើមដែរ ។

ជ្រូកបាដែលមានស្ថានភាពដងខ្លួនល្អ



## ង- ការផ្តល់ចំណី រួមជាមួយនឹងចំណីបន្ថែម

- ការផលិតទឹកកាមល្អទៅបានលុះត្រាតែចំណីមានប្រូតេអ៊ីនខ្ពស់ (អាស៊ីតអាមីនេខ្ពស់ ដូចជា លីស៊ីន) ដូចនេះត្រូវផ្តល់បន្ថែមលីស៊ីនឱ្យជ្រូកស៊ី ចំនួន ៧ ថ្ងៃ ក្នុងមួយខែ
- ដើម្បីបង្កើនផលិតកម្ម និង គុណភាពទឹកកាម ជាពិសេសពេលអាកាសធាតុក្តៅត្រូវលាយ វីតាមីន សេ ចំនួន ១ ក្រាម រាល់ថ្ងៃ ។



ដើម្បីបង្កើនគុណភាពទឹកកាម ត្រូវបន្ថែមវីតាមីនសេ ក្នុងចំណីជ្រូកបា

## ច- កម្មវិធីចាក់វ៉ាក់សាំង

ចាក់វ៉ាក់សាំងរំលឹករៀងរាល់ ៦ខែ ម្ដងរួមមាន:

- ប៉េស្ដជ្រូក (CSF)
- ប៉ាវ៉ូវីរុស (Parvovirus)
- អូហ្សេស្គី (Aujesky)
- អុតក្ដាម ទ្រីវ៉ាឡង់ (FMD trivalent)




ត្រូវចាក់វ៉ាក់សាំងប៉ាវ៉ូដល់ជ្រូកបា

***ចំណាំ : រៀងរាល់ ៦ខែ ត្រូវចាក់ថ្នាំទម្លាក់បរាសិតឱ្យជ្រូកបាផងដែរ ដោយប្រើប្រាស់ អ៊ីវើមិចទីន។***

## ឆ- មន្ទីរពិសោធន៍

- ក្រោយពេលយកទឹកកាម គេត្រូវតែរៀបចំកម្រិតប្រើប្រាស់នៅមន្ទីរពិសោធន៍
- មន្ទីរពិសោធន៍ត្រូវតែស្អាត សម្លាប់មេរោគ និងត្រូវការសំភារៈច្បាស់លាស់ ដើម្បីការពារការឆ្លងមេរោគមកទឹកកាម
- គ្រប់សំភារៈទាំងអស់ ដែលប្រើជាមួយ (ផ្ទុក) ទឹកកាម ត្រូវតែសម្អាត និងសម្ងួតពីព្រោះទឹកអាចសម្លាប់មេជីវិតឈ្មោល (ស្ពែម៉ាតូសូអ៊ីត)។



មន្ទីរពិសោធន៍នៅមជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិតខេត្តតាកែវ



ឧបករណ៍សំខាន់ៗក្នុងមន្ទីរពិសោធន៍



ឧបករណ៍សម្ងួតគ្រប់សំភារៈទាំងអស់

## ១.២. ការផលិតទឹកកាម

### ១.២.១. ការបង្ហាត់ជ្រូកបា

ក- មេជ្រូកសិប្បនិម្មិត :

- ឧបករណ៍សំខាន់នៅក្នុងការបង្ហាត់សិប្បនិម្មិត គឺមេជ្រូកសិប្បនិម្មិត
- មេជ្រូកសិប្បនិម្មិត គឺជាមេដែលបាគិតថាជាមេជ្រូកពិត ហើយនៅពេលដែលជ្រូកបា ឃើញធ្វើឱ្យវាមានចំណង់ផ្លូវភេទ
- មេជ្រូកសិប្បនិម្មិតត្រូវតែធ្ងន់ និងរឹងមាំ ពីព្រោះជ្រូកបាអាចមានទម្ងន់រហូតដល់ ៣០០ គីឡូក្រាម ។



ជ្រូកបាឡើងពាក់មេជ្រូកសិប្បនិម្មិត

## ខ- ការបង្រៀនជ្រូកបា

- ជ្រូកបាក្មេងមិនឡើងពាក់មេសិប្បនិម្មិតដោយខ្លួនវាទេ ដូចនេះគេចាំបាច់ត្រូវតែបង្រៀនជាមុន តែវាមានការលំបាកណាស់ ហើយជាការងារបច្ចេកទេស
- ជ្រូកបា គួរតែបង្រៀនឱ្យរៀនឡើងពាក់មេសិប្បនិម្មិត នៅពេលអាយុបានពី ៧-៨ ខែ
- ជ្រូកបាខ្លះងាយស្រួលបង្រៀនណាស់ ប៉ុន្តែជ្រូកបាខ្លះទៀតទាមទារឱ្យមានបទពិសោធន៍ក្នុងការបង្ហាត់ ។



បសុពេទ្យធ្វើឱ្យជ្រូកបាក្មេងមានសំរើប និងបង្ហាញមេជ្រូកសិប្បនិម្មិតឱ្យវាឃើញ



ជ្រូកបាមិនស្គាល់មេសិប្បនិម្មិតទេ ដូចនេះត្រូវតែបង្រៀនវាថែមទៀត

ជ្រូកបានេះខ្លាចមេជ្រូកសិប្បនិម្មិត





មុនដំបូងគួរតែបង្រៀនវាឱ្យឡើងពាក់លើខ្នងបសុពេទ្យ

ការបង្រៀនជ្រូកបាវ័យក្មេងទាមទារអ្នកមានបទពិសោធន៍ច្រើន



ជួយលើកឱ្យបាឡើងពាក់មេជ្រូកសិប្បនិម្មិត



បសុពេទ្យចាប់ផ្តើមធ្វើឱ្យជ្រូកបា
មានសំរើប



ជ្រូកបាអាចយកទឹកកាមនៅលើកដំបូងបាន

## ១.២.២. ការយកទឹកកាម

- កន្លែងចិញ្ចឹមជ្រូកបាត្រូវតែស្ងាត់ស្ងៀម ហើយជៀសវាងអ្នកចូលមើលច្រើន
- ការយកទឹកកាមគឺជាការងារបច្ចេកទេស ដូចនេះបុគ្គលិកត្រូវតែទទួលការបណ្ដុះបណ្ដាល និងអនុវត្តឱ្យបានតឹមត្រូវ
- ត្រូវមានច្បាប់ទម្លាប់ត្រឹមត្រូវ និងហ្មត់ចត់ ដើម្បីឱ្យប្រាកដថាទឹកកាមមានគុណភាពល្អ
- ការយកទឹកកាមពីបាមិនងាយស្រួលទេ ដូចនេះអ្នកយកទឹកកាមពីជ្រូកបា ចាំបាច់ត្រូវតែស្គាល់បាឱ្យបានច្បាស់លាស់ ហើយគួរមានតែបុគ្គលិក ១ រឺ ២នាក់ ប៉ុណ្ណោះ ដែលជួយជំរុញបាឱ្យមានចំណង់។



បសុពេទ្យមកដល់យ៉ាងស្ងៀមស្ងាត់ក្នុងទ្រុង ហើយស្ទាបអង្អែលជ្រូកបា



ចាប់លិង្គជ្រូកដោយប្រុងប្រយត្ន័



លាងសម្អាត និងសម្លាប់មេរោគនៅលិង្គ



ជ្រូកបាសប្បាយចិត្ត



ចាប់ផ្តើមយកទឹកកាម ហើយមិនត្រូវឱ្យដៃ
ប៉ះពាល់នឹងទឹកកាមឡើយ



ទឹកកាមបាញ់ចេញ ២ លើកៈ

លើកទី១ ចេញខាប់ដូចម្សៅ

( ត្រូវយកចេញ)



ការយកទឹកកាមបានសម្រេចគឺ

អាចមានចំណុះ ៧០០ម.ល

## ១.២.៣. ការរៀបចំទឹកកាមយកទៅបង្កាត់

### ក- ការត្រួតពិនិត្យទឹកកាម :

ការត្រួតពិនិត្យទឹកកាមជាការងារមួយចាំបាច់ ដែលត្រូវធ្វើមុនពេលរៀបចំយកទឹកកាមទៅបង្កាត់ ។ គេត្រូវពិនិត្យទឹកកាមលើ ៣ចំណុចសំខាន់គឺ :

- កំហាប់របស់ទឹកកាម
- អត្រាស្លាប់របស់មេជីវិតឈ្មោល
- ភាពខុសប្រក្រតីរបស់មេជីវិតឈ្មោល ។

*ប្រសិនបើគុណភាពទឹកកាមមិនបានទៅតាមកម្រិតបទដ្ឋានទេ គេមិនត្រូវរៀបចំវាយកទៅបង្កាត់ទេ ដូចនេះត្រូវតែបោះចោល!*

នៅមជ្ឈមណ្ឌលតូចៗ ការវាយតំលៃពីកំហាប់ជួយឱ្យគេដឹងពីចំនួនកម្រិតប្រើប្រាស់ទៅលើមេជ្រូក (តិចបំផុត ១ កោដិមេជីវិតឈ្មោលក្នុងមួយកម្រិត) ។



ភាពមិនប្រក្រតីរបស់មេជីវិតឈ្មោល



បសុពេទ្យយកសំណាក ដើម្បីពិនិត្យមើល
មេជីវិតឈ្មោល



គ្រូតពិនិត្យគុណភាពមេជីវិតឈ្មោល
ដោយប្រើមីក្រូទស្សន៍



មេជីវិតឈ្មោលមានគុណភាពល្អ



មេជីវិតឈ្មោលមានគុណភាពអន់

## ខ- ការរៀបចំទឹកកាម

ការរៀបចំទឹកកាមគឺធ្វើឡើងក្នុងគោលបំណងបែងចែកទឹកកាមទៅតាមកម្រិត (ដូស) ដោយក្នុងមួយដូស ត្រូវមាន ១០០ មីលីលីត្រ ។ ទឹកកាមត្រូវលាយជាមួយផលិតផលពិសេស គឺសូលុយស្យុងម្សៅ បេតេអេស (BTS) ដែលមានសីតុណ្ហភាព ៣៨ អង្សាសេ ។

បេតេអេស មានផ្ទុកចំណីសម្រាប់ចិញ្ចឹមមេជីវិតឈ្មោល និង ថែរក្សាមេជីវិតឈ្មោល ឱ្យរស់នៅបានយូរ (មេជីវិតឈ្មោល គឺជាសរីរៈមានជីវិត ដូចនេះវាត្រូវការស៊ីចំណី) ហើយដែលក្នុងម្សៅបេតេអេសនោះមានប្រុចតូស ដែលជាចំណីដ៏ល្អ ។ លើសពីនេះទៅទៀតក្នុងម្សៅបេតេអេស មានអង់ទីប៊ីយ៉ូទិកដើម្បីការពារការឆ្លងមេរោគចូលទៅក្នុងមេជីវិតឈ្មោល ។



ការពង្រាវ បេតេអេស



ល្បាយស្មើសាច់នៃបេតេអេស



កម្តៅល្មមគឺ ៣៨អង្សាសេ



ទឹកកាមត្រូវបានគេចាក់ចូលទៅក្នុង
បេតេអេស ដោយប្រុងប្រយ័ត្ន និងថ្នមៗ

ត្រូវកូរទឹកកាមដោយប្រុងប្រយ័ត្ន
ដើម្បីរក្សាជីវិតរបស់មេជីវិតឈ្មោល



## គ- ការច្រកកម្រិតប្រើ

ទឹកកាមដែលលាយរួចត្រូវបានគេច្រកដាក់ក្នុងដបចំណុះ ១០០ ម.ល ក្នុងមួយដូស ព្រោះជាចំណុះមួយដែលអាចរាយប៉ាយបានគ្រប់គ្រាន់នៅក្នុងស្បូន។ គោលបំណងនៃការច្រកគឺដើម្បីការពារទឹកកាម ពីការឆ្លងមេរោគក្នុងកំឡុងពេលដឹកជញ្ជូន ជាពិសេសដបត្រូវបានបិទគំរបជិត។ ដបជ័រសម្រាប់ ដាក់ទឹកកាមត្រូវស្ដើងដើម្បីឱ្យឆាប់ត្រជាក់ ហើយមុនពេលបង្កាត់ត្រូវកម្ដៅឱ្យក្ដៅឧណ្ហ។



ដបជ័រសម្រាប់ច្រកទឹកកាម



ចាក់បំពេញក្នុងដបដោយប្រុងប្រយ័ត្ន
ដើម្បីកុំឱ្យប៉ះពាល់ដល់មេជីវិតឈ្មោល



បិទដបឱ្យជិតដើម្បីការពារកុំឱ្យឆ្លងមេរោគ ដល់ទឹកកាម

## ឃ- ការថែរក្សាទឹកកាម

ទឹកកាមអាចរក្សាទុកបាន ២ថ្ងៃ ប៉ុន្តែសំខាន់ត្រូវ :

- ជៀសវាងកុំឱ្យកម្តៅប្រែប្រួល ដូចនេះត្រូវថែរក្សាក្នុងសីតុណ្ហភាពត្រជាក់បន្ទាប់ ពីការរៀបចំរួច ក្នុងកំឡុងពេលដឹកជញ្ជូន និងមុនពេលបង្កាត់
- ជៀសវាងការក្រឡុកខ្លាំង ប៉ុន្តែត្រូវបង្វិលដបរៀងរាល់ ៦ម៉ោង
- សម្រាប់មជ្ឈមណ្ឌល ទឹកកាមត្រូវថែរក្សាក្នុងសីតុណ្ហភាព ១៦ អង្សាសេ គឺក្នុងទូរទឹកកកជាប្រចាំ
- ការដឹកជញ្ជូនត្រូវប្រើធុងទឹកកក ហើយគេត្រូវច្រកទឹកកកក្នុងថង់ប្លាស្ទិចជាមុន ដើម្បីជៀសវាងកុំឱ្យដបទឹកកាមប៉ះផ្ទាល់ជាមួយទឹកកក
- មុនយកទៅបង្កាត់ ត្រូវទុកដបទឹកកាមនៅខាងក្រៅ ពី ២ - ៣ នាទី ដើម្បីឱ្យកម្តៅឡើងសន្សឹមៗរហូតដល់ ៣០-៣៥ អង្សាសេ តែជៀសវាងកុំឱ្យត្រូវកម្តៅ និងពន្លឺ។




ទូរទឹកកកនៅក្នុងមជ្ឈមណ្ឌលដែលមាន សីតុណ្ហភាព ពី ១៦ ទៅ ១៨អង្សាសេ



ធុងទឹកកកដែលល្អសម្រាប់ការដឹកជញ្ជូនៈ គឺ ទឹកកាមមិនប៉ះផ្ទាល់ជាមួយទឹកកក



នៅប្រទេសកម្ពុជាអាកាសធាតុក្តៅ ទឹកកាមអាចមានកម្តៅលើសពី ៣០អង្សាសេ
នៅពេលយកចេញក្រៅពីធុងទឹកកក

ដើម្បីបានទឹកកាមជ្រូកដែលមានគុណភាពល្អយើងត្រូវការ :

- ទីធ្លាសមរម្យ និងមានអនាម័យល្អត្រឹមត្រូវ
- ជ្រូកបាពូជកូនកាត់ល្អ
- បុគ្គលិកបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ
- មានឧបករណ៍គ្រប់គ្រាន់

ការទទួលខុសត្រូវនៅមជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិតត្រូវមានកម្រិតខ្ពស់ ពីព្រោះភាពជោគជ័យរបស់កម្មវិធីបង្កាត់សិប្បនិម្មិត មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងគុណភាពនៃកម្រិតទឹកកាមដែលបានផលិត ។

## ១.៣. ការបង្កាត់សិប្បនិម្មិត

### ១.៣.១. សេចក្តីផ្តើម

ការបង្កាត់សិប្បនិម្មិតជ្រូកត្រូវអនុវត្តឱ្យបានត្រឹមត្រូវបំផុត។ ជាទូទៅការបង្កាត់សិប្បនិម្មិតត្រូវបានគេអនុវត្តនៅបណ្តាប្រទេសជាច្រើន ហើយប្រហែល ៩០ភាគរយ ត្រូវបានបង្កាត់ដោយសិប្បនិម្មិត ហើយមានតែ ១០ ភាគរយ ប៉ុណ្ណោះ ដែលបង្កាត់តាមធម្មជាតិ។ បច្ចេកទេសនេះបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់អ្នកចិញ្ចឹមជ្រូក។ តែចាំបាច់ត្រូវអនុវត្តតាមបច្ចេកទេសឱ្យបានហ្មត់ចត់។ ដើម្បីឱ្យមានទំនុកចិត្តលើការបង្កាត់សិប្បនិម្មិតនេះ មជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិតត្រូវបង្កាត់ឱ្យបានជោគជ័យពី ៨៥ ភាគរយឡើងទៅ។



បសុពេទ្យកំពុងអនុវត្តការបង្កាត់សិប្បនិម្មិត

## ១.៣.២. ដំណើរការបង្កាត់

ក- **<u>ការតាមដានការរកឈ្មោល</u>:** គឺជាបញ្ហាសំខាន់ដើម្បីទទួលបានជោគជ័យក្នុងការបង្កាត់

- ការតាមដានការរកឈ្មោលត្រូវតែធ្វើ ២ដង ក្នុង១ថ្ងៃ ចន្លោះ ១២ម៉ោងម្តង
- ជ្រើសរើសបញ្ហាស្ត្រេស និង សំលេងរំខាន (ឡូឡា) គឺត្រូវធ្វើដោយស្ងៀមស្ងាត់ ។



យោនីឡើងក្រហមនៅពេលរកឈ្មោល

**សញ្ញារកឈ្មោល :**

- យោនីរីកធំ និងពណ៌ក្រហម
- ពេលបសុពេទ្យឡើងជិះលើខ្នងមេជ្រូក វានៅស្ងៀម ហើយចំពោះមេជ្រូកដែលនៅមិនស្ងៀមគេមិនអាចបង្កាត់បានទេ
- វត្តមានរបស់ជ្រូកបាសំរួលដល់ការតាមដានការរកឈ្មោល ។



វិធីសាស្ត្រល្អដើម្បីត្រួតពិនិត្យការនៅស្ងៀមរបស់មេជ្រូក

មេជ្រូករកឈ្មោលត្រៀមសម្រាប់បង្កាត់

គឺនៅស្ងៀម



## ខ- ពេលវេលាល្អសម្រាប់ការបង្កាត់

- មេជ្រូកបង្កាត់សិប្បនិម្មិតត្រូវបង្កាត់ ២ ដង
- ចន្លោះពេលទាំង ២ នោះអាចមានរវាងពី ១០-១៨ ម៉ោង។ ទឹកកាមអាចរស់នៅក្នុងស្បូនបាន ២៤ម៉ោង
- **មេជ្រូកក្រមុំ** ត្រូវបង្កាត់លើកទី ១ តិចជាង ១២ ម៉ោង ក្រោយពេលឃើញថាវានៅស្ងៀម និងនៅលើកទី ២ ត្រូវធ្វើឡើង ១២ ម៉ោងក្រោយពីបង្កាត់លើកទី ១
- **មេជ្រូកធ្លាប់កូនរួច** ត្រូវបង្កាត់លើកទី១ នៅ ២៤ ម៉ោង ក្រោយពេលឃើញថាវានៅស្ងៀម និងលើកទី២ ត្រូវធ្វើឡើង ១២ ម៉ោងក្រោយពីលើកទី ១។





សម្រាប់ការបង្កាត់សិប្បនិម្មិតមេជ្រូកក្រមុំ និង មេជ្រូកធ្លាប់កូនរួចមានពេលវេលាបង្កាត់ខុសគ្នា

## គ- ការរៀបចំទំនាក់ទំនងដើម្បីបង្កាត់សិប្បនិម្មិតជាមួយមជ្ឈមណ្ឌល

ទំនាក់ទំនងនេះមានសារៈសំខាន់ ព្រោះកន្លែងដែលត្រូវបង្កាត់អាចនៅឆ្ងាយពីមជ្ឈមណ្ឌល

- មេជ្រូកធ្លាប់កូនរួច និងមេក្រមុំអាចរកឈ្មោលនៅថ្ងៃ សៅរ៍ ឬ ថ្ងៃអាទិត្យ នៅពេលព្រឹក ឬ ពេលល្ងាច ដូចនេះត្រូវមានអ្នកប្រចាំការគ្រប់ពេល
- សំខាន់ត្រូវបណ្តុះបណ្តាលអ្នកចិញ្ចឹមឱ្យចេះតាមដានការរកឈ្មោល និង ពេលវេលាសមស្របសម្រាប់បង្កាត់ ដើម្បីជៀសវាងការចំណាយពេលឥតប្រយោជន៍
- អ្នកចិញ្ចឹមនៅតំបន់ជនបទអាចទទួលការបណ្តុះបណ្តាលពីរបៀបបង្កាត់ ដោយការធ្វើបង្ហាញពីរបៀបបង្កាត់សិប្បនិម្មិត ២ដង ។



បសុពេទ្យគួរតែមានលទ្ធភាពអនុវត្តការបង្កាត់សិប្បនិម្មិតជារៀងរាល់ថ្ងៃ

## ឃ- បច្ចេកទេសបង្កាត់សិប្បនិម្មិត

- មិនត្រូវបង្កាត់មេជ្រូកណាដែលនៅមិននៅស្ងៀមទេ
- ជាការល្អត្រូវអនុវត្តដោយយកជ្រូកបាដាក់នៅពីមុខមេជ្រូក
- សម្អាតយោនីដោយប្រើថ្នាំសម្លាប់មេរោគដែលអាចរកបាន ឬ សាប៊ូ
- ប្រើក្រណាត់ជូតសម្ងួតយោនីឱ្យបានស្ងួតល្អ
- ស៊កបញ្ចូលបំពង់ជ័រសម្រាប់បង្កាត់យឺតៗរហូតដល់មានអារម្មណ៍ថាដល់កស្បូន
- ដាក់ភ្ជាប់ដបទឹកកាមជាមួយបំពង់ជ័រសម្រាប់បង្កាត់ ។



ជ្រូកបានៅពីមុខមេជ្រូកជួយ
សំរួលដល់ការបង្កាត់សិប្បនិម្មិត



សម្អាតយោនី និងជូតសម្ងួតយោនី
របស់មេជ្រូកឱ្យបានស្អាតល្អ

ការស៊កបញ្ចូលបំពង់ជ័រ សម្រាប់បង្កាត់





ការភ្ជាប់ដបទឹកកាមជាមួយ នឹងបំពង់សម្រាប់បង្កាត់

## បច្ចេកទេសបង្កាត់សិប្បនិម្មិត

- ដើម្បីជួយ និង ពន្លឿនដល់ការស្រូបចូលនូវទឹកកាម គេត្រូវស្ទាបអង្អែលត្រគាកមេជ្រូក
- ទុកឱ្យមេជ្រូកខំប្រឹងស្រូបយកទឹកកាមដោយខ្លួនវា
- ការបង្កាត់សិប្បនិម្មិតជាមធ្យមចំណាយពេល ៣ នាទី
- រង់ចាំ ៥ ទៅ ១០នាទី មុនពេលទាញបំពង់ជ័រសម្រាប់បង្កាត់ចេញមកក្រៅ
- ជួនកាលទឹកកាមខ្លះ (តិចតួច) ចេញមកក្រៅ តែមិនប៉ះពាល់ដល់ការបង្កកំណើតទេ
- ត្រួតពិនិត្យបំពង់ជ័រសម្រាប់បង្កាត់ដើម្បីពិនិត្យមើលក្រែងមានខ្ទុះ ឬ ឈាម ។



ការស្ទាបអង្អែលត្រគាក
និងសង្កត់ខ្នងដើម្បីពន្លឿនការ
ស្រូបចូលរបស់ទឹកកាម



ការចាក់បង្ហូរទឹកកាម
ចំណាយពេល ពី ១ - ៣ នាទី



ក្រោយពេលបង្កាត់
កុំដកបំពង់ជ័រសម្រាប់បង្កាត់
ចេញភ្លាមៗ

## ១.៤. សារៈប្រយោជន៍នៃការបង្កាត់សិប្បនិម្មិត

- នាំពូជល្អៗទៅដល់កសិករតូចតាច ( ចិញ្ចឹមជាលក្ខណៈគ្រួសារ)
- ទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺ
- បាមួយអាចបង្កាត់បានមេច្រើន
- ធានាទឹកកាមមានគុណភាពល្អ

### ១.៤.១. គុណភាពសេនេទិច

<u>ផលប្រយោជន៍ :</u>

- ការបង្កាត់ខ្វែងគឺជាវិធីសាស្ត្រដ៏ល្អក្នុងការបង្កើនគុណភាពកូនជ្រូក
- បាដែលជ្រើសរើសនឹងអាចផ្តល់កូនចំនួនពី ៨-១២ ក្បាល
- មានតែការជ្រើសរើសបាល្អរបស់ក្រុមហ៊ុនច្បាស់លាស់ប៉ុណ្ណោះ ទើបអាចធានាគុណភាពបាបានល្អ
- សម្រាប់ប្រទេសកម្ពុជាយើង គេត្រូវធ្វើការជ្រើសរើសបាទាំងឡាយណាដែលអាចបង្កើនផលប្រយោជន៍ខ្ពស់ បើទោះជាគេបង្កាត់ជាមួយមេជ្រូកពូជក្នុងស្រុកក៏ដោយ ។



តើបានេះអាចបង្កើនផលិតកម្មរបស់មេជ្រូកដែរឬទេ?



បាពូជ ម៉ាស្ទ័រ ១៦ (Maxter 16) ពូជកូនកាត់របស់បារាំង



ពូជកូនកាត់ (មេពូជក្នុងស្រុកបង្កាត់សិប្បនិម្មិតជាមួយទឹកកាមបាពូជម៉ាក់ស្ទ័រ)

**បង្កើនផលិតភាព ៖**

- សាយកូន ៖ កូនជ្រូកច្រើនក្នុងមួយសំបុក
- កូនទើបកើតថ្លោស
- កូនកើតមានទំហំប៉ុនគ្នា។

**នៅពេលគេបំប៉នជ្រូកដោយប្រើចំណីដូចគ្នា ៖**

- កំណើនទម្ងន់ប្រចាំថ្ងៃកើនឡើង
- បន្ថយអែហ្វស៊ីអ (FCR) ( បរិមាណចំណីដែលស៊ី ដើម្បីកើនទម្ងន់ ១ គ.ក្រ)



កូនជ្រូកច្រើនក្នុងមួយសំបុក



ទម្ងន់ពេលកើតកើនឡើង

ទម្រង់រូបរាង របស់កូនជ្រូកកូនកាត់ ដែលបង្កាត់ជាមួយបាម៉ាស្ទ័រ :

- កូនរស់នៅពេលកើតសរុបៈ ១១ ក្បាល
- កូនជ្រូករស់នៅពេលផ្តាច់ដោះ : ៩ ក្បាល
- ទម្ងន់ពេលផ្តាច់ដោះ : ៧,៧ គីឡូក្រាម
- ជ្រូកសម្រាប់បំប៉នក្នុងមេមួយក្បាល ក្នុងមួយឆ្នាំ : ១៨ ក្បាល
- ចំណាយចំណីពី ៣-៣,៣ គីឡូក្រាម ដើម្បីកើនទម្ងន់បាន ១ គីឡូក្រាម (អែហ្វសុីអាមានពី ៣-៣,៣)
- ជ្រូកអាយុតិចជាង ១៦០ ថ្ងៃ មានទម្ងន់ ៨០ គ.ក្រ ។



ជ្រូកបំប៉នពូជកូនកាត់

## ១.៤.២.សុវត្ថិភាព

នៅពេលបង្កាត់ដោយប្រើបាពាក់ផ្ទាល់ នឹងធ្វើឱ្យមានការឆ្លងជំងឺជាច្រើនដល់មេ ជាពិសេសសពួកមេរោគ ដែលរស់នៅលើតើក និង ផ្លូវដង្ហើម ហើយបាបញ្ចេញមេរោគច្រើនទៅឱ្យមេមានដូចជា:

- ជំងឺអុតក្តាម
- ជំងឺប៉េស្តជ្រូក
- ជំងឺកញ្ជ្រិល
- ជំងឺផ្លូវដង្ហើម ជាពិសេសបង្កឡើងដោយមីកូប្លាស្មា។



ការប៉ះផ្ទាល់នៅពេលបង្កាត់តាមធម្មជាតិនឹងធ្វើឱ្យមានការចម្លងជំងឺខ្លាំងក្លា

ក្នុងដំណាក់កាលមេរោគសម្ងំ បានៅតែមានសុខភាពល្អ តែវាបញ្ចេញមេរោគមកក្រៅរួចជាស្រេច។



វីរុសជំងឺប៉េស្តជ្រូកមានច្រើននៅក្នុងតើក ហើយត្រូវបានបញ្ចេញមកក្រៅតាម មាត់ ច្រមុះ និង ភ្នែក។

មេរោគជំងឺកញ្ជ្រិល (Erysipelae) មានច្រើននៅតាមផ្លូវដង្ហើម



ជំងឺអុតក្តាមជាជំងឺឆ្លងរាតត្បាតខ្លាំង ហើយនៅពេលមេរោគកំពុងរាតត្បាតក្នុងតំបន់ ត្រូវជៀសវាងកុំឱ្យបាចូលក្នុងកន្លែងចិញ្ចឹម ។





មីកូប្លាស្មា និងប៉ាស្ទឺរេឡា ត្រូវបានបញ្ចេញមកក្រៅតាមច្រមុះ និងមាត់

## ១.៤.៣. សេដ្ឋកិច្ច

### ក- ការចំណាយប្រចាំឆ្នាំសម្រាប់បាមួយក្បាល

- ការសាងសង់ទ្រុង
- កម្មវិធីវ៉ាក់សាំង
- ការព្យាបាលផ្សេងៗ
- ការផ្តល់ចំណីប្រចាំថ្ងៃឱ្យបានគ្រប់គ្រាន់ ដើម្បីទទួលបានទឹកកាមគុណភាពល្អ
  - បើប្រើចំណីផ្សំសម្រេច : ៣៥០ ដុល្លា ក្នុងមួយឆ្នាំ
  - បើប្រើចំណីផ្ទះបាយ : ២០០ ដុល្លា ក្នុងមួយឆ្នាំ ។



ជ្រូកបាស៊ីរាល់ថ្ងៃ!

### ខ- ចំណាយក្នុងមួយដូស ( បរិមាណទឹកកាមបង្កាត់មេ ១ ) :

- ចំពោះជ្រូកបាដែលផ្តល់ចំណីល្អ យើងអាចយកទឹកកាមបាន២ដងក្នុងមួយអាទិត្យ
- ការប្រមូលម្តង ជាមធ្យមអាចរៀបចំបាន ១០ ដូស ដែល ស្មើនឹង ៥០០ មេ × ២ ដូស ក្នុងមួយឆ្នាំ
- ការចំណាយលើបំពង់ជ័រសម្រាប់បង្កាត់ចំនួន២ បេតេអេស (BTS) និង ដបជ័រចំនួន២ អស់សរុប ២ ដុល្លា
- កន្លែងបង្កាត់អាចលក់កម្រិត២ដូស (ដើម្បីបង្កាត់មេមួយ) ក្នុងតំលៃ ១៥០០០ រៀល ។



តាមរយៈការបង្កាត់សិប្បនិម្មិត នេះ
បាមួយអាចបង្កាត់បានមេ
ចំនួន ៥០០ ក្បាល ក្នុងមួយឆ្នាំ

## ១.៤.៤.គុណភាពទឹកកាម :

ប្រសិនបើបាមានបញ្ហាគ្រុនក្តៅខ្លាំងដោយសារជំងឺឆ្លង ក្នុងកំឡុងពេល ៣ សប្តាហ៍ បន្ទាប់ពីជ្រូកមានសុខភាពល្អឡើងវិញ ទឹកកាមរបស់វាមិនមានមេជីវិតឈ្មោលទេ។ ដូចគ្នានេះដែរ ចំពោះបាបង្កាត់មេរាល់ថ្ងៃនឹងធ្វើឱ្យដង់ស៊ីតេ និង សកម្មភាពរបស់មេជីវិតឈ្មោលមានកម្រិតទាប ហើយជានិច្ចកាលមិនសមស្របសម្រាប់ផលិតកូនជ្រូកឱ្យបានច្រើននោះទេ ។ នៅមជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិត ចាំបាច់ត្រូវត្រួតពិនិត្យតាមមីក្រូទស្សន៍រាល់គ្រប់សំណាកទាំងអស់ ដើម្បីធានាឱ្យមានមេជីវិតឈ្មោល ៣ កោដិក្នុងមួយកម្រិត ។

មជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិត
ត្រូវធានាកុំឱ្យមានអ្វីផ្សេងទៀតនៅក្នុងដប



## ២-ដំណើរការបន្តពូជ

### ២-១-ភាពពេញវ័យ/ការបង្កាត់លើកដំបូង :

- ដើម្បីឱ្យមេផ្តល់ផលប្រយោជន៍ខ្ពស់ គេចាំបាច់ត្រូវធ្វើឱ្យមេឆាប់ចាប់ផ្តើមរកឈ្មោល
- តែសភាពរបស់មេក្រមុំ ត្រូវតែសមស្រប ដើម្បីធានាឱ្យសត្វធំធាត់ និង ផលិតទឹកដោះ
- ត្រូវរង់ចាំដល់មេក្រមុំរកឈ្មោលលើកទី ៣ ទើបបង្កាត់ គឺមេក្រមុំមានអាយុ ៨ ខែ
- មេក្រមុំត្រូវមានទម្ងន់ ១២០ គ.ក្រ
- មេកើតកូនលើកដំបូង ពេលមានអាយុ ១ ឆ្នាំ នឹងមានទម្ងន់ពី ១៦០-១៨០ គ.ក្រ។



ស្ថានភាពល្អសម្រាប់បន្តពូជ

### ២-២-ការបង្កកំណើត

ការបង្កកំណើតគឺជាលទ្ធភាពផលិតកូនរបស់មេបន្ទាប់ពីបង្កាត់ (តាមធម្មជាតិ ឬដោយសិប្បនិម្មិត) ហើយអ្នកចិញ្ចឹមនឹងសន្សំថវិកាបានច្រើន ប្រសិនបើការបង្កាត់លើកដំបូងទទួលបានជោគជ័យ។ មានន័យថាគេត្រូវកាត់បន្ថយការត្រឡប់មករកឈ្មោលឡើងវិញ។ នៅពេលបង្កាត់មិនជាប់មេជ្រូកនឹងរកឈ្មោលនៅ ២១ ថ្ងៃ បន្ទាប់ ដូចនេះម្ចាស់ជ្រូកត្រូវផ្តល់ចំណី ២១ ថ្ងៃទៀត (ចំណាយប្រហែលពី ១២-២០ ដុល្លា) ដោយមិនមានផលប្រយោជន៍អ្វីសោះ។ វិធីសាស្ត្រសំខាន់ដើម្បីបង្កើនចំនួនកូនចាំបាច់ត្រូវការពារបញ្ហាសំខាន់ៗ ដែលនាំឱ្យបង្កាត់មិនជាប់។



បើទោះជាមិនផើម
ក៏មេជ្រូកត្រូវការស៊ីរាល់
ថ្ងៃដែរ!

## ២.៣. ការដាក់បាអត់ជាប់បណ្ដាលមកពីបា

ការដាក់បាអត់ជាប់អាចបណ្តាលមកពីទឹកកាមរបស់បាមានគុណភាពអន់ ដែលជាហេតុធ្វើឱ្យមេជីវិតឈ្មោលមិនគ្រប់ចំនួន ដូចនេះដើម្បីធានាការបង្កកំណើតជាមួយមេជីវិតញីបានល្អចាំបាច់ត្រូវមានមេជីវិតឈ្មោលចំនួនពី ១-៣ កោដិ។

ដើម្បីធានាឱ្យមេជីវិតឈ្មោលមានគ្រប់ចំនួន ក្នុងដំណើរការបង្កាត់សិប្បនិម្មិត ទឹកកាមត្រូវបានត្រួតពិនិត្យតាមមីក្រូទស្សន៍ និង ដាក់ពណិបានត្រឹមត្រូវ។

ទឹកកាមដែលមានគុណភាពអន់
មិនអាចបង្កកំណើតបានទេ



មានមូលហេតុជាច្រើនដែលធ្វើឱ្យទឹកកាមរបស់បាមានគុណភាពអន់ :

**១- បាមានជំងឺ :** ប្រសិនបើបាមានបញ្ហាកម្ដៅឡើងខ្ពស់ នោះធ្វើឱ្យទឹកកាមមានគុណភាពអន់ បើទោះវាជាពីជំងឺក៏ដោយ ហើយពិសេសក្នុងរវាង ២-៣ សប្ដាហ៍ បន្ទាប់ពីជា។ គេអាចការពារបញ្ហានេះបានគឺពេលបាមានជំងឺ ប្រើប៉ារ៉ាសេតាមុល (Paracetamol) ឬ អាណាល់ហ្សាំង (Analgine) ឬ តុលហ្វេឌីន (Tolfedine) ឬ កាល់ម៉ាហ្សាំង (Calmagine) ដើម្បីបញ្ចុះកម្ដៅ។ ម្យ៉ាងវិញទៀតក្នុងចន្លោះពេល ៣ សប្ដាហ៍ បន្ទាប់ពីជាពីជំងឺ គេមិនត្រូវប្រើប្រាស់បាសម្រាប់បង្កាត់ឡើយ ។



គ្រុនក្ដៅបញ្ឈប់ការផលិតមេជីវិតឈ្មោល

**២- បាក្មេងពេក** មិនអាចផលិតទឹកកាមឱ្យមានគុណភាពល្អទេ ជួនកាលដោយសារពងស្វាសលូតលាស់មិនទាន់ពេញលេញ ដូចនេះគេមិនត្រូវប្រើបាដែលមានអាយុតិចជាង ៨ ខែ ឡើយ ហើយត្រូវពិនិត្យមើលការលូតលាស់របស់ពងស្វាសផងដែរ ។



បានេះមានអាយុ ៥ ខែ ដូចនេះវានៅក្មេងពេក ហើយពងស្វាសរបស់វាលូតលាស់មិនទាន់ពេញលេញ ។

**៣- បាពាក់មេច្រើនពេកក្នុងមួយសប្តាហ៍** ជាហេតុធ្វើឱ្យទឹកកាមមានគុណភាពអន់ផងដែរ ដូចនេះចន្លោះពេលបង្កាត់ដ៏ល្អនោះគឺ ២ ដង ក្នុងមួយសប្តាហ៍ ។

**៤- ដោយសារអាកាសធាតុក្តៅពេក**

ដើម្បីឱ្យជ្រូកបាផលិតមេជីវិតឈ្មោលបានល្អ ចាំបាច់ត្រូវ :

- លាយវីតាមីនសេក្នុងចំណីចំនួន ១ ក្រាម/ថ្ងៃ
- បន្ថែមអាស៊ីតអាមីនេ (លីស៊ីន) ចំនួន ១ សប្តាហ៍ ក្នុងខែ ។



ក្នុងមួយសប្តាហ៍ៗ កុំប្រើបាឱ្យពាក់មេច្រើនពេក !

## ២.៤. បច្ចេកទេសជំរុញឱ្យមេឆាប់រកឈ្មោល

បច្ចេកទេសសំខាន់ៗ ដើម្បីជំរុញឱ្យមេឆាប់រកឈ្មោល ក្រោយពីផ្តាច់ដោះ ឬ សម្រាប់មេក្រមុំមាន ៖

**ក- ស្រេ្តស ៖** ស្រេ្តសគឺជាកត្តាដ៏សំខាន់ ដែលធ្វើឱ្យមេឆាប់រកឈ្មោល

- ការផ្តាច់ដោះគឺបង្កបញ្ហាស្រេ្តស តែសម្រាប់មេក្រមុំ អ្នកចិញ្ចឹមចាំបាច់ធ្វើឱ្យវាមានស្រេ្តស
- យកមេជ្រូកទៅទ្រុងថ្មី ធ្វើឱ្យមេជ្រូកស្រេ្តស
- ការដាក់មេជ្រូក ២-៣ ក្បាលក្នុងទ្រុងតែមួយ (មេមិនធើម) នាំឱ្យពួកវាខាំគ្នាធ្វើឱ្យស្រេ្តស
- អ្នកចិញ្ចឹមចូលទៅក្នុងទ្រុង ហើយធ្វើឱ្យជ្រូកភ្ញាក់ ឬស្រែកខ្លាំងធ្វើឱ្យស្រេ្តស ។



ពេលយកជ្រូកច្រើនដាក់ក្នុងទ្រុងជាមួយគ្នាធ្វើឱ្យមេជ្រូកខាំគ្នា = ស្រេ្តស

- ពិតណាស់ប្រសិនបើមាន**ចិញ្ចឹមបា** នោះវត្តមានរបស់បានឹងជួយជំរុញដល់ការរកឈ្មោល ដូចនេះមេជ្រូកកូនរួច ឬ មេក្រមុំត្រូវតែយកទៅដាក់នៅទ្រុងជិតបា ដើម្បីឱ្យបានទទួលក្លិនរបស់បា និងឱ្យវាហិតគ្នា ។



វត្តមានរបស់បាជួយជំរុញឱ្យមេមានអារម្មណ៍

**ខ- ពន្លឺ :** ពន្លឺមានសារៈសំខាន់ណាស់ក្នុងការជួយជំរុញឱ្យមេជ្រូកឆាប់រកឈ្មោល

- មេជ្រូកកូនរួច ឬ មេក្រមុំ ត្រូវការពន្លឺ ១៨ ម៉ោង
- ដាក់អំពូលភ្លើងក្នុងទ្រុង ហើយបិទនៅ ម៉ោង ១០ យប់ ។



បន្ថែមពន្លឺសិប្បនិម្មិត គឺជួយជំរុញឱ្យមេឆាប់រកឈ្មោល

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# រោគសញ្ញាជំងឺជ្រូក

ឧបត្ថម្ភដោយៈ

គម្រោងចិញ្ចឹមសត្វកម្ពុជា
សហគមន៍អឺរ៉ុប

សហគមន៍អឺរ៉ុប

អង្គការស្បៀង និងកសិកម្ម
នៃអង្គការសហប្រជាជាតិ

# មាតិកា

ទំព័រ


ជំពូក ១: ការធ្វើរោគវិនិច្ឆ័យទូទៅ.......... ០១

ជំពូក ២: ការធ្វើរោគវិនិច្ឆ័យលើស្បែក.......... ០៣

ជំពូក ៣: ការពិនិត្យលើភ្នែក.......... ១១

ជំពូក ៤: ការធ្វើរោគវិនិច្ឆ័យលើដុំពក.......... ១៧

ជំពូក ៥: ការពិនិត្យទ្វារធំ និងលាមក.......... ២១

ជំពូក ៦: ការពិនិត្យក្រសាល់គូថ.......... ២៩

ជំពូក ៧: ការពិនិត្យផ្លូវបន្ទពូជ និងទឹកនោម.......... ៣១

ជំពូក ៨: ដំបៅលើប្រដាប់បន្តពូជ.......... ៣៣

ជំពូក ៩: ទឹកនោមមានពណ៌ខុសធម្មតា.......... ៣៥

ជំពូក ១០: ពិនិត្យរោគវិនិច្ឆ័យកកន្ទ្រាមដោះ.......... ៣៧

ជំពូក ១១: ការពិនិត្យលើសកម្មភាពរបស់ជ្រូក.......... ៤១

ជំពូក ១២: ការពិនិត្យច្រមុះ និងការដកដង្ហើម.......... ៤៧

ជំពូក ១៣: ការធ្វើរោគវិនិច្ឆ័យជំងឺប្រព័ន្ធសរសៃប្រសាទ.......... ៥១

ជំពូក ១៤: ការពិនិត្យសត្វ ដែលបង្ហាញសញ្ញាមិនស៊ីចំណី.......... ៥៧

តារាង: តារាងកម្មវិធីវ៉ាក់សាំងដែលត្រូវអនុវត្ត.......... ៤២

# ជំពូក ១ ការធ្វើរោគវិនិច្ឆ័យទូទៅ

## I. រោគសញ្ញាជំងឺជាអ្វី?

- រោគសញ្ញា គឺជាសញ្ញាសំគាល់មិនប្រក្រតីទាំងឡាយ ដែលលេចចេញ និងកើតឡើង លើខ្លួនសត្វក្នុងពេលសត្វមានជំងឺ ។ យើងអាចសំគាល់ រោគសញ្ញាបានតាមរយៈ
  - វិញ្ញាណទាំង៥ របស់យើង (ឃើញ ឮ ធំក្លិន ក្តៅ ត្រជាក់ ទន់ រឹង...)
  - បច្ចេកទេសពិនិត្យ (ប៉ះ ស្ទាប វាស់កំដៅ ដេញអោយដើរ...)
- ពេលភ្នាក់ងារសុខភាពសត្វភូមិ បានស្គាល់ច្បាស់រោគសញ្ញា គាត់អាចកំណត់ជំងឺ និងគ្រប់គ្រងបញ្ហាបាន ។
- សៀវភៅខ្នាតតូចនេះ បង្ហាញយ៉ាងសាមញ្ញនូវរោគសញ្ញា ដែលងាយស្រួលសង្កេត និង ផ្តល់ចំណុចសំខាន់ៗសម្រាប់កំណត់ឈ្មោះជំងឺ ។

**ដើម្បីស្គាល់រោគសញ្ញាភ្នាក់ងារសុខភាពសត្វភូមិត្រូវពិនិត្យសត្វឱ្យបានច្បាស់លាស់**

## II. បច្ចេកទេសពិនិត្យជ្រូក



*រូបភាពទី ១.១: ភ្នាក់ងារសុខភាពសត្វភូមិ ចូលក្នុងទ្រូង ដើម្បីសង្កេតជ្រូក*

### យើងចាំបាច់:

- ត្រូវចូលឱ្យជិតជ្រូក ។
- ត្រូវសង្កេតការក្រោក និងបម្លាស់ទីរបស់ជ្រូក ។



*រូបភាពទី ១.២: ភ្នាក់ងារសុខភាពសត្វភូមិ ស្ទាបជ្រូកដើម្បីពិនិត្យឲ្យបានត្រឹមត្រូវ*

* ត្រូវសង្កេតសញ្ញាផ្សេងៗ ពីច្រមុះដល់កន្ទុយ ។
* ត្រូវស្ទាបលើដងខ្លួន។
* គួរហែកមាត់ជ្រូកពិនិត្យ ។

**ចាំបាច់បំផុត:**

* ត្រូវមានសីតុណ្ហមាត្រ (ទែម៉ូម៉ែត្រ) សម្រាប់វាស់កម្តៅជ្រូក ។ ការវាស់កម្តៅ ត្រូវធ្វើឡើងនៅពេលព្រឹក ។
* ជ្រូកក្តៅខ្លាំងនៅពេលព្រឹក មានន័យថាជ្រូក មានជំងឺ ។
* សង្កេតមើលចង្វាក់ដង្ហើមជ្រូក ។



*រូបភាពទី ១.៣: ភ្នាក់ងារសុខភាពសត្វភូមិ វាស់កម្តៅជ្រូក*

## III. ការសាកសួរម្ចាស់ជ្រូក

ជាការពិត រាល់ព័ត៌មានសំខាន់ៗមួយចំនួនដែល ទាក់ទងនឹងជ្រូក គឺត្រូវផ្តល់ដោយកសិករ ព្រោះគាត់ជាអ្នកថែទាំរៀងរាល់ថ្ងៃ ។ សំណួរដែលគួរសួរទៅកសិករមាន:

* តើជ្រូកស៊ីចំណីឬទេ? ព្រោះបើជ្រូកឈប់ស៊ី វាជាបញ្ហាធ្ងន់ធ្ងរ និងត្រូវប្រញាប់វាស់កម្តៅជាបន្ទាន់ (គ្រុនក្តៅ=មានការចម្លងរោគ)
* តើជ្រូកចេញរោគសញ្ញានៅពេលណា? ដើម្បីដឹងថា វាជាជំងឺស្រួចស្រាវ ឬមិនសូវស្រួចស្រាវ ។
* តើមានជ្រូកធំ ឬកូនជ្រូកឈឺប៉ុន្មានក្បាល? ដើម្បីដឹងថាវាជាជំងឺឆ្លង ឬអត់ ។
* តើបានប្រើថ្នាំអ្វីហើយឬនៅ? ដើម្បីដឹងថា គាត់ព្យាបាលហើយ ឬមិនទាន់ និងឱ្យយើងប្រយ័ត្នប្រយែង ក្នុងការជ្រើសរើសថ្នាំមកប្រើ ។



*រូបភាពទី ១.៤: ភ្នាក់ងារសុខភាពសត្វភូមិ សាកសួរព័ត៌មានពីកសិករ*

# ជំពូក ២ ការធ្វើរោគវិនិច្ឆ័យលើស្បែក

ជំងឺ និងបញ្ហាមួយចំនួនអាចធ្វើឱ្យស្បែកផ្លាស់ប្តូរសណ្ឋានៈ

- ចំពោះពណ៌ៈ ក្រហម ស្វាយ ខ្មៅ...
- ចំពោះការស្ទាបៈ ក្តៅ មានជាតិខ្លាញ់រងើម កន្លែងប៉ោងខុសធម្មតា...
- ចំពោះស្លាកស្នាមៈ ក្រមំ ស្លាកស្នាម ខ្ទុះ...
- ចំពោះបរាសិតៈ ដង្កែ រុយ...

## I. ខ្លាញ់រងើមលើស្បែក

### ក. មូលហេតុ

ស្តាហ្វីឡូកុកកូស ជាបាក់តេរី ហើយវារាតត្បាត ធ្វើឱ្យរលាត់ស្បែក និងបង្កឱ្យមានការឆ្លងជំងឺ ។

### ខ. រោគសញ្ញា

- ដំបូងចំណុចតូចពណ៌ត្នោតចាស់ ចាប់ផ្តើមចេញ ពីផ្នែកជុំវិញមុខ ឬជើង ។
- កន្លែងដែលមានខ្លាញ់រងើមមានសភាពកខ្វក់ ។
- បន្ទាប់មកប្រែទៅជាពណ៌ត្នោត ហើយរាល ដាលបន្តិចម្តងៗ រហូតដល់ពេញខ្លួនទាំងមូល ។
- ការរាតត្បាតធ្ងន់ធ្ងរអាចធ្វើឱ្យកូនជ្រូកងាប់បាន ។



រូបភាពទី ២.១: កូនជ្រូកមានជំងឺរលាកស្បែក



រូបភាពទី ២.២: កូនជ្រូកមួយចំនួនក្នុងសំបុកឆ្លងជំងឺរលាកស្បែក

គ. ការពារ

- ជៀសវាងកម្រាលទ្រុងសើម ។ កម្រាលមិនល្អនាំឱ្យដំបៅជង្គង់ជ្រូក ។
- កាត់ធ្មេញកូនជ្រូកឱ្យល្អ ដើម្បីបង្ការការខាំក្បាលដោះ ។
- លាងសំអាតដោះមេជ្រូក២ដងក្នុងមួយថ្ងៃ ជាមួយទឹកអ៊ីយ៉ូឌីន ព្រោះកន្ទ្រាមដោះ ជាកន្លែងផ្ទុកមេរោគ និងបណ្តាលអោយមានការឆ្លងរាលដាលជំងឺ ។

ឃ. ព្យាបាល

គ្មានប្រសិទ្ធភាព ប៉ុន្តែអាចប្រើថ្នាំខាងក្រោមនេះដើម្បីឱ្យស្ថានភាពសត្វប្រសើរជាងមុន ។

- អាម៉ុកស៊ីស៊ីលីន អិលអា (Amoxicillin LA) ឬឡាំងកូមីស៊ីន (Lincomycin) ។
- បាញ់ថ្នាំសម្លាប់មេរោគលើស្បែក ធីអេច៤ (TH4) ១០-២០ ម.ល លាយជាមួយទឹក ១លីត្រ) ។

## II. ផ្ទាំងក្រហមលើស្បែក

### ១. បង្កឡើងដោយជំងឺកញ្ជ្រិល

វាបង្កឡើងដោយបាក់តេរី និងមានស្ទើរគ្រប់កសិដ្ឋាន ។ ជំងឺនេះ មិនសូវកើតមានចំពោះកូនជ្រូកអាយុតិចជាងបីខែទេ ។

ក. រោគសញ្ញា

- ផ្ទាំងពណ៌ក្រហមធំៗនៅលើស្បែកប្រែទៅជាខ្មៅ ។
- ជ្រូកងាប់យ៉ាងទាន់ហន់ (បើស្រួចស្រាវ) ។
- កម្តៅឡើងខ្លាំង (៤១ អង្សាសេ) ហើយវាមិនស៊ីចំណី ។



រូបភាពទី ២.៣: ស្បែកជ្រូកកើតជំងឺកញ្ជ្រិល

ខ. ការពារ

អាចចាក់ថ្នាំបង្ការជ្រូក នៅអាយុ ៤ខែ (ចាក់រុយវ៉ាក់របស់ក្រុមហ៊ុនមេរីយ៉ាល់ ពីរដងក្នុងចន្លោះ ៤អាទិត្យ)។

គ. ព្យាបាល

ចាក់ប៉េនីស៊ីលីន (Penicillin) ឬអាម៉ុកស៊ីស៊ីលីន (Amoxicillin) ចំនួន ៣ ទៅ ៥ថ្ងៃ។

## ២. បង្កឡើងដោយសារអង្កែ

វាបង្កឡើងដោយបរាសិត ដែលបណ្តាលឱ្យសត្វលូតលាស់យឺត។

ក. រោគសញ្ញា

- មានចំណុចក្រហមៗ ជាច្រើននៅលើស្បែក ដែលសំខាន់នៅត្រង់ខ្នង និងពោះ។
- ជ្រូកនៅមិនសុខ និងត្រដុសខ្នងជាញឹកញាប់។
- បក់ត្រចៀកចុះឡើង។

ខ. ការពារ

ចាក់ការពារជ្រូក រាល់៣ខែម្តង ជាមួយអ៊ីវ៉ូម៉ិចទីន (Ivomectin)។

គ. ព្យាបាល

ចាក់អ៊ីវ៉ូម៉ិចទីន (Ivomectin) ២ដង ក្នុងកម្រិត ១ ម.ល ក្នុង ៣០ គ.ក្រ ជ្រូករស់ ដោយដាក់លើកទី២ នៅ ២អាទិត្យ ក្រោយពីដាក់លើកទី១ ព្រោះវដ្តជីវិតបរាសិតគឺ ១០ ទៅ ១៤ ថ្ងៃ។



*រូបភាពទី ២.៤: ជ្រូកកើតអង្កែនៅលើស្បែក*



*រូបភាពទី ២.៥: ជ្រូកកើតអង្កែនៅលើត្រចៀក*

## ៣. បង្កឡើងដោយរុយ ឬមូស

វដ្ដជីវិតរបស់រុយគឺ ១ ទៅ ២ អាទិត្យ ហើយរុយញីអាចពងបាន៤០០ពង។ ពួកវាចូលចិត្តកន្លែងសើម។

### ក. រោគសញ្ញា

- មានស្នាមអុចក្រហមៗ និងរលាត់តិចៗលើ ស្បែក។
- មានការបាត់បង់ឈាម និងជ្រូកលូតលាស់តិចតួច។

### ខ. ការពារ

- បំបាត់ជម្រករុយ ឬមូស។
- បំបាត់ (លាងសំអាត) ក្រម៉ដែលរុយពងដាក់បំពេញក្រលុកក្នុងទ្រុងនិងសំអាតរបស់ដែល ប្រឡាក់ប្រឡូក នៅតាមជញ្ជាំងព្រោះកន្លែងទាំងនេះវាទាក់ទាញរុយ ឬមូស ឱ្យមកពងណាស់។



*រូបភាពទី ២.៦:*
*ជ្រូកមានចំណុចក្រហមលើស្បែក*

### គ. ព្យាបាល

- ប្រើថ្នាំបាញ់សម្លាប់សត្វល្អិត (ទ្រិកលរ័ហ្វុង) លើជម្រករុយ ឬមូស។
- បាញ់ថ្នាំប៊ុយតុក (Butox) លើខ្លួនសត្វរៀងរាល់ ២ខែម្ដង។
- ចាក់ថ្នាំដិចសាមេតាសូន (Dexamethosone) បើស្បែករលាត់ខ្លាំង។

ស្បែកប្រែជាក្រហម

## ៤. ក្រហមដោយកម្ដៅថ្ងៃ

### ក. រោគសញ្ញា

- ស្បែកក្រហម
- ស្បែករលាក ហើយសើម។
- ជ្រូកបង្ហាញការឈឺចាប់ និងនៅមិនសុខ។



*រូបភាពទី ២.៧:*
*ស្បែកជ្រូកក្រហមដោយកម្ដៅថ្ងៃ*

ខ. ការពារ

- ត្រូវមានម្លប់នៅក្នុងទ្រុង។

គ. ព្យាបាល

- ត្រូវបាញ់ទឹកលើជ្រូក ដើម្បីបន្ថយកម្តៅ។
- ត្រូវមានទឹកគ្រប់គ្រាន់សម្រាប់ជ្រូកផឹក។
- ចាក់ថ្នាំប៉ារ៉ាសេតាម៉ុល (Paracetamol) ដើម្បីបញ្ចុះកម្តៅជ្រូក និងបន្ថយការរលាក។

ស្បែកឡើងអុចពណ៌ស្វាយ

## ៥. បង្កឡើងដោយជំងឺប៉េស្ត

ក. រោគសញ្ញា



- មានលេចឡើងជាំគ្រាប់ឈាមអុចៗលើស្បែក ហើយស្បែកប្រែជាពណ៌ស្វាយដែលដំបូង ត្រង់ត្រចៀក និងកន្ទុយ រួចរាលដាលទៅច្រមុះ ជើង ពោះ និងខ្នង។
- ក្តៅខ្លាំងលើសពី ៤០ អង្សាសេ ចំនួន ២ ទៅ ៣ថ្ងៃ។
- លាមករាកពណ៌លឿងប្រផេះ និងមានក្លិនស្អុយ ឆ្អាប។
- ដំណើរទ្រេតទ្រោត ច្រើនអង្គុយចុះនៅមិននឹង។



*រូបភាពទី ២.៨: ជ្រូកកើតជំងឺប៉េស្ត*

ខ. ព្យាបាល

គ្មានការព្យាបាលទេ ប៉ុន្តែៈ

- ចាក់អង់ទីប៊ីយ៉ូទិក (ស៊ុលហ្វា ជាមួយទ្រីមេតូព្រីម (Sulfa TMP) ឬអង់រ៉ូផ្លកសាក់ស៊ីន (Enrofloxacine) អាចបង្ការការវាយលុករបស់ជំងឺឱកាសនិយម ដូចជាបាស៊ីរ៉ែលឡា សាល់ម៉ូណែលឡា។
- ប្រើប្រាស់ថ្នាំដូចជាការ៉ាស៊ីល(Carasil) ឬអេម៉ាតូប៉ង់(Hematopan) ដើម្បីជំរុញឱ្យប្រព័ន្ធការពារសត្វបានប្រសើរអាចធ្វើឱ្យជ្រូកជាបាន។

គ. ការពារ

- ចាក់វ៉ាក់សាំងកូនជ្រូកនៅអាយុ ៣អាទិត្យ ៧ អាទិត្យ និង ១១អាទិត្យ។
- ចាក់វ៉ាក់សាំងជ្រូកក្រមុំ មេជ្រូក និងបា រៀងរាល់ ៦ខែម្តង។
- ប្រុងប្រយ័ត្នចំពោះវ៉ាក់សាំងៈ
  - ការជ្រើសរើសៈ វ៉ាក់សាំងមួយចំនួនមានប្រសិទ្ធភាពដូចជា (ប៉េស្តវ៉ាក់ ឬ កូឡាប៉េស្ត ឬ ស៊ី អេស អេហ្វ របស់អាំងទែវេត)។
  - ការថែរក្សាៈ ត្រូវដាក់ឱ្យបានត្រឹមត្រូវនៅកន្លែងត្រជាក់។ ត្រូវប្រើឱ្យអស់ តែក្នុងអំឡុងពេល ១ម៉ោងបន្ទាប់ពីលាយជាមួយទឹករួច។ វ៉ាក់សាំងដែលសល់មិនអាចរក្សាទុកបានទេ។
  - បច្ចេកទេសចាក់ៈ ចាក់នៅសាច់ដុំជាមួយម្ជុលត្រឹមត្រូវ (ចំពោះមេជ្រូក ម្ជុលប្រវែង ៤០-៥០ ម.ល)។

ស្បែកឡើងពណ៌ខៀវ

## ៦. បង្កឡើងដោយជំងឺសាល់ម៉ូណែលឡូស៊ីស

បាក់តេរីសាល់ម៉ូណែលឡា ចម្លងរាលដាលលើមនុស្ស និងសត្វ។ បាក់តេរីសាល់ម៉ូណែលឡាមួយចំនួន អាចធ្វើឱ្យជ្រូកឈឺ។ ការចម្លងខ្លាំងក្លារបស់បាក់តេរីសាល់ម៉ូណែលឡាកូលេរ៉ាស៊ូ កើតមានចំពោះជ្រូកអាយុ ១២-១៤អាទិត្យ។

ក. រោគសញ្ញា



រូបភាពទី ២.៩: ត្រចៀកកូនជ្រូកឡើងពណ៌ខៀវ

- ស្បែកចុងត្រចៀក កន្ទុយ ច្រមុះ និងជើង ប្រែជាពណ៌ខៀវ ។
- គ្រុនក្តៅខ្លាំងលើសពី ៤០អង្សាសេ ។
- រលាកសួត និងឈឺចាប់លើផ្លូវដង្ហើម ។
- លាមករាកមានក្លិនស្អុយខ្លាំងខុសពីធម្មតា ។
- កើតលើជ្រូកអាយុតិចជាង ៦ខែ ។

## ខ. ការពារ

- អនុវត្តអនាម័យឱ្យបានល្អដោយសម្លាប់មេរោគ ។
- បើមានជំងឺនេះកើតមាន ទឹកដែលដាក់ឱ្យជ្រូកផឹកក្នុងទ្រុងត្រូវមានអនាម័យល្អ ។
- ការចាក់ថ្នាំបង្ការមិនមានប្រយោជន៍ទេចំពោះជំងឺនេះ ។

## គ. ព្យាបាល

ចាក់ថ្នាំអង់រ៉ូផ្លុកសាក់ស៊ីន (Enrofloxacine) ។

# ៧. បង្កឡើងដោយជំងឺត្រចៀកខៀវ

**(Porcine Respiratory and Reproductive Syndrome, PRRS)**

## ក. រោគសញ្ញាលើមេជ្រូក

- ត្រចៀកមាន ពណ៌ខៀវ ។
- មិនសូវស៊ីចំណី ១ ទៅ ២អាទិត្យ ។ បន្ទាប់មក មេជ្រូកឈប់ស៊ីចំណីហើយស្រកទម្ងន់ ។
- រលូត (ខុសគ្នាពីជំងឺសាល់ម៉ូណេឡា) ចំពោះមេធំ ។



រូបភាពទី ២.១០: កូនជ្រូកកើតជំងឺត្រចៀកខៀវ

## ខ. រោគសញ្ញាលើកូនជ្រូក

- ក្អកតិចៗ ។
- ត្រចៀកពណ៌ខៀវ
- កូនជ្រូកស្គម និងមានរោមច្រើន

▪ ២០% នឹងងាប់បន្ទាប់ពីជួបបញ្ហាដូចនេះ។

គ. ព្យាបាល

▪ ចាក់ថ្នាំផ្លរហ្វេនីកុល (Florfenicol) សម្រាប់កូនជ្រូក៣អាទិត្យបន្ទាប់ពីផ្តាច់ដោះ។

▪ លាយអុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) សម្រាប់មេជ្រូកស៊ីរយៈពេល ៣អាទិត្យ។

ឃ. ការពារ

បង្ខាំងជ្រូកដែលទិញថ្មីរយៈពេល ៦ អាទិត្យនៅទ្រុងផ្សេងកុំឱ្យមានការប៉ះពាល់ជាមួយជ្រូកដទៃទៀត។

## III. បរាសិតខាងក្រៅ

### ១. ដង្កែ ចៃ មូស និងរុយ

យើងអាចមើលឃើញលើស្បែក

ក. រោគសញ្ញា

▪ មានរលាត់នៅលើស្បែក។

▪ សត្វមានរោមស្រអាប់ ប៉ះហើយត្រដុសនៅមិនស្ងៀម។

▪ បាត់បង់ឈាម និងធំធាត់យឺត។

▪ ខ្លះទៀតអាចចម្លងជំងឺផ្សេងៗ (រុយចម្លងជំងឺអឹកូលីជាដើម)។



*រូបភាពទី ២.១១: មេជ្រូករុកគួនដោយរុយ*

ខ. ព្យាបាល

▪ ចាក់ថ្នាំដិចសាមេតាសូន (Dexamethasone) (មិនត្រូវចាក់លើមេធើម) ដើម្បីបន្ថយការឈឺចាប់ដោយរលាត់ និងភាពក្រហល់ក្រហាយ។

▪ បំបាត់ជម្រកសត្វល្អិត និងសំអាតកន្លែងកខ្វក់។

▪ បាញ់ថ្នាំសម្លាប់មេរោគលើខ្លួនសត្វដូចជា ប៊ុយតុក (Butox)...។

▪ ចំពោះចៃ និងដង្កែត្រូវចាក់ថ្នាំអ៊ីវ៉ូម៉ិចទីនតាមក្រោមស្បែក។ ថ្នាំអ៊ីវ៉ូម៉ិចទីន១% សម្រាប់ ៣០ គ.ក្រ ទម្ងន់ជ្រូករស់។

# ជំពូក ៣ ការពិនិត្យលើភ្នែក

គេត្រូវពិនិត្យ២ដំណាក់កាលជាប្រចាំ

**ផ្នែកខាងក្រៅរបស់ភ្នែក៖**

- ហើមភ្នាសខាងក្នុង។
- បិទភ្នែក ដោយសារមានការឈឺចាប់។
- ការហូរទឹករងៃ ដោយសារមានការរាតត្បាតរបស់បាក់តេរី ត្រូវប្រើថ្នាំបន្តក់ឈ្មោះ ក្លរ៉ង់ហ្វេនីកុល ៣ដង ក្នុងមួយថ្ងៃ។

**ជាលិកាក្នុងត្របកភ្នែក៖**

- ជាលិកាត្របកភ្នែក៖ ក្រហម ពិបាកបើកភ្នែក។
- ពណ៌ខុសធម្មតា៖ លឿង ស ឬក្រហម។
- ការហូរចេញមកក្រៅ៖ ឈាម ឬខ្ទុះ។



*រូបភាពទី ៣.១: ភ្នែកជ្រូកមានសភាពធម្មតា*



*រូបភាពទី ៣.២: ភ្នែកជ្រូកមានសភាពមិនធម្មតា*

## I. ហើមត្របកភ្នែក

បង្កឡើងដោយអ៊ីកូលី

### ក. រោគសញ្ញា



*រូបភាពទី ៣.៣: កូនជ្រូកកើតជំងឺហើមត្របកភ្នែក*

- កើតចំពោះកូនជ្រូកបន្ទាប់ពីផ្តាច់ដោះបាន ពី១ ទៅ៤អាទិត្យ ។
- ភ្នែកក្រហមៈ (រលាកជុំវិញបរិវេណភ្នែក) ដោយមានហូរទឹកមកជាមួយហើយមិនយូរប៉ុន្មានត្របកភ្នែកនឹងបិទជិត ហើយស្អិត ។
- កម្តៅស្មើរតែធម្មតា ៣៩ អង្សាសេ ។
- ដើរទ្រេតទ្រោត ។
- ជ្រូកភាគច្រើននឹងងាប់ ។

### ខ. ព្យាបាល

មានការលំបាក ដោយសារមានរបួសខួរក្បាល (ហើមនៅក្នុងខួរផងដែរ) ។

- ចាក់អង់ទីប៊ីយ៉ូទិក អង់រ៉ូផ្លុកសាក់ស៊ីន ជាមួយស៊ុលហ្វាទ្រីមេតូព្រីម (Enrofloxacine + Sulfa TMP) ដើម្បីទប់ទល់ការរាតត្បាតផ្លូវដង្ហើម ។
- បន្ថយកម្តៅត្រូវចាក់ថ្នាំដូចជាៈ ប៉ារ៉ាសេតាម៉ុល (Paracetamol) ឬកាល់ម៉ាស៊ីន (Calmgine) ឬអាណាហ្សាំង (Alnagine) ។

### គ. ការពារ

- ផ្តល់ចំណីដែលមានប្រូតេអ៊ីនត្រឹម១៨ % បានហើយ ។
- ប្រើក្លរីន សម្រាប់សំអាតទឹកជ្រូកផឹក ។
- អនាម័យទ្រុងឱ្យបានស្អាតល្អ ។

## II. ជាលិកាត្របកភ្នែកមានភាពមិនប្រក្រតី

### ១. ជាលិកាត្របកភ្នែកមានពណ៌ក្រហមៈ ជំងឺប៉េស្ត

ជាលិកាកែវភ្នែកមានពណ៌ក្រហម អាចបណ្តាលមកពីការឆ្លងជំងឺផ្សេងៗ ប៉ុន្តែនៅកម្ពុជាយើងគេសង្កេតឃើញថា ភាគច្រើនកើតឡើងដោយសារជំងឺប៉េស្ត ។

## ក. រោគសញ្ញា

- រលាកជាលិកាកែវភ្នែក (រលាកនៅបរិវេណភ្នែក) ហើមត្របកភ្នែក ដោយមានហូរទឹកភ្នែក និងមានពពឹកភ្នែក ។
- បន្តមកទៀតត្របកភ្នែកបិទទាំងស្រុង ហើយជាប់ស្អិត ។
- សីតុណ្ហភាពលើសពី ៤១ អង្សាសេ ។
- ជាំឈាមក្រោមស្បែក ។
- ដើរព័ន្ធដើង ។



*រូបភាពទី ៣.៤: ជ្រូករលាកជាលិកាកែវភ្នែកដោយជំងឺប៉េស្ត*

## ខ. ព្យាបាល

មិនអាចព្យាបាលបានទេជំងឺប៉េស្ត ព្រោះវាបង្កឡើងដោយវីរុស ។

- ជាទូទៅ គេប្រើអង់ទីប៊ីយ៉ូទិកប្រឆាំងនឹងជំងឺផ្លូវដង្ហើម ដូចជាតេត្រាស៊ីគ្លីន (Tetracycline) ។
- បញ្ចុះកម្តៅដោយប្រើថ្នាំដូចជាៈ ប៉ារ៉ាសេតាម៉ុល (Paracetamol) ឬកាល់ម៉ាស៊ីន (Calmagine) ឬអាណាស៊ីន (Alnagine) ។
- ប្រើ ការ៉ាស៊ីល (Carasil) ឬប៊ីយ៉ូឌីល (Biodil) ដើម្បីជំរុញឱ្យប្រព័ន្ធការពារសត្វបានប្រសើរ ។

## ២. ជាលិកាត្របកភ្នែកមានពណ៌ស្លេកស្លាំង ដោយជំងឺខ្វះឈាម

### ក. រោគសញ្ញា



*រូបភាពទី ៣.៥: កូនជ្រូកស្លេកស្លាំង*

- ភ្នាសស្តើងក្នុងត្របកភ្នែកមានពណ៌ស ដែលជាធម្មតាមានពណ៌ ផ្កាឈូក ។
- ជ្រូកស្លេកស្លាំង ហើយអាចងាប់ដោយការដក ដង្ហើមមិនបានគ្រប់គ្រាន់ ។

### ខ. មូលហេតុ និងការពារ

- ខ្វះជាតិដែកឬទង់ដែង ចំពោះកូនជ្រូក កំពុងបៅដោះ ដោយសារមិនបានផ្តល់ជាតិ ទាំងនេះដល់វា និងមេជ្រូកខ្វះទឹកដោះ ។
- ចាក់ ១ ម.ល ជាតិដែកសម្រាប់កូនជ្រូកអាយុ២ថ្ងៃ និងចាក់រំលឹកនៅអាយុ១០ថ្ងៃ ដើម្បីជៀសវាងការស្លេកស្លាំង ។

### គ. ព្យាបាល

- សម្រាប់សត្វជ្រូកធំ គឺដំបៅក្រពះ: ផ្តល់ចំណីឱ្យបានត្រឹមត្រូវរួមមានបន្លែបៃតង និងចាក់វីតាមីនបេ ១២ (Vitamin B12) ។
- សារធាតុចិញ្ចឹមរាងកាយមិនគ្រប់គ្រាន់សម្រាប់ជ្រូកស៊ីតាមវាល ។ ចាក់ស្ត្រេសវីត (Stressvit) ។
- មានព្រូនៈ ចាក់អ៊ីវ៉ូម៉ិចទីន (Ivomectin) ។

## ៣. ជំងឺដែលធ្វើឱ្យជាលិកាត្របកភ្នែកមានពណ៌លឿង

បញ្ហានេះសំខាន់បណ្តាលមកពីភាពមិនប្រក្រតីរបស់ថ្លើម ដែលធ្វើឱ្យជាលិកាត្របកភ្នែក និងស្បែកឡើងពណ៌លឿង ។

- ជំងឺឡិបតូស្ពៀរ៉ូកើតចំពោះកូនជ្រូក (អាយុតិចជាង ៣ខែ): ចម្លងតាមរយៈទឹកនោមកណ្តុរ ។ ព្យាបាលៈ ត្រូវប្រើអង់ទីប៊ីយ៉ូទិកដូចជា ប៊ង់ស្ត្រិប (Beastrep) ។

- ចំពោះកូនជ្រូក និងមេជ្រូក អាចបណ្ដាលឱ្យខូចថ្លើមផ្ចាល់ដែលបង្កដោយអាល់ហ្វាតុកស៊ីនក្នុងគ្រាប់ពោត។ អាល់ហ្វាតុកស៊ីនកើតឡើងដោយផ្សិត ដែលមានក្នុងពោត ដូចនេះត្រូវផ្លាស់ប្តូរពោតនោះចេញ។
- សាល់ម៉ូណែលឡា: ធ្វើឱ្យខូចដល់ថ្លើមដែលនាំឱ្យ កើតជំងឺលឿង (សូមមើល ជំងឺរាក នៅទំព័រទី៣៤ ចំនុចទី៥)។



*រូបភាពទី ៣.៦: ជ្រូកកើតខាន់លឿង*

# ជំពូក ៤ ការធ្វើរោគវិនិច្ឆ័យលើដុំពក

## I. បូស (អាប់សែ)

ជាថង់ខ្ទុះ កើតបន្ទាប់ពីមានសកម្មភាពរបស់បាក់តេរី ។

### ក. រោគសញ្ញា

- ខ្ទុះនៅក្នុងបូស មានបាក់តេរីយ៉ាងច្រើន ។
- ដំបូងហើមតូច រួចរីកទៅជាធំ ។
- ដំបូងមានសភាពរឹង ហើយ១អាទិត្យក្រោយប្រែក្លាយ ទៅជាមានទឹក ឬខ្ទុះនៅខាងក្នុងដុំពក ។
- ស្បែកក្រហម អាចបណ្តាលទៅជាដំបៅរលួយ ។

### ខ. មូលហេតុ

- ការចាក់ថ្នាំមិនបានត្រឹមត្រូវៈ ម្ជុលមិនស្អាត ម្ជុលខ្លីពេក ចាក់ខុសបច្ចេកទេស របស់ផ្លូវបញ្ចូលឱសថ ។ល ។



*រូបភាពទី ៤.១: បូស ឬអាប់សែបន្ទាប់ពីការចាក់ថ្នាំ មិនបានត្រឹមត្រូវ*



*រូបភាពទី ៤.២: បូស ឬអាប់សែបន្ទាប់ពីការវះកាត់*

### គ. ព្យាបាល

- នៅពេលបូសមានសភាពទន់ត្រូវវះ ហើយយកខ្ទុះចេញរួចលាងសំអាតជាមួយទឹកអ៊ីយ៉ូឌីន។
- មិនចាំបាច់ ចាក់អង់ទីប៊ីយ៉ូទិកទេ។

## II. ហើមមានឈាមកក

គឺជាថង់ឈាម ដែលកើតមាននៅពេលដែលដាច់ ឬធ្លាយសរសៃឈាមរួចក្លាយជារបួស។

### ក. រោគសញ្ញា

- ជាទូទៅកើតលើស្មា ត្រចៀក និងប្រដាប់បន្តពូជ។

### ខ. មូលហេតុ

- ការខាំគ្នា។
- អង្គែ នាំឱ្យមានការត្រដុសត្រចៀក ឬស្មាខ្លាំងៗ។
- របួសអំឡុងពេលកើតកូន ចំពោះប្រដាប់បន្តពូជ។



រូបភាពទី ៤.៣: ដុំពកកើតបន្ទាប់ពីជ្រូកត្រដុសត្រចៀក



រូបភាពទី ៤.៤: ដុំពកកើតនៅ ២អាទិត្យបន្ទាប់ពីត្រដុសត្រចៀកជ្រូក

### គ ព្យាបាល

- គ្មានការព្យាបាលទេ ហើយកុំធ្វើការវះឱ្យសោះ។

### III. ក្លូន ឬអ៊ែកនី (នៅផ្ចៃពងស្វាស ឬពោះ)

កើតដោយការដាច់សន្ទះផ្ចិត ឬពងស្វាស ដែលធ្វើឱ្យពោះវៀនធ្លាក់ចេញមកក្រៅពោះ ឬចូលទៅក្នុងក្រសោមពងស្វាស ។

#### ក. រោគសញ្ញា

- ហើមទំហំពី កន្លះ ទៅ ២តឹក លយចេញពីផ្ចិត និងពោះ ឬពីមុខពងស្វាស ។



ធ្លាក់ពោះវៀនក្នុងក្រសោមពងស្វាស

#### ខ. ផលប៉ះពាល់

- ធ្វើឱ្យសត្វធំធាត់យឺត ហើយជ្រូកមិនអាចធំ ដល់ ៩០ គ.ក្រទេ ។



ធ្លាក់ពោះវៀនចេញមកក្រៅពោះ

រូបភាពទី ៤.៩ ក្លូន ឬអ៊ែនទី

#### គ. ព្យាបាល

- គ្មានការព្យាបាលទេ និងកុំវះកាត់ ។

#### ឃ. ការពារ

- ចាក់ថ្នាំអាម៉ុក អិលអេ (Amoxicillin LA) លើកូនជ្រូកអាយុ ១ថ្ងៃ ដើម្បីកុំឱ្យមេរោគឆ្លងតាមទងផ្ចិត ។

**កុំក្រៀវចំពោះជ្រូក ដែលធ្លាក់ពោះវៀនក្នុងពងស្វាស។**

## III. ក្លូន ឬអែកនី (នៅផ្នែកពងស្វាស ឬពោះ)

កើតដោយការដាច់សន្ទះផ្ចិត ឬពងស្វាស ដែលធ្វើឱ្យពោះវៀនធ្លាក់ចេញមកក្រៅពោះ ឬចូលទៅក្នុងក្រសោមពងស្វាស។

### ក. រោគសញ្ញា

- ហើមទំហំពី កន្លះ ទៅ ២តឹក លយចេញពីផ្ចិត និងពោះ ឬពីមុខពងស្វាស។



*ធ្លាក់ពោះវៀនក្នុងក្រសោមពងស្វាស*

### ខ. ផលប៉ះពាល់

- ធ្វើឱ្យសត្វធំធាត់យឺត ហើយជ្រូកមិនអាចធំដល់ ៩០ គ.ក្រទេ។



*ធ្លាក់ពោះវៀនចេញមកក្រៅពោះ*

*រូបភាពទី ៤.៥ ក្លូន ឬអ៊ែននី*

### គ. ព្យាបាល

- គ្មានការព្យាបាលទេ និងកុំវះកាត់។

### ឃ. ការពារ

- ចាក់ថ្នាំអាម៉ុក អិលអេ (Amoxicillin LA) លើកូនជ្រូកអាយុ ១ថ្ងៃ ដើម្បីកុំឱ្យមេរោគឆ្លងតាមទងផ្ចិត។

**កុំគ្រៀវចំពោះជ្រូក ដែលធ្លាក់ពោះវៀនក្នុងពងស្វាស។**

# ជំពូក ៥ ការពិនិត្យលើទ្វារធំ និងលាមក

## ពេលពិនិត្យលាមក យើងនឹងឃើញ

ភាក

- ពណ៌: លឿង ប្រផេះ បៃតង ។ល ។
- ទិដ្ឋភាព (សភាព): រាវដូចទឹក ខាប់ដូចក្រែម ។ល ។
- សមាសធាតុ: សំបោរ ឈាម ។ល ។

ក្អៀន

ព្រូន

## I. ជំងឺភាក

### រោគសញ្ញាទូទៅ

### នៅពេលចាប់ផ្តើម

- ជាទូទៅយើងឃើញជ្រូកងាប់យ៉ាងរហ័សដោយមិនបង្ហាញរោគសញ្ញាភាកឡើយ ។
- ជ្រូកដេកញាក់ផ្តុំគ្នាមួយកន្លែង ឬដេកនៅជ្រុងមួយនៃទ្រុង ។
- នៅគូទ និងកន្ទុយមានសភាពសើម និងកខ្វក់ ។
- អាចឃើញទ្រុងប្រលាក់ប្រឡូកទៅដោយលាមក ដែលមានសភាពរាវដូចទឹកសំបោរ និងមានក្លិនស្អុយ ។

### ការវិវត្តរបស់ជំងឺភាក

- ខ្សោះជាតិទឹកក្នុងខ្លួន ហើយចុះស្គមលឿន ។
- ភ្នែករូងខូង ។
- រោមច្រើន ហើយមានសភាពស្គមជ្រីវជ្រួញខុសធម្មតា ។

*ជំងឺភាកចែកជាប្រភេទផ្សេងៗពីគ្នា ចាប់តាំងពីកូនកើតរហូតដល់ពេញវ័យ*

## ១. អឺកូលី

កើតចំពោះកូនជ្រូក ទើបនឹងកើត ។

### ក. រោគសញ្ញា



*រូបភាពទី ៥.១: កូនជ្រូកទើបកើតមានជំងឺរាកដែលបង្កដោយអឺកូលី*

- កើតចំពោះកូនជ្រូកអាយុក្រោម ៥ថ្ងៃ ។
- លាមកពណ៌លឿង ដូចក្រែមលាយជាមួយសំបោរ ។
- លាមករាកមាននៅជាប់គូទ និងកន្ទុយ ។
- មិនយូរប៉ុន្មាន កូនជ្រូកនឹងខ្សោះជាតិទឹក ។

### ខ. ព្យាបាល

- ចាក់ថ្នាំដូចជា *កូលីស្ទីន* ជាមួយអំពីស៊ីលីន (អំពីដិច សាឡូន និង ប៊ីយ៉ូ *កូលីស្ទីន* Ampi Dexalone + Colistin) ឱ្យកូនជ្រូកទាំងអស់ នៅពេលព្រឹក និងល្ងាច ។
- សម្រាប់មេជ្រូកចាក់ទ្រីមេតូព្រីម ជាមួយស៊ុលហ្វា (Sulfa TMP) ព្រោះទឹកដោះមេជ្រូកមានមេរោគអឺកូលី ។

### គ. ការពារ

- ឱ្យកូនជ្រូកបៅទឹកដោះដំបូង ព្រោះវាមានអង់ទីគរ ដែលអាចឱ្យកូនជ្រូកទប់ទល់នឹងជំងឺអឺកូលីបាន ។
- កុំឱ្យកូនជ្រូករងារ និងត្រូវខ្យល់ខ្លាំង ព្រោះនៅពេលដែលពោះវៀនកូនជ្រូកត្រជាក់វាធ្វើឱ្យមេរោគអឺកូលីលូតលាស់លឿន ។ រៀបចំធ្វើសំបុក និងផ្តល់កម្តៅឱ្យកូនជ្រូកសម្រាប់ពេលយប់ ។

## ២. កុកស៊ីដ្យូស៊ីស

កើតចំពោះកូនជ្រូក អាយុ ៧ ទៅ ២១ថ្ងៃ ។

### ក. រោគសញ្ញា

- រាកប្រែពីលឿង ទៅជាប្រផេះ ឬបៃតង ។

▪ លាមកមានសភាពដូចក្រែម និងម៉ៅ្យ។

▪ កូនជ្រូកស្គមជ្រីវជ្រួញខុសពីធម្មតា។

ខ. ព្យាបាល

មានការពិបាក

▪ ស៊ុលហ្វា (សិបតូទ្រីល ស៊ុលហ្វា ៣៣) ។

គ. ការពារ

មានប្រសិទ្ធភាពណាស់

▪ បញ្ច្រកតុលត្រាស៊ុរីល (Toltrazuril) (អង់ទីកុក បៃកុក) ឱ្យកូនជ្រូកអាយុ ៣ថ្ងៃ។



*រូបភាពទី ៥.២: លក្ខណៈពិសេសរបស់កូនជ្រូករាគ ដែលបង្កដោយកុកស៊ីឌីយ៉ូស៊ីស*

## ៣. រាគឈាមចំពោះកូនជ្រូកបៅដោះ

បង្កដោយមេរោគក្លូស្រ្ទីឌីយ៉ូម ។

ក. រោគសញ្ញា

▪ កូនជ្រូករាគខ្លាំងមានក្លិនស្អុយ ដែលជាទូទៅមានលាយឈាម ។

▪ កើតមានចំពោះកូនជ្រូកអាយុពី ១ ទៅ ៧ថ្ងៃ បន្ទាប់ពីកើត។

▪ កូនជ្រូកងាប់ច្រើន។

▪ ជំងឺនេះ កើតឡើងតែចំពោះកូនជ្រូកដើររកស៊ីចំណីខ្លួនឯងនៅតាមវាលប៉ុណ្ណោះ ។



*រូបភាពទី ៥.៣: កូនជ្រូករាគ ដែលបង្កដោយក្លូស្ត្រីឌីយ៉ូម*

ខ. ព្យាបាល

▪ ចាក់អាម៉ុកស៊ីស៊ីលីន (Amoxicillin) យកល្អគួរច្រកតាមមាត់

ហើយត្រចៀកមានពណ៌ខៀវ ។

- ខាន់លឿង ព្រោះថ្លើមបានខូច ។

ខ. មូលហេតុ

- ពេលជ្រូកកើតជំងឺប៉េស្ត ហើយបន្ទាប់មកជាទូទៅវានឹងកើតជំងឺសាម៉ូណែលឡាតាមក្រោយ ។

គ. ព្យាបាល

មានការលំបាក

- ចាក់អង់រ៉ូផ្លុកសាក់ស៊ីន (Enrofloxacine) ។

ឃ. ការពារ

មានការលំបាក

- មិនត្រូវចាក់វ៉ាក់សាំងទេ ។
- អនាម័យល្អ រំងាប់មេរោគ និងកំចាត់សត្វកណ្ដុរចោល ។

## ៦. ជ្រូកកំពុងលូតលាស់

រលាកពោះវៀន

ក. រោគសញ្ញា

- សភាពរ៉ាំរ៉ៃៈ លាមករាកសុទ្ធតែទឹក មានពណ៌ប្រផេះ ដែលធ្វើឱ្យការលូតលាស់យឺត ។
- សភាពស្រួចស្រាវៈ លាមករាកមានលាយឈាមដោយបង្កឱ្យជ្រូកមានសភាពស្លេកស្លាំង (ជាលិកាត្របកភ្នែកស្លេកស្លាំង) ។



*រូបភាពទី ៥.៦: រាកមានពណ៌ប្រផេះ*

ខ. ព្យាបាល

- ប្រើទីឡូស៊ីន (Tylosin) ដូចជា ទីឡូបូក (Tylo+), ទីប៊ីយង់ (Tylbian) ។ល ។

គ. ការពារ

- នៅពេលផ្លាស់ជ្រូកយកទៅទ្រុងបំប៉ន ត្រូវលាយទីឡូស៊ីន ជាមួយអុកស៊ីតេត្រាស៊ីគ្លីន (Tylosin + Oxytetracycline) ក្នុងចំណីឱ្យវាស៊ីរយៈពេល ៥ថ្ងៃ។

## II. ក្តៀន

ការក្តៀន ច្រើនកើតលើមេជ្រូក ហើយវាប៉ះពាល់ខ្លាំងចំពោះមេជ្រូកនៅពេលវាជិតកើតកូន។

ក. រោគសញ្ញា

- លាមកស្ងួត។
- លាមកតិច។



*រូបភាពទី ៥.៧: លាមកក្តៀនស្ងួត*

ខ. មូលហេតុ

- មេជ្រូកមិនសូវស៊ីចំណីគ្រប់គ្រាន់ៈ ពីព្រោះជ្រូកក្តៅខ្លាំង (វាអាចជារោគសញ្ញានៃជំងឺផ្សេងៗដូចជា គ្រុនចៀកខៀវ ប៉េស្ត។
- ដោយសារចំណីមានជាតិសរសៃ បន្លែស្រស់មិនគ្រប់គ្រាន់។

គ. ព្យាបាល

- ដេញឱ្យមេជ្រូកដើរដើរ។
- ផ្តល់ពពួកបន្លែបៃតង។
- បញ្ចុកប្រេងប៉ារ៉ាហ្វីន (Paraffin oil) តាមមាត់ ៣០០ ម.លក្នុង ១ថ្ងៃ។

**ក្តៀន គឺជាបញ្ហាដ៏សំខាន់ដែលធ្វើឱ្យជ្រូកពិបាកកើតកូន និងជាបុព្វហេតុដែលបង្កឱ្យមានជំងឺលាសដោះរលាកស្បូន និងអត់ទឹកដោះ (MMA)។**

## III. ព្រូនអាស្ការី (Ascaris)

កើតមានលើជ្រូកសាច់ និងមេជ្រូក ។

### ក. រោគសញ្ញា



*រូបភាពទី ៥.៨: អាស្ការីសជាព្រូនធំ ងាយមើលឃើញក្នុងលាមក*

- ក្នុងលាមកមានព្រូនប្រវែងពី ២៥០-៤០០ ម.ម ។
- មានព្រូនជាច្រើននៅក្នុងពោះវៀនស្រូបយកចំណីអាហារ ដែលធ្វើឱ្យជ្រូកលូតលាស់យឺត ។
- កូនព្រូនធ្វើការបំលាស់ទីទៅក្នុងសួត ហើយបណ្តាលឱ្យជ្រូកក្អក ។

### ខ. ព្យាបាល

- ចាក់អ៊ីវើមិចទីន (Ivermectine) ១% គឺ ១ ម.ល ក្នុង៣០ គ.ក្រទម្ងន់រស់ ។

### គ. ការពារ

- ចាក់អ៊ីវ៉ូមិចទីន ឱ្យមេជ្រូកមុនពេលកើតកូន ២ អាទិត្យ ។
- ចាក់អ៊ីវ៉ូមិចទីន ឱ្យកូនជ្រូកនៅពេលផ្តាច់ដោះ ។

# ជំពូក ៦ ការពិនិត្យក្រសាល់គូទ

## ធ្លាក់ក្រសាល់គូទ

### ក. រោគសញ្ញា

- ក្រសាល់គូទលៀនចេញក្រៅ(១-១០ស.ម) ហើយចាប់ផ្ដើមហើមនិងមានទឹករងៃ។ វាអាចមានការហូរឈាមដោយសារការរលាត់ ឬដាច់។
- ជ្រូកផ្សេងទៀតអាចខាំទាញក្រសាល់គូទដែលលៀននេះ។
- ជ្រូកស្លេកស្លាំង ដោយសារហូរឈាមច្រើន។
- ក្ស្សៀន។



*រូបភាពទី ៦.១: ជ្រូកលៀនក្រសាល់គូថ*

### ខ. មូលហេតុ

- រាកធ្វើឱ្យជ្រូកប្រឹងខ្លាំង។
- ប្រឹងក្អក។
- ចំណីមានមីកូតុកស៊ីន ដូចជាពោត។
- ធ្លាក់ក្រសាល់គូទដោយសារការប្រឹងខ្លាំងនៅពេលកើតកូន។

### គ. ព្យាបាល

- រុញក្រសាល់គូទចូល ហើយដេរព័ទ្ធជុំវិញក្រសាល់គូទ។

# ជំពូក ៧ ការពិនិត្យផ្លូវបន្តពូជ និងទឹកនោម

ពេលខ្លះ បសុពេទ្យមិនអាចកត់សំគាល់ការហូរខ្ទុះតាមប្រដាប់បន្តពូជទេ។ វាសំខាន់ណាស់ក្នុងការពិនិត្យមើលដោយយកចិត្តដាក់លើកម្រាលទ្រុង ឬប្រដាប់ភេទមេជ្រូក ដើម្បីឱ្យឃើញការហូរខ្ទុះតាមប្រដាប់បន្តពូជទេ។

## I. ហូរខ្ទុះតាមប្រដាប់បន្តពូជ

### ១. រលាកប្លោកនោម និងរលាកតំរងនោម

ស្ថានភាព និងការស៊ីចំណីរបស់មេជ្រូកពេលខ្លះមានសភាពធម្មតា ប៉ុន្តែជួនកាលក៏វាមានជំងឺ**រលាកប្លោកនោម និងរលាកតំរងនោមដែរ**។

#### ក. រោគសញ្ញា

- ជំងឺនេះមានសភាពរ៉ាំរ៉ៃហើយមិនបណ្តាលឱ្យសត្វងាប់ទេ។
- ខ្ទុះលាយជាមួយទឹកនោមឬមានទឹកហូរចេញពណ៌ស ជាប់ប្រដាប់បន្តពូជ។
- មានខ្ទុះនៅលើកម្រាល ឬនៅជាប់ទ្រុង។



*រូបភាពទី ៧.១: ហូរខ្ទុះតាមប្រដាប់បន្តពូជ*

#### ខ. ព្យាបាល

**ត្រូវព្យាបាល** ទោះបីជាមេជ្រូកមើលមានទៅសភាពធម្មតាក៏ដោយ

- ប្រើអង់ទីប៊ីយ៉ូទិកដូចជា ចាក់ ឬលាយក្នុងចំណីនូវអុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) ឬទ្រីមេតូព្រីមជាមួយស៊ុលហ្វា (Sulfa TMP)។

### ២. រលាកប្លោកនោម និងរលាកស្បូន

មេជ្រូកឈឺមិនអាចស៊ីចំណី ហើយបង្ហាញអាការៈឈឺចាប់

វាជាជំងឺ**រលាកប្លោកនោម-រលាកស្បូន**។

# ជំពូក ៩ ទឹកនោមមានពណ៌ខុសធម្មតា

កំហាប់ទឹកនោមកើនឡើង

## ក. រោគសញ្ញា

- ទឹកនោមមានពណ៌លឿងចាស់។
- លាមកស្ងួត។
- ភ្នែកខូង។



*រូបភាពទី ៩.១: ដើម្បីពិនិត្យទឹកនោម ត្រូវដាស់ជ្រូកឲ្យក្រោក ហើយរង់ចាំបន្តិច ជ្រូកនឹងនោម*

## ខ. មូលហេតុ

- ផឹកទឹកមិនគ្រប់គ្រាន់ធ្វើឱ្យកំហាប់ទឹកនោមកើនឡើង ហើយប្រែពីពណ៌លឿងខ្ចីទៅជាលឿងចាស់។
- ចំណីសំបូរទៅដោយទង់ដែងស៊ុលផាត ($CuSO_4$) ច្រើន។

## គ. ផលប៉ះពាល់

- សម្រាប់មេបំបៅកូន វាផលិតទឹកដោះតិច។
- ចំពោះមេផើម ធ្វើឱ្យរលាកប្លោកនោម។
- ចំពោះជ្រូកសាច់ធ្វើឱ្យវាស៊ីចំណីតិច និងលូតលាស់យឺត។

## ឃ.ព្យាបាល

- ចំពោះមេផើម ត្រូវឱ្យវាផឹកទឹកពី ២០-៣០ លីត្រក្នុងមួយថ្ងៃ។
- ចំពោះមេបំបៅកូន ត្រូវឱ្យផឹកទឹកពី ៣៥-៤៥ លីត្រក្នុងមួយថ្ងៃ។

# ជំពូក ១០ ពិនិត្យរោគវិនិច្ឆ័យកន្សោមដោះ

ការពិនិត្យកន្សោមដោះ ត្រូវធ្វើឡើងដោយស្ទាបដោះឱ្យបានហ្មត់ចត់ ដើម្បីដឹងពីសភាពរបស់ដោះ (រឹង ទន់ ក្តៅ ឬហើម) ។

## I. បញ្ហាអត់ទឹកដោះ

### ១. រលាកស្បូន លាសដោះ អត់ទឹកដោះ (MMA)

#### ក. រោគសញ្ញា

- អត់ទឹកដោះ ។
- មេជ្រូកមិនស៊ីចំណី ។
- កូនជ្រូកងាប់ ដោយសារអត់ទឹកដោះ ។
- ជួនកាលកន្សោមដោះឡើងរឹង ។



*រូបភាពទី ១០.១: បើមេជ្រូកគ្មានទឹកដោះបន្ទាប់ពីកើតកូន ពេទ្យសត្វត្រូវព្យាបាលវាជាបន្ទាន់*

#### ខ. ព្យាបាល

- ត្រូវព្យាបាលជា**បន្ទាន់** ព្រោះកូនជ្រូកនឹងងាប់ដោយគ្មានទឹកដោះបៅ ។
- ចាក់អុកស៊ីតុកស៊ីន 0,៥ សេសេ **តាមសរសៃវ៉ែន** ដោយចាក់ ៣ដងក្នុងមួយថ្ងៃ (ទឹកដោះនឹងចេញភ្លាម) ។
- ចាក់អង់ទីប៊ីយ៉ូទិក : ទ្រីមេតូព្រីម ជាមួយស៊ុលហ្វា (Sulfa TMP) ដោយចាក់ ១ដងក្នុងមួយថ្ងៃរយៈពេល ៥ថ្ងៃ ។
- ចាក់ដិចសាមេតាស៊ូន (Dexamethasone) ប្រសិនកន្សោមដោះឡើងរឹង ។

#### គ. ការពារ

- ជៀសវាងការក្តៀនមុនពេលកើតកូន ។
- ត្រូវបំលាស់ទីមេជ្រូកទៅទ្រុងសម្រាប់កើត យ៉ាងតិច ១០ ថ្ងៃ មុនពេលកើត ។

## II. កន្សោមដោះរឹង

### ១. លាសដោះ

#### ក. រោគសញ្ញា



*រូបភាពទី ១០.២: មានតែក្បាលដោះមួយចំនួន ដែលអាចផលិតទឹកដោះសម្រាប់កូនជ្រូក ២-៣ ពៅ*

- កូនជ្រូកខ្សោយ ដោយសារពួកវាបៅមិនបានគ្រប់គ្រាន់ ។
- មេជ្រូកមិនស៊ីចំណី ។
- គ្រុនក្តៅចាប់ពី ៤០ អង្សារសេ ។
- កន្សោមដោះហើម ពណ៌ក្រហម និងឈឺចាប់ប្រសិនបើការព្យាបាលមិនបានល្អរយៈពេល ២-៣ ថ្ងៃ បន្ទាប់ក្រពេញដោះនឹងឈប់ផលិតទឹកដោះ ។

#### ខ. ព្យាបាល

- ចាក់អង់ទីប៊ីយ៉ូទិក : ទ្រីមមេតូព្រីមជាមួយស៊ុលហ្វា (Sulfa TMP) ឬ អាម៉ុកស៊ីស៊ីលីន អិល អេ (Amoxicillin LA) ។
- ចាក់ដិចសាមេតាស៊ូន (Dexamethasone) ។
- ប្រសិនបើកូនជ្រូកអាយុលើសពី ១០ ថ្ងៃ ត្រូវផ្តល់ចំណីសម្រេច (ចំណីគ្រាប់) ក្នុងករណីមេជ្រូកមានបញ្ហាលាសដោះ ។

### ២. ដំបៅក្បាលដោះ

នៅពេលដែលក្បាលដោះមានរបួស មេជ្រូកមានការឈឺចាប់ និងមិនឱ្យកូនបៅ ។

#### ក. រោគសញ្ញា

- ស្នាមដាច់លើស្បែកក្បាលដោះ ។
- ក្បាលដោះប្រែពីពណ៌ក្រហមស្រាលទៅជាខ្មៅ ។
- ដំបៅ ។
- ស្នាមរបួស ឬក្រមរ ។

• ដំបៅ ។

• ស្នាមរបួស ឬក្រមរ ។



រូបភាពទី ១០.៣: ដំបៅបង្កដោយធ្មេញកូនជ្រូក



រូបភាពទី ១០.៤: ដំបៅបង្កដោយជំងឺអុតក្តាម

## ខ. មូលហេតុ

- កម្រាលមិនល្អ ។
- កូនជ្រូក មិនបានកាត់ធ្មេញ ឬកាត់ធ្មេញមិនបានត្រឹមត្រូវ ។
- ជំងឺអុតក្តាម ។

## គ. ព្យាបាល

- ប្រើទឹកអ៊ីយូឌីន លាបសម្លាប់មេរោគលើក្បាលដោះ ។
- ចាក់អង់ទីប៊ីយ៉ូទិក ដូចជា អាម៉ុកស៊ីស៊ីលីន អិលអេ (Amoxicillin LA) ។

# ជំពូក ១១ ពិនិត្យលើសកម្មភាពរបស់ជ្រូក

ត្រួតពិនិត្យ

- វិធីសាស្ត្រតែមួយ ដើម្បីពិនិត្យបញ្ហាជើងយើងត្រូវចូលទៅក្នុងទ្រុង ដើម្បីបង្ខំឱ្យជ្រូកឈរ ។
- ដើម្បីរកមូលហេតុជំងឺ គេត្រូវបន្តពិនិត្យពីក្រចករហូតដល់ជើងទាំងមូល ។

ផលប៉ះពាល់សំខាន់គឺ

- ធ្វើឱ្យជ្រូកផឹកទឹកមិនគ្រប់គ្រាន់ ដែលជាហេតុបណ្ដាលឱ្យរលាកប្លោកនោម ។
- ធ្វើឱ្យជ្រូកមិនអាចស៊ីចំណីបានគ្រប់គ្រាន់ ដែលជាហេតុនាំឱ្យក្លៀន និងលូតលាស់យឺត ។
- ជ្រូកដែលឈឺមានជំហរមិនល្អ ។



*រូបភាពទី ១១.១: មេជ្រូកមិនអាចទ្រខ្លួននឹងជើងក្រោយទ្វេង*

## I. ខ្វក់ជើង

### ១. រលាកសន្លាក់

- រលាកសន្លាក់បង្កឡើងដោយបាក់តេរី ។
- បាក់តេរីបង្កជំងឺលើកូនជ្រូកកំពុងបៅដោះគឺ ស្ត្រិបតូកុកកូស (Streptococcus) ។

### ក. រោគសញ្ញា

- ខ្វក់ជើងដោយហើមសន្លាក់ ។

▪ ជ្រូកមានសភាពឈឺចាប់ ។

▪ មិនចង់ក្រោកឈរ ។



រូបភាពទី ១១.៣: រលោកសន្ទាក់ជើងមុខ



រូបភាពទី ១១.២: រលោកសន្ទាក់ជង្គង់ក្រោយ

## ខ. ព្យាបាល

▪ ប្រើឡាំងកូមីស៊ីន (Lincomycin) ឬអាម៉ុកស៊ីស៊ីលីន (Amoxicillin) ។

## គ. ការពារដល់កូនជ្រូក

▪ បន្ទាប់ពីកូនជ្រូកកើតអាយុ ១ ថ្ងៃ ត្រូវចាក់អាម៉ុកស៊ីស៊ីលីន អិលអេ (Amoxicillin LA) ។

## ២. បែកក្រចកជើង

មាននៅលើក្រចក ចន្លោះខ្នែងជើង និងក្រចកជើង ។

## ក. រោគសញ្ញា

▪ ជ្រូកពិបាកដើរ ដោយមានហើមនៅកជើង ។

▪ សភាពហើម ឃើញមាននៅជុំវិញកជើង ហើយបង្កជាដំបៅ ។



រូបភាពទី ១១.៤: ដំបៅបណ្តាលមកពីការប៉ះទង្គិចនឹងទ្រុងដែក



រូបភាពទី ១១.៥: ដំបៅបណ្តាលមកពីការខូចជើង

## ខ. មូលហេតុ

- ដោយសារកម្រាលមិនល្អ ធ្វើពីស៊ីម៉ង់ ឬទ្រុងធ្វើពីដែក។ នៅពេលឃើញមេជ្រូកមានបញ្ហាបែកក្រចកជាញឹកញយ ត្រូវរៀបចំកម្រាលទ្រុងឡើងវិញ។

## គ. ព្យាបាល

- ឡាំងកូមីស៊ីន (Lincomycin) ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (Sulfa TMP) ។
- កម្រាលទ្រុងត្រូវក្រាលអង្កាមពីលើ។
- បាញ់ស្ព្រៃ ដូចជាពួកអុកស៊ីតេត្រាស៊ីគ្លីន (Spray OTC) ត្រង់មុខរបួស។

# ៣. ជំងឺអុតក្ដាម (FMD)

## ក. រោគសញ្ញា

- មានបញ្ហាខ្ចកជើងលឿន។
- ជ្រូកខ្លាចក្នុងការដើរ។
- នៅពេលជ្រូកដើរវាមានសភាពឈឺចាប់ និងស្រែកខ្លាំង។
- មានពងដោរនៅគល់ក្រចកច្រមុះ និងមាត់។


*រូបភាពទី ១១.៦: ដំបៅបណ្ដាលមកពីជំងឺអុតក្ដាម*

## ខ. ព្យាបាល

- ទ្រីមេតូព្រីម ជាមួយស៊ុលហ្វា (Sulfa TMP) ឬអុកស៊ីតេត្រាស៊ីគ្លីន (OTC) ។
- សំអាតមុខរបួសជាមួយសាប៊ូ ហើយបាញ់ស្ព្រៃអុកស៊ីតេត្រាស៊ីគ្លីន (Spray OTC) ។
- រួចបញ្ចុះកម្ដៅដោយប្រើ អាណាល់ហ្សីន (Analgine) តុលហ្វេឌីន (Tolfedine) ។
- ដាក់សត្វឈឺនៅកន្លែងស្ងួត។

### ជ្រូកមិនចង់ដើរ

# ៤. ជំងឺប៉េស្ត (CSF)

មានជំងឺជាច្រើនធ្វើឱ្យជ្រូកក្ដៅ ដែលធ្វើឱ្យវាមិនចង់ដើរ និងក្រោក។ ប៉ុន្តែវាមានលក្ខណៈ

ពិសេសសម្រាប់ជំងឺប៉េស្ត ដែលធ្វើឱ្យជ្រូកខ្ជិល និងគ្មានកម្លាំងនៅជើងសម្រាប់ក្រោកឈរ និងដើរ ។

ក. រោគសញ្ញា

- ជ្រូកមិនចង់ក្រោកឈរ ឬមិនចង់ស៊ីចំណី ។
- នៅពេលអ្នកជួយលើកឱ្យក្រោកឈរ ជ្រូកដើរសំដៅទៅរកស្នូកចំណី តែវាស៊ីបន្តិចបន្តួច ឬមិនស៊ី ហើយវាចង់ដេក ។



រូបភាពទី ១១.៧: ជ្រូកកើតជំងឺប៉េស្តស្រួចស្រាវ ពិបាកធ្វើចលនា

ខ. មូលហេតុ

- គ្រប់ជំងឺឆ្លង ដែលមានលក្ខណៈស្រួចស្រាវតែងតែធ្វើឱ្យកម្តៅខ្លួនសត្វឡើងខ្ពស់ ។ តែអ្នកត្រូវសង្ស័យជាដំបូងថា វាជាជំងឺប៉េស្ត (CSF) ។

## II. ជ្រូកអង្គុយដូចឆ្កែ

### ១. កង្វះកាល់ស្យូម

ក. រោគសញ្ញា

- មេជ្រូកមានសភាពដូចឆ្កែអង្គុយ ។
- រីងខ្លួន ។
- ក្នុងពេលបំបៅកូន ឬផ្តាច់ដោះ មេជ្រូកមានបញ្ហាខ្វកជើងភ្លាម ។



រូបភាពទី ១១.៨: ជ្រូកអង្គុយដូចឆ្កែ

ខ. មូលហេតុ

- ផលិតទឹកដោះច្រើនពេក ។
- ជ្រូកមិនសូវស៊ីចំណី ជាពិសេសមេកំពុងបំបៅកូន ។
- កង្វះវីតាមីន ដេ (D3) ។
- ចំណីមានកាល់ស្យូមមិនគ្រប់គ្រាន់ ។

គ. ព្យាបាល

- វីតាមីន ដេ (D3) ជាមួយកាលស្យូម (ឧ. កូហ្វាកាល់ស្យូម Cofacalcium)។

ឃ. ការពារ

- បន្ទាប់ពីកើតត្រូវលាយម្សៅ ដេ សេ ប៉េ (DCP) ៣០ ក្រាមក្នុងមួយថ្ងៃ។

## ២. ទន់ជើង ឬកន្ទេកជើង

កូនជ្រូកទន់ជើង ឬកន្ទេកជើង។

ក. រោគសញ្ញា

- កូនជ្រូកមិនអាចក្រោកឈរ ជើងក្រោយពែកទៅរាបដល់ដី។
- កូនជ្រូកមិនអាចដើរបាន ដូចនេះវាងាយរងការដេកកិនពីមេ។
- កូនជ្រូកកម្រេរស់។



*រូបភាពទី ១១.៩: កូនជ្រូកទន់ជើង ឬកន្ទេកជើងទើបនឹងកើត*

ខ. ព្យាបាល

- ប្រើកៅស៊ូបន្ទះ ២៥ ម.ម រុំជើងក្រោយ។
- ម៉ាស្សាត្រង់សាច់ដុំ។
- ចាប់កូនជ្រូកឱ្យបៅ ២-៣ ដងក្នុងមួយថ្ងៃ។

គ. ការពារ

ចាក់វីតាមីនអ៊ី-សេលេនីញ៉ូម (Vitamin E – selenium) ឱ្យមេជ្រូកនៅ ៣ សប្តាហ៍មុនពេលកើត។

# ជំពូក ១២ ការពិនិត្យច្រមុះ និងការដកដង្ហើម

I. ការក្អក

ការក្អកងាយសង្កេតណាស់ ប៉ុន្តែពេលខ្លះវាមិនបង្ហាញអោយឃើញនោះទេ ដូចនេះយើងត្រូវធ្វើឱ្យវាផ្លាស់ទី ដើម្បីសង្កេតចង្វាក់នៃការដកដង្ហើម និងការក្អករបស់វា។

១. មីកូប្លាស្មា

ក. រោគសញ្ញា

- ក្អកជាប់គ្នា ៧ ទៅ ៨ ដងក្នុងមួយលើក។
- ក្អកខ្លាំងនៅពេលព្រឹកព្រលឹម។
- កម្តៅជាមធ្យម ៣៩.៥០ អង្សាសេ។
- ជ្រូកនៅតែបន្តស៊ីចំណី ប៉ុន្តែការស្រូបសារធាតុចិញ្ចឹមពីចំណីថយចុះ ៥០ភាគរយ។



រូបភាពទី ១២.១: មានភាពងាយស្រួលក្នុងការអង្កេតឃើញជ្រូកក្អក ប៉ុន្តែការដឹងពីចំនួននៃការក្អក និងបញ្ហាដំណកដង្ហើមមានសារៈសំខាន់ណាស់។

ខ. ព្យាបាល

ចាក់អុកស៊ីតេត្រាសីគ្លីន (OTC) ឬអង់រ៉ូហ្វ្លក់សាក់ស៊ីន ( Enrofloxacine) ឬផ្លរហ្វេនីកុល ( Flo-rfenicol) ឬទីឡូស៊ីន (Tylosin) រយៈពេល ៥ថ្ងៃ។

គ. ការពារ

- លាយអង់ទីប៊ីយ៉ូទិក (ហ្វ្លរហ្វេនីកុល) ក្នុងចំណីឱ្យស៊ី ២អាទិត្យក្រោយពេលផ្តាច់ដោះ ព្រោះក្នុងអំឡុងពេលនេះកូនជ្រូកបាត់បង់អង់ទីគ័រ ដែលទទួលបានពីមេវា។
- ចំពោះកូនជ្រូក ដែលត្រូវផ្លាស់ទៅកាន់ទ្រុងជ្រូកសាច់ចំបាច់ត្រូវលាយអង់ទីប៊ីយ៉ូទិកខាងលើក្នុងចំណីអោយស៊ី ១អាទិត្យមុន។

## ២. ផ្តាសាយជ្រូក

### ក. រោគសញ្ញា

- ជំងឺមានសភាពធ្ងន់ធ្ងរ : ពេលថ្ងៃជ្រូកមានសុខភាពធម្មតា លុះពេលព្រលឹមឡើង ជ្រូក ៩០ ភាគរយនឹងឈឺ ។
- ជ្រូកក្អក និងពិបាកដកដង្ហើម ។
- សីតុណ្ហភាពលើសពី ៤០ អង្សាសេ ។
- ជ្រូក នឹងជាសះស្បើយឡើងវិញក្នុងរយៈពេល ៥ ថ្ងៃ ។

### ខ. ព្យាបាល

គ្មានថ្នាំព្យាបាល ពីព្រោះផ្តាសាយបង្កឡើងដោយវីរុស ។ ចាក់អង់ទីប៊ីយ៉ូទិក ដើម្បីការពារជំងឺឱកាសនិយម ដែលបង្កឡើងដោយពពួកបាក់តេរីដូចជា ប៉ាស្ទឺរ៉ែលឡា (Pasteurella) មីកូប្លាស្មា (Mycoplasma) ដោយប្រើអុកស៊ីតេត្រាស៊ីគ្លីន (OTC) រយៈពេល ៣ថ្ងៃ ។

## II. ការដកដង្ហើមខុសធម្មតា

### ២. រលាកសួត

ជាពិសេសកើតមានចំពោះកូនជ្រូកនៅពេលផ្តាច់ដោះ និងជ្រូកសាច់ ។

### ក. រោគសញ្ញា

- ដកដង្ហើមញាប់ និងក្អកមួយៗ ។
- កម្តៅលើសពី ៤០អង្សាសេ និងភ្នែកក្រហម ។



*រូបភាពទី ១២.២: ក្នុងករណីរលាកសួត ក្អកមួយៗ និងមានការឈឺចាប់ ការដកដង្ហើមគឺ ប្រឹងដកយ៉ាងពិបាក*

▪ ចេញពណិខៀវនៅលើស្បែក ។

ខ. មូលហេតុ

▪ ជំងឺសារទឹក: ជាជំងឺឱកាសនិយម រួមជាមួយមីកូប្លាស្មា (Mycoplasma) ។

▪ ជ្រូករងការត្រជាក់ ទ្រុងសើមគ្មានអនាម័យ ។

▪ ជំងឺផ្សេងទៀត: សាល់ម៉ូណេឡូស៊ីស (Salmonellosis) មានសភាពធ្ងន់ធ្ងរ ត្រចៀកច្រមុះ និងកន្ទុយមានពណិខៀវ និងបង្កឡើងដោយវីរុសដូចជា ជំងឺឆ្កួតជ្រូក (Aujesky) ជំងឺផ្តាសាយជ្រូក (Swine Flu) ឬជំងឺត្រចៀកខៀវ ( PRRS) ។

គ. ព្យាបាល

▪ អង់ទីប៊ីយ៉ូទិក ដែលមានសកម្មភាពប្រឆាំងនឹងពួកប៉ាស្ទឺរ៉ែលឡា និងមីកូប្លាស្មាដូចជា អុកស៊ីតេត្រាស៊ីគ្លីន (OTC) ឬអង់រ៉ូផ្លុកសាស៊ីន (Enrofloxacin) ឬ ផ្លរហ្វេនីកុល (Florfenicol) ដោយប្រើកម្រិតថ្នាំទ្វេដងចាក់នៅថ្ងៃទី ១ ។

▪ ត្រូវដាក់ជ្រូកនៅកន្លែងស្ងួត និងកុំឱ្យជ្រូកទទួលនូវភាពត្រជាក់ ។

## III. ការហូរសារធាតុរាវតាមច្រមុះ

### ១. ការហូរខ្ទុះតាមរន្ធច្រមុះ

ក. រោគសញ្ញា

▪ ឃើញខ្ទុះហូរចេញមកពីរន្ធច្រមុះ ។

▪ ជាទូទៅកើតលើជ្រូកអាយុពី ១០ ទៅ ១៨ អាទិត្យ ។

▪ ក្អក និងដកដង្ហើមញាប់ ។

▪ កម្ដៅលើស ៤០អង្សាសេ ។

▪ ចេញជាំពណិខៀវនៅលើស្បែក ជាពិសេសនៅលើចុងត្រចៀក ។



*រូបភាពទី ១២.៣: ហូរខ្ទុះតាមច្រមុះ*

ខ. មូលហេតុ

▪ ជំងឺសារទឹក ។

- ជំងឺឱកាសនិយម គឺមេរោគមីកូប្លាស្មា។

គ. ការព្យាបាល

- អុកស៊ីតេត្រាស៊ីគ្លីន ឬអង់រ៉ូផ្លុកសាស៊ីន ឬផ្លូហ្វេនីកុល... ចាក់កម្រិតទ្វេដងនៅថ្ងៃទី១។
- អាម៉ុកស៊ីស៊ីលីន មានប្រសិទ្ធភាពព្យាបាលជំងឺសារទឹក ប៉ុន្តែមិនមានប្រសិទ្ធភាពព្យាបាលមីកូប្លាស្មាទេ ដូចនេះគួរប្រើអុកស៊ីតេត្រាស៊ីគ្លីន (OTC) ឬអង់រ៉ូផ្លុកសាស៊ីន (Enrofloxacin) ឬផ្លូរហ្វេនីកុល (Florfenicol) ដែលពួកវាមានប្រសិទ្ធភាពសម្រាប់ព្យាបាលជំងឺទាំងពីរខាងលើ។

**ចំណាំ: ការចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺសារទឹកមិនមានប្រយោជន៍ទេ**

## ២. ការហូរឈាមតាមច្រមុះ

ក. រោគសញ្ញា

- ឈាមហូរមានពពុះចេញពីច្រមុះ។
- ក្អករយៈពេលខ្លីៈ ក្អកម្តងពី ១ ទៅ ៣ដង។
- ពិបាកដកដង្ហើមធ្ងន់ធ្ងរ។
- ត្រចៀកពណ៌ខៀវ។
- ជ្រូកចុះខ្សោយកម្លាំងធ្ងន់ធ្ងរ។
- មិនស៊ីចំណី។
- សីតុណ្ហភាពខ្ពស់។
- ងាប់ភ្លាមៗ និងអត្រាងាប់ខ្ពស់។



*រូបភាពទី ១២.៤: ហូរឈាមមានពពុះតាមច្រមុះ*

ខ. មូលហេតុ

បង្កដោយមេរោគ អាក់ទីណូបាក់ស៊ីលុស (Actinobacillus) ។

គ. ការព្យាបាល

អាម៉ុកស៊ីស៊ីលីន (Amoxicillin) ឬ អង់រ៉ូផ្លក់សាស៊ីន (Enrofloxacine) ចាក់កម្រិត ទ្វេដងនៅថ្ងៃទី ១។

# ជំពូក ១៣

# ការធ្វើរោគវិនិច្ឆ័យ ជំងឺប្រព័ន្ធសរសៃប្រសាទ

## I. ការប្រកាច់

### ស្ត្រិបតូកុកកូស

#### ក. រោគសញ្ញា

- ជាទូទៅច្រើនកើតលើកូនជ្រូកផ្ដាច់ដោះ។
- ចលនារបស់ភ្នែកញាក់កន្ត្រាក់ៗ។
- កូនជ្រូកដេកផ្អៀង ហើយញាក់ៗ។
- បន្ទាប់មកជ្រូកប្រែពោះម្ខាងទៀត ជើងខ្ចៅៗ និងបែកពពុះមាត់។
- សីតុណ្ហភាព ៤១អង្សាសេ។



*រូបភាពទី ១៣.១: កូនជ្រូកប្រកាច់ដោយសារ ឆ្លងជំងឺស្ត្រិបតូកុកគូស*

#### ខ. ព្យាបាល

- ផ្លាស់ទីកូនជ្រូកនៅកន្លែងផ្សេង និងថែរក្សាវាឱ្យនៅកន្លែងស្ងៀមស្ងាត់។
- ដំបូងចាក់ដិចសាមេតាសូន (Dexamethasone) (តែមួយដងគត់)។
- ចាក់អំពីសាលីន (Ampicillin) ឬអាម៉ុកស៊ីស៊ីលីន (Amoxicillin) រយៈពេល ៥ថ្ងៃ។

## II. ការឈរមិននឹង

### ជំងឺហើម

#### ក. រោគសញ្ញា

- កើតលើកូនជ្រូកអាយុ ១-៤អាទិត្យ ក្រោយពេលផ្ដាច់ដោះ។
- ឈរមិននឹង កូនជ្រូកដើរដូចស្រវឹងស្រា។

- ហើមត្របកភ្នែក។
- សម្លេងស្ទូរងឺត១ខុសធម្មតា។
- ឈប់ស៊ីចំណី ប៉ុន្តែសីតុណ្ហភាពធម្មតា។
- បន្ទាប់មកពេលខ្លះខ្វិន និងពិបាកដកដង្ហើម។



*រូបភាពទី ១៣.២: កូនជ្រូកឈរមិននឹង និង ហើមត្របកភ្នែកដោយសារជំងឺហើម*

### ខ. ព្យាបាល

- ចាក់ទ្រីមេតូព្រីម ជាមួយស៊ុលហ្វា (Sulfa TMP) ឬអង់រ៉ូផ្លក់សាស៊ីន (Enrofloxacine) និងដិចសាមេតាសូន (Dexamethasone)។
- ជាញឹកញាប់កូនជ្រូកងាប់។

### គ. ការការពារ

- ផ្តល់ចំណីដែលមានប្រូតេអ៊ីន តែ ១៨ ភាគរយ។
- ប្រើក្លរីនសម្រាប់លាយក្នុងទឹក។

## III. ការញាក់ញ័រ

### ជំងឺប៉េស្តជ្រូក (CSF)

### ក. រោគសញ្ញា

- សាច់ដុំញាក់ញ័រ គេសង្កេតឃើញសញ្ញានេះ នៅពេលដែលវាកំពុងដើរតែប៉ុណ្ណោះ ហើយ មិនឃើញទេនៅពេលដែលកូនជ្រូកដេក។
- រោគសញ្ញាប្រព័ន្ធប្រសាទ ដងខ្លួនញាក់ញ័រ ។
- មិនអាចឈរបាន ឬដើរមិនត្រង់។
- ការឈរមិននឹង។



*រូបភាពទី ១៣.៣: កូនជ្រូកញាក់ញ័រជាទូទៅគឺខ្សោយ និងមានទំហំខុស ៗគ្នា ដោយសារមេជ្រូកឆ្លងជំងឺប៉េស្តនៅពេលដើម*

### ខ. ព្យាបាល និងការពារ

- មិនអាចព្យាបាលបានទេ។

▪ ត្រួតពិនិត្យកម្មវិធីចាក់វ៉ាក់សាំងការពារប្រឆាំងនឹងជំងឺប៉េស្តឡើងវិញ។

## IV. ការកន្ត្រាក់សាច់ដុំ

### ១. ជំងឺឆ្កែឆ្កួត

កើតលើជ្រូក ជាពិសេសជ្រូកដែលចិញ្ចឹមលែង ហើយត្រូវឆ្កែឆ្កួតខាំ។

### ក. រោគសញ្ញា

▪ ឆ្កែឆ្កួតបានខាំជ្រូក។

▪ ពិបាកដើរ ភ្នែកក្រឡេកក្រឡាប់។

▪ ញាក់ច្រមុះ។

▪ ស៊ីលឿន និងហៀរទឹកមាត់ច្រើន។

▪ សាច់ដុំកន្ត្រាក់ៗ និងដំណើរញើរញ័រ។

▪ សាច់ដុំអាចទៅជាញាក់ញ័រ។

▪ ការងាប់ជាទូទៅកើតក្នុងអំឡុងពេល ៣ថ្ងៃ។

### ខ. ព្យាបាល

▪ មិនមានថ្នាំព្យាបាលទេ។

▪ ចូរចងចាំថា ជំងឺឆ្កែឆ្កួតគ្រោះថ្នាក់ចំពោះមនុស្ស។



*រូបភាពទី ១៣.៤: ឆ្កែមានជំងឺឆ្កែឆ្កួត*

## ២. ជំងឺតេតាណូស

### ក រោគសញ្ញា

- កូនជ្រូកងាយទទួលជំងឺនេះ ។
- រឹងជើង និងសាច់ដុំ ។
- កន្ទុយត្រង់ ។
- សាច់ដុំនៅលើត្រចៀក និងមុខញាក់ញ័រ ។



*រូបភាពទី ១៤.១: កូនជ្រូកបង្ហាញរោគសញ្ញាតេតាណូស (នៅពេលដែលអ្នកប៉ះ វាមិនក្រោក ឬមិនរត់) បន្ទាប់ពីក្រៀវបាន២-៣ថ្ងៃ*

### ខ. មូលហេតុ

- មកពីមិនបានធ្វើអនាម័យឱ្យត្រឹមត្រូវនៅពេលក្រៀវ ។

### គ. ព្យាបាល

- ដំណាក់កាលដំបូង ចាក់ប៉េនីស៊ីលីនកម្រិតខ្ពស់ជាប្រចាំថ្ងៃ ។

## ៣. ខ្វិន (Paralysis)

### ការពុលដោយបាក់តេរីក្នុងចំណី

បណ្តាលមកពីពពួកបាក់តេរីរស់នៅកន្លែង ដែលគ្មានអុកស៊ីសែនដូចជា ដី និងចំណីដែលស្អុយរលួយ ។ ការពុលចំណី ជាជំងឺកើតមានលើជ្រូក ដែលដើររកចំណីតាមទីវាល ។

### ក. រោគសញ្ញា

- ញាក់សាច់ដុំ ។
- ភាពទន់ខ្សោយរបស់ដៃជើងបណ្តាលឱ្យញាក់ញ័រ ឬខ្វិន ។
- ខ្វាក់ភ្នែក ។
- ហៀរទឹកមាត់ច្រើន ។
- ពិបាកដកដង្ហើម ។

## ខ. មូលហេតុ

- ដោយសារបាក់តេរីក្លូស្រ្ទីដ្យូមបញ្ចេញជាតិពុល ។
- ដោយសារជ្រូកស៊ីចំណីរលួយ ដូចជាសម្រាម ។
- ដីមានពពួកបាក់តេរី ។

## គ. ការព្យាបាល

មិនមានប្រសិទ្ធភាពទេ ។

- ប្រើអាម៉ុកស៊ីស៊ីលីនក្នុងកម្រិតខ្ពស់ ។



*រូបភាពទី ១៤.២: សំរាម សំណើម និងលក្ខខណ្ឌដែលគ្មានខ្យល់ជាកន្លែងដែល ល្អបំផុតរបស់បាក់តេរីក្លូស្ត្រីដ្យូម*

ជំពូក ១៤

# ការពិនិត្យសត្វដែលបង្ហាញសញ្ញាមិនស៊ីចំណី

## I. ការមិនស៊ីចំណីដោយសីតុណ្ហភាពក្នុងខ្លួនធម្មតា

សត្វមិនស៊ីចំណី ហើយសីតុណ្ហភាពនៅពេលព្រឹកធម្មតា។

### ដំបៅក្រពះ

#### ក. រោគសញ្ញា

- ជាទូទៅកើតលើជ្រូកមេ និងជ្រូកសាច់។
- មិនស៊ីចំណី តែសីតុណ្ហភាពក្នុងខ្លួនធម្មតា។
- ស្លេកស្លាំង (ការហូរឈាមក្នុងក្រពះ)។
- លាមកក្មៀន (លាមកពណ៌ខ្មៅ)។
- ក្អួត។



*រូបភាពទី ១៥.១: ជ្រូកមានការឈឺចាប់ខ្លាំង និងមិនអាចស៊ីចំណីបានដោយសារដំបៅក្រពះ*

#### ខ. មូលហេតុ

- ចំណីមិនមានជាតិសរសៃគ្រប់គ្រាន់។
- វត្ថុធាតុដើមក្នុងចំណីមានគុណភាពអន់។

#### គ. ព្យាបាល

- ផ្តល់ចំណី ៤ ទៅ ៥ដងក្នុង ១ថ្ងៃ ដោយលាយជាមួយទឹកដើម្បីឱ្យចំណីទន់។
- ផ្តល់បន្លែស្រស់។
- ចាក់ការ៉ាស៊ីល (Carasil) ឬអេម៉ាតូប៉ង់ (Hematopan) ដើម្បីជំរុញឱ្យវាស៊ីចំណី និងផ្តល់វីតាមីនបេ ១២ (Vitamin B12)។

## II. ការមិនស៊ីចំណី ដោយសីតុណ្ហភាពក្នុងខ្លួនក្តៅ

#### ក. រោគសញ្ញា

- ជ្រូកមិនស៊ីចំណី។

- កម្តៅនៅពេលព្រឹកឡើងលើសពី ៤០អង្សាសេ ។
- មិនមានរោគសញ្ញាដទៃទៀតទេ ។

### ខ. មូលហេតុញឹកញាប់

- មេរោគក្នុងឈាម (Septicemia)៖ នៅពេលបាក់តេរីវិវត្តនៅពេញទាំងខ្លួនដោយឆ្លងកាត់តាមសរសៃឈាមនានា ។ជំងឺនេះមានលក្ខណៈធ្ងន់ធ្ងរនិងជារឿយៗធ្វើអោយសត្វចុះខ្សោយយ៉ាងខ្លាំង សីតុណ្ហភាពឡើងខ្ពស់ និងមិនឃ្លានចំណី ។
  - កូនងាប់ក្នុងពោះ មេមិនអាចស៊ីចំណីបន្ទាប់ពីកើតកូនបាន ២-៣ថ្ងៃ និងសីតុណ្ហភាពឡើងខ្ពស់ ។ ប្រសិនបើមេរោគមិនធ្វើការវិវត្តន៍ទេនឹងមានការហូរឈាមធ្លាក់តាមផ្លូវបន្តពូជ ។
  - កូនងាប់កើតមិនអស់ និងសុកមិនធ្លាក់ ។
  - បាក់តេរីក្នុងឈាមផ្សេងទៀត (ឧទាហរណ៍ ជំងឺកញ្ជ្រិល) ។



*រូបភាពទី ១៥.២៖ កូនជ្រូកងាប់នៅក្នុងពោះ ដោយសារកើតមិនអស់ និងសុកមិនធ្លាក់*

  - ជំងឺធ្លាក់ស៖ ពេលដែលជំងឺឆ្លងដល់ក្រលៀនរបស់មេជ្រូក មេរោគនឹងធ្វើការវិវត្តនក្នុងឈាម ។
- ប៉េស្តស្រួចស្រាវ(បង្ហាញរោគសញ្ញាមិនច្បាស់លាស់)៖ ករណីនេះគេសង្កេតឃើញសីតុណ្ហភាពឡើងខ្ពស់ក្នុងរយៈពេលប៉ុន្មានថ្ងៃ ប៉ុន្តែការប្រើប្រាស់អង់ទីបូទិកពុំមានប្រសិទ្ធភាពទេ ។ យើងត្រូវពិនិត្យ ២ ទៅ៣ថ្ងៃបន្ទាប់ ហើយធ្វើការវះកាត់សាកសព ដើម្បីរករោគសញ្ញា ជំងឺប៉េស្ត ។

### គ. ព្យាបាល

ត្រូវធ្វើការចាក់អង់ទីប៊ីយ៉ូទិក ដែលមានសកម្មភាពលឿន (អុកស៊ីតេត្រាស៊ីគ្លីន Oxytetracyclin ឬអង់រ៉ូហ្លក់សាស៊ីន Enrofloxacine) ដោយប្រើកម្រិតទ្វេដង ។

**យើងត្រូវចាក់អុកស៊ីតូស៊ីននៅពេលមេជ្រូកកើតកូនរួចរាល់ ដើម្បីឱ្យប្រាកដថាមិនមានកូនជ្រូកងាប់ ឬសុកមិនទាន់ធ្លាក់អស់។**

# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ការប្រើប្រាស់បសុឱសថ

ឧបត្ថម្ភដោយៈ

គម្រោងចិញ្ចឹមសត្វកម្ពុជា
សហគមន៍អឺរ៉ុប

សហគមន៍អឺរ៉ុប

អង្គការស្បៀង និងកសិកម្ម
នៃអង្គការសហប្រជាជាតិ

# មាតិកា

ទំព័រ


**១- បសុឱសថ** .................................................. ០១

១-១- សេចក្ដីផ្ដើម .................................................. ០១

១-២- ការបែងចែកប្រភេទឱសថ .................................................. ០២

**២-ការបង្ហាញពីប្រភេទឱសថ** .................................................. ១៥

២-១- ការបង្ហាញពីប្រភេទឱសថ .................................................. ១៥

២-២- ប្រភេទឱសថសម្រាប់ចាក់ .................................................. ១៥

២-៣- ប្រភេទម្សៅបញ្ចូកតាមមាត់ .................................................. ១៦

២-៤- ប្រភេទរាវ/ទឹក .................................................. ១៦

២-៥- ប្រភេទគ្រាប់ធំ និងតូច .................................................. ១៧

២-៦- ប្រភេទបន្តក់តាមភ្នែក .................................................. ១៨

២-៧- ប្រភេទស្រោចពីលើសត្វ .................................................. ១៨

២-៨- ប្រភេទក្រែម និងស្រ្តាយ .................................................. ១៩

**៣- ការប្រើប្រាស់បសុឱសថ** .................................................. ១៩

៣-១- ការប្រើប្រាស់បសុឱសថ .................................................. ១៩

៣-២- ការអានស្លាកថ្នាំ .................................................. ២០

៣-៣- ការធ្វើឱ្យរលាយស្មើសាច់ .................................................. ២១

៣-៤- កម្រិតប្រើប្រាស់ .................................................. ២១

៣-៥- ពេលវេលាប្រើប្រាស់ .................................................. ២៣

៣-៥- ផ្លូវបញ្ចូលឱសថ .................................................. ២៦

៣-៦- សំភារៈចាំបាច់ .................................................. ៣១

ទំព័រ

**៤- ការប្រុងប្រយ័ត្ន** ............ ៣២

៤-១- ការលាយឱសថបញ្ចូលគ្នា ............ ៣២

៤-២- ការចម្លងជម្ងឺ ............ ៣៣

៤-៣- កាកសំណល់ឱសថ ............ ៣៤

៤-៤- ផលវិបាកនៃការប្រើប្រាស់ឱសថ ............ ៣៥

៤-៥- គុណភាពរបស់ឱសថ ............ ៤០

៤-៦-ការថែរក្សាឱសថ ............ ៤០

**៥- អង់ទីប៊ីយ៉ូទិក** ............ ៤៣

៥-១- អង់ទីប៊ីយូទិកជាអ្វី? ............ ៤៣

៥-២- អ្វីទៅជាបាក់តេរី? ............ ៤៤

៥-៣- សកម្មភាពរបស់អង់ទីប៊ីយ៉ូទិក ............ ៤៦

៥-៤- គ្រួសារអង់ទីប៊ីយ៉ូទិក ............ ៤៦

៥-៥- ការប្រើអង់ទីប៊ីយ៉ូទិករួមគ្នា ............ ៤៩

៥-៦- ការជ្រើសរើសអង់ទីប៊ីយ៉ូទិក ............ ៥០

**៦- ការណែនាំ** ............ ៥៣

# ការប្រើប្រាស់បសុឱសថ

## ១. បសុឱសថ

### ១.១. សេចក្តីផ្តើម

**និយមន័យ:** បសុឱសថគឺជាសារធាតុសកម្ម ដែលមានប្រសិទ្ធភាពក្នុងការព្យាបាល ឬ ការពារជំងឺ។ បសុឱសថត្រូវប្រើប្រាស់សម្រាប់:

- ថែរក្សាសុខភាពសត្វ គឺមានន័យថាការពារ និង ព្យាបាលជំងឺសត្វ
- កែលំអផលិតកម្មសត្វ
- ការពារសុខភាពសាធារណៈ ដូចជាជំងឺខ្លះអាចឆ្លងពីសត្វមកមនុស្ស

**ត្រូវប្រុងប្រយត្ន:** *នៅពេលប្រើប្រាស់ឱសថត្រូវយកចិត្តទុកដាក់ចំណុចសំខាន់ៗ ៣ គឺ* ***គុណភាព សុវត្ថិភាព និង ប្រសិទ្ធភាព*** *។*



## ១.២. ការបែងចែកប្រភេទឱសថ

ដោយយោងទៅតាមប្រភេទសកម្មភាព គេបែងចែកឱសថជា ៧ ប្រភេទ :

១- **វីតាមីន និងសារធាតុរ៉ែ :** ត្រូវការជាចាំបាច់សម្រាប់ទ្រទ្រង់សុខភាព ធ្វើឱ្យការលូតលាស់បានល្អ និងធ្វើឱ្យការបន្តពូជប្រព្រឹត្តទៅល្អធម្មតា ។

២- **អង់ទីប៊ីយ៉ូទិក :** ជាប្រភេទឱសថដែលចាំបាច់ប្រើសម្រាប់ព្យាបាលជំងឺដែលបង្កឡើងដោយបាក់តេរី វាត្រូវបានប្រើប្រាស់សម្រាប់ការពារការឆ្លងរបស់ពពួកបាក់តេរីផងដែរ ។

៣- **ឱសថប្រឆាំងពួកបរាសិត :** ជាប្រភេទឱសថដែលមានសកម្មភាពប្រឆាំងបរាសិតខាងក្នុង និងខាងក្រៅ ។

៤- **ឱសថប្រឆាំងនឹងការរលាក :** ជាប្រភេទឱសថដែលប្រសិទ្ធភាពប្រឆាំងទប់ទល់នឹងការរលាក គ្រុនក្តៅ និងបន្ថយឈឺចាប់ ។

៥- **អ័រម៉ូន :** ជាប្រភេទឱសថដែលមានសកម្មភាពជួយរំញោចដល់ប្រដាប់បន្តពូជ ។

៦- **វ៉ាក់សាំង :** ត្រូវការចាំបាច់សម្រាប់ការពារជំងឺ ជាពិសេសជំងឺដែលបង្កឡើងដោយវីរុស ។

៧- **ថ្នាំបាញ់សម្លាប់មេរោគ :** មានសកម្មភាពជួយកម្ចាត់ពពួកបាក់តេរី វីរុស ផ្សិត ដែលមាននៅក្នុងបរិយាកាស ។

# ១.២.១. វីតាមីន និងសារធាតុរ៉ែ

## ក- វីតាមីន :

### តួនាទីរបស់វីតាមីន

- វីតាមីន អា (Vitamin A) : មានសារៈប្រយោជន៏សម្រាប់ជួយឱ្យភ្នែក រោម ស្បែក លូតលាស់បានល្អ ។
- វីតាមីន បេ (Vitamin B) : ជាក្រុមនៃពពួកវីតាមីន ដូចជា វីតាមីន បេ ១, វីតាមីន បេ ៦, វីតាមីនបេ ១២ ។
  - **វីតាមីនក្រុមបេ** មានតួនាទីសំខាន់ក្នុងការលូតលាស់ ពីព្រោះវាជួយក្នុងការស្រូបយកប្រូតេអ៊ីន។ កង្វះវីតាមីនក្រុមបេ បណ្ដាលឱ្យសត្វលូតលាស់យឺត ។
  - **វីតាមីន បេដប់ពីរ (Vitamin $B_{12}$)** ចាំបាច់ណាស់សម្រាប់ ធ្វើឱ្យសត្វជាសះស្បើយបន្ទាប់ពីរបួស ។

វីតាមីនជួយឱ្យសត្វមានសុខភាពល្អ ជាពិសេសវីតាមីន**អា** ជួយឱ្យស្បែកភ្លឺរលោងស្អាតល្អ



- វីតាមីន សេ (Vitamin C) ៖ ជួយភ្ញោច និងការពារស្ត្រេសដែលជាមូលហេតុបង្កឱ្យសត្វមានជំងឺ ។
- វីតាមីន ដេ (Vitamin D) ៖ ចាំបាច់សម្រាប់ការលូតលាស់ ការថែទាំឆ្អឹង និងធ្មេញ ព្រមទាំងជួយស្រូបយកកាល់ស្យូម ។
- វីតាមីន អឺ (Vitamin E) ៖ មានតួនាទីសំខាន់សម្រាប់ជួយការបន្តពូជ ធ្វើឱ្យសាច់ដុំមាំមួន និងការពារជំងឺ ។




ក្នុងកំឡុងវ័យបន្តពូជ គេចាំបាច់ត្រូវចាក់ វីតាមីន អាដេ ៣ អឺ ($AD_3E$)

## <u>**ប្រភពវីតាមីន**</u>

- វីតាមីន អា (Vitamin A) ៖ សំបូរនៅក្នុងស្មៅ, ស្លឹកដំឡូងមី, ម្សៅត្រី, ពោតក្រហម
- វីតាមីន បេ (Vitamin B) ៖ សំបូរនៅក្នុងគ្រាប់ធញ្ញជាតិ, សណ្តែកសៀង
- វីតាមីន សេ (Vitamin C) ៖ សំបូរនៅក្នុងផ្លែឈើ, រុក្ខជាតិដុះក្នុងទឹក
- វីតាមីន ដេ (Vitamin D) ៖ សំបូរនៅក្នុងម្សៅត្រី
- វីតាមីន អឺ (Vitamin E) ៖ សំបូរនៅក្នុងគ្រាប់ធញ្ញជាតិ, ប្រេងចម្រាញ់ពីរុក្ខជាតិ ។

# ប្រភពវីតាមីន







***ចំណាំ:*** *ការថែរក្សាវត្ថុធាតុដើមសម្រាប់ផ្សំចំណីមិនល្អ ដូចជាការទុកយូរថ្ងៃពេក ឬត្រូវថ្ងៃ នឹងបណ្តាលឱ្យបាត់បង់វីតាមីនយ៉ាងឆាប់រហ័ស ។*

*ជាទូទៅសត្វត្រូវការវីតាមីនបន្ថែមប្រចាំថ្ងៃ ជាពិសេសជ្រូក ។*

## ខ- សារធាតុរ៉ែ

- **កាល់ស្យូម (Ca)**

■ កាល់ស្យូម គឺជាសារធាតុរ៉ែចាំបាច់សម្រាប់ការលូតលាស់ឆ្អឹង និង ស៊ុត និង ជំរុញការលូតលាស់។

■ ប្រភពកាល់ស្យូម គឺបានមកពីម្សៅសំបកខ្យង ខ្ចៅ... ដែលស្ងួត។

■ នៅកំឡុងពេលបំបៅកូន មេគោ និងមេជ្រូក ត្រូវការសារធាតុកាល់ស្យូមយ៉ាងច្រើនដើម្បីផលិតជាទឹកដោះ ។ ដូចនេះគេចាំបាច់ត្រូវចាក់បន្ថែមនូវកាល់ស្យូមគ្លុយកូណាត (Calcium gluconate) ដល់សត្វដូចខាងក្រោម :

- មេគោ ១ក្បាល ត្រូវចាក់ ២៥០ម.ល
- មេជ្រូក ១ក្បាល ត្រូវចាក់ ១០០ម.ល។



ដើម្បីផលិតទឹកដោះមេគោត្រូវការសារធាតុកាល់ស្យូមជាច្រើន

- **ផូស្វ័រ (P)**

  - ផូស្វ័រ ជាសារធាតុចាំបាច់ ជួយឱ្យបង្កើតឆ្អឹង ស៊ុត និងជំរុញការលូតលាស់
  - ដើម្បីជួយឱ្យមានការលូតលាស់បានល្អចាំបាច់ត្រូវផ្តល់ ម្សៅដេសេប៉េ (DCP) (ឌីកាល់ស្យូមផូស្វាត : Di Calcium Phosphate) ដល់សត្វ ។ កម្រិតប្រើគឺពី ១០-២០ ក្រាម ក្នុងមួយថ្ងៃ សម្រាប់មេជ្រូកបំបៅកូន និងជ្រូកកំពុងលូតលាស់ ។

**ត្រូវប្រុងប្រយត្ន័** : មិនត្រូវប្រើជីផូស្វាតសម្រាប់ដាក់ស្រែ យកមកលាយជាមួយចំណីសត្វឡើយ ព្រោះវាមានជាតិពុល ដូចជា ហ្លុយអ័រ (Fluor) ដែលប៉ះពាល់ដល់សុខភាពសត្វ ។



ម្សៅដេសេប៉េ (DCP)
ផ្តល់កាល់ស្យូម និងផូស្វ័រដល់មេជ្រូក

- **ជាតិដែក** (Fe)

  - កូនជ្រូកទាំងអស់ ត្រូវចាក់ជាតិដែក នៅថ្ងៃទី ២ បន្ទាប់ពីកើត និង ត្រូវចាក់ម្តងទៀតនៅ ១០ថ្ងៃក្រោយ
  - ជាតិដែក ជួយការពារកូនជ្រូកកុំឱ្យស្លេកស្លាំង និងខ្សោយ ។

**ឈ្មោះឱសថ** : ហ្វែរីដិច (Ferridex), ដិចប្រ៊ុល ២០០ (Dexprol 200), ហ្វែរ៉ូ ២០០០ (Ferro 2000)...

យកល្អគេត្រូវចាក់ជាតិដែក (Iron Dextran) ដល់កូនជ្រូកទាំងអស់



## គ- ប្រេមិច

- ក្នុងប្រេមិច (Premix) មានសារធាតុរ៉ែ និងវីតាមីនគ្រប់មុខ ដែលចាំបាច់សម្រាប់ការលូតលាស់ ការបន្តពូជ និងធ្វើឱ្យសត្វមានសុខភាពល្អ ។
- តម្រូវការប្រេមិចប្រែប្រួលទៅតាមប្រភេទសត្វ ដូចជា: មេជ្រូក ជ្រូកសាច់ គោ មាន់ ។ ដូច្នេះគេចាំបាច់ត្រូវទិញប្រេមិចឱ្យត្រូវទៅតាមតម្រូវការរបស់ប្រភេទសត្វ ។
- គេត្រូវលាយប្រេមិច ជាមួយចំណីឱ្យសត្វស៊ីរៀងរាល់ថ្ងៃ ។ តម្លៃរបស់ប្រេមិចសមរម្យ និងជួយឱ្យសត្វលូតលាស់បានល្អ។ ឧទាហរណ៍ បើយើងលាយប្រេមិចឱ្យជ្រូកសាច់រៀងរាល់ថ្ងៃ យើងចំណាយប្រហែលតែ ១,៥០០ រៀលក្នុងជ្រូក ១ក្បាលក្នុងរយៈពេល ១ខែ។



នៅពេលផ្សំចំណីដោយខ្លួនឯង កសិករត្រូវលាយបន្ថែមប្រេមិចទៅក្នុងចំណី

## ១.២.២. អង់ទីប៊ីយ៉ូទិក

អង់ទីប៊ីយ៉ូទិក ជាឱសថមានប្រសិទ្ធភាពសម្រាប់ព្យាបាលជំងឺសត្វដែលបង្កឡើងដោយពួកបាក់តេរី ។ អង់ទីប៊ីយ៉ូទិកនឹងត្រូវបង្ហាញនៅចំណុចក្រោយ ។

## ១.២.៣. ឱសថប្រឆាំងបរាសិត

**ក- បរាសិតខាងក្រៅ**

- **ដង្កែ :** ដង្កែជញ្ជក់ឈាម និងធ្វើឱ្យសត្វចុះខ្សោយ បង្កឱ្យរបួសស្បែក និង អាចចម្លងជំងឺដល់សត្វ ។

- **រុយ/ចៃ :** ប្រសិនបើមានរុយច្រើន (២០០ ក្បាល) ទុំលើខ្លួនសត្វ នោះវានាំឱ្យរំខានដល់សត្វ និង ធ្វើឱ្យសត្វនៅមិនសុខ/មិនស្ងៀម ។





**ដង្កែ** **រុយ/ចៃ**

- **ឱសថប្រឆាំងបរាសិតរួមមាន៖**

  - **អ៊ីវើមិចទីន ១ %** (Ivermectine 1%) **៖** មានប្រសិទ្ធភាពកម្ចាត់ដង្កែ។ កម្រិតប្រើ៖

    - គោ ៖ ១ ម.ល ក្នុងទម្ងន់ ៥០ គ.ក្រ
    - ជ្រូក ៖ ១ ម.ល ក្នុងទម្ងន់ ៣០ គ.ក្រ

  - **ប៊ុយតុក** (Butox) ៖ មានប្រសិទ្ធភាពកម្ចាត់បានទាំងចៃ និង រុយ។ គេប្រើដោយបាញ់នៅលើខ្លួនសត្វ ។ កម្រិតលាយគឺ ២,៥ សេសេ លាយជាមួយទឹក ៥ លីត្រ ឬ ១ សេសេ ទឹក ២លីត្រ។

**ខ- បរាសិតខាងក្នុង**

បរាសិតខាងក្នុងសំខាន់ៗ គឺមាននៅក្នុងពោះវៀន និង ថ្លើម។ ឱសថសម្រាប់ព្យាបាលដែលពេញនិយមនោះរួមមាន៖

- **អ៊ីវើមិចទីន ១ %** (Ivermectine 1%) **៖** កម្រិតប្រើ៖

  - គោ ៖ ១ ម.ល ក្នុងទម្ងន់ ៥០ គ.ក្រ
  - ជ្រូក ៖ ១ ម.ល ក្នុងទម្ងន់ ៣០ គ.ក្រ

***ចំណាំ ៖ អ៊ីវើមិចទីន ១ %*** *ពុំមានប្រសិទ្ធភាពប្រឆាំងនឹងដង្កូវថ្លើមទេ។*

- អាល់បង់ដាស៊ូល (Albendazole) ៖ មានប្រសិទ្ធភាពប្រឆាំងគ្រប់ព្រូន និង ដង្កូវថ្លើម។ គេប្រើដោយបញ្ជូកតាមមាត់ និងត្រូវប្រើក្នុងកម្រិត ៖ ១០ម.ល សម្រាប់ទម្ងន់ ១០០ គ.ក្រ។



ព្រូនអាស្ការីស (Ascaris)

រស់នៅក្នុងពោះវៀន

## គ- បរាសិតក្នុងឈាម

បរាសិតក្នុងឈាមដែលបង្កបញ្ហាលើគោរួមមាន ៖ បាបេស្យា (Babesia) និង ទ្រីប៉ាណូសូម៉ា (Trypanosoma)។ ភ្នាក់ងារចម្លងជំងឺគឺមាន ដង្កែ ឬមូស ។ ថ្នាំសម្រាប់ព្យាបាលគឺ បេរេនីល (**Berenil**)។



គោដែលមានបរាសិតក្នុងឈាម ៖ ពពួកទ្រីប៉ាណូសូម៉ា (Trypanosoma) មានរោគសញ្ញា ស្គម រាក កម្តៅខ្ពស់ និងមានហូរទឹកភ្នែក

### ១.២.៤. ឱសថប្រឆាំងនឹងការរលាក

ឱសថដែលប្រឆាំងនឹងការរលាក ត្រូវបានគេប្រើប្រាស់នៅពេលមានបញ្ហា ៖

- **ការរលាក ៖** ដូចជារលាកសន្លាក់ ដែលមានសភាពក្តៅ ហើម និងឈឺចាប់ ។
- **គ្រុនក្តៅខ្លាំង ៖** ដូចជាក្នុងករណីជំងឺប៉េស្តជ្រូក (CSF) ។
- **ការឈឺចាប់ ៖** ដូចជាពេលមានបញ្ហាឈឺជើង ។

***ឱសថប្រឆាំងនឹងការរលាកអាចបង្កឱ្យដំបៅក្រពះ ដូចនេះត្រូវប្រើក្នុងរយៈពេលខ្លី ។ ឱសថទាំងនេះមានដូចជា ៖***

- ដិចសាមេតាសូន (Dexamethazone) ៖ ឱសថនេះមានប្រសិទ្ធភាពបាន ២៤ ម៉ោង តែគ្មានប្រសិទ្ធភាពបញ្ចុះកម្តៅទេ ហើយក៏មិនអាចប្រើទៅលើសត្វជើមបានដែរ ។
- ប៉ារ៉ាសេតាម៉ុល (Paracetamol) ៖ មានប្រសិទ្ធភាពបាន ៦ ម៉ោង ។
- តុលហ្វេឌីន (Tolfedine) ៖ មានប្រសិទ្ធភាពបាន ៤៨ ម៉ោង ។



ការហើម និង ឈឺចាប់នៅជើង ជាសញ្ញាបង្ហាញពីការរលាកសន្លាក់

## ១.២.៥. អរ័ម៉ូន

- អុកស៊ីតុកស៊ីន (Ocytocin) : ជួយឱ្យស្បូនកន្ត្រាក់ ប្រើក្នុងកំឡុងពេលកើតកូន (ក្រោយពេលបែកទឹកភ្លោះ) និងជួយបញ្ចេញទឹកដោះ ។
- ប្រូស្តាគ្លង់ឌីន (Prostaglandin) : ជួយឱ្យស្បូនកន្ត្រាក់ ប្រើនៅពេលមានបញ្ហារលាកស្បូន ហើយអាចបំផ្លាញគីស្ត (Cysts) នៅក្នុងអូវែ ។
- អឺស្ត្រាឌីយ៉ូល (Oestradiol) : ប្រើសម្រាប់ជំរុញឱ្យមេជ្រូករកឈ្មោល ។



អុកស៊ីតុកស៊ីនជាឱសថ ជំនួយការកន្ត្រាក់ស្បូនបញ្ចេញកូនមកក្រៅ

## ១.២.៦. វ៉ាក់សាំង




វ៉ាក់សាំងមានប្រសិទ្ធភាពការពារជំងឺ ប៉ុន្តែមិនមែនសម្រាប់ព្យាបាលជម្ងឺទេ :

- វ៉ាក់សាំងមានសារៈសំខាន់សម្រាប់ការពារជំងឺដែលបង្កឡើងដោយ**វីរុស** ព្រោះអង់ទីប៊ីយ៉ូទិកមិនអាចកម្ចាត់វីរុសបានទេ ។
- *វ៉ាក់សាំងមួយមុខការពារជំងឺបានតែមួយប្រភេទតែប៉ុណ្ណោះ ។*
- ការប្រើប្រាស់វ៉ាក់សាំងគឺចាំបាច់ត្រូវគោរពទៅតាមកម្មវិធី និង ការណែនាំរបស់រោងចក្រផលិតផ្ទាល់ ។

## ២. ការបង្ហាញពីប្រភេទឱសថ

### ២.១. ការបង្ហាញពីប្រភេទឱសថ

ទម្រង់របស់ឱសថមានច្រើនប្រភេទ ដូចជា :

- ប្រភេទម្សៅ
- ប្រភេទទឹក/សូលុយស្យុង
- ប្រភេទគ្រាប់
- ប្រភេទថ្នាំចាក់
- ប្រភេទស្រោយ/ក្រែមលាបខាងក្រៅ ។

### ២.២. ប្រភេទឱសថសម្រាប់ចាក់

**ក- ប្រភេទផលិតជាទឹក**

ប្រភេទចំណុះឱសថដែលគេនិយមប្រើប្រាស់រួមមានៈ

- ដបចំណុះ ២៥០ មីលីលីត្រ, ១០០ មីលីលីត្រ, ៥០ មីលីលីត្រ និង ២០ មីលីលីត្រ ។
- វាងាយស្រួលប្រើ ហើយថ្នាំដែលមាននៅក្នុងដបអាចប្រើបានច្រើនដង ឬច្រើនខែ ។

**ខ- ប្រភេទដែលត្រូវរៀបចំ**

- ប្រភេទម្សៅៈ ចាំបាច់ត្រូវលាយជាមួយទឹក មុនពេលយកទៅចាក់លើសត្វ
- ការរៀបចំវាមិនសូវងាយស្រួលពេកទេ
- ការរក្សាទុកក្រោយពេលលាយរួចមានកំណត់ :
    - វ៉ាក់សាំងរក្សាទុកបានតែ ២-៣ ម៉ោង
    - បេរេនីល (Berenil) រក្សាបាន ៧ ថ្ងៃ ។

## ២-ការបង្ហាញពីប្រភេទឱសថ

### ២-១- ការបង្ហាញពីប្រភេទឱសថ

ទម្រង់របស់ឱសថមានច្រើនប្រភេទ ដូចជា :

- ប្រភេទម្សៅ
- ប្រភេទទឹក/សូលុយស្យុង
- ប្រភេទគ្រាប់
- ប្រភេទថ្នាំចាក់
- ប្រភេទស្រ្គាយ/ក្រែមលាបខាងក្រៅ ។

### ២-២- ប្រភេទឱសថសម្រាប់ចាក់

**ក- ប្រភេទផលិតជាទឹក**

ប្រភេទចំណុះឱសថដែលគេនិយមប្រើប្រាស់រួមមាន:

- ដបចំណុះ ២៥០ មីលីលីត្រ, ១០០ មីលីលីត្រ, ៥០ មីលីលីត្រ និង ២០ មីលីលីត្រ ។
- វាងាយស្រួលប្រើ ហើយថ្នាំដែលមាននៅក្នុងដបអាចប្រើបានច្រើនដង ឬច្រើនខែ ។

**ខ- ប្រភេទដែលត្រូវរៀបចំ**

- ប្រភេទម្សៅ: ចាំបាច់ត្រូវលាយជាមួយទឹក មុនពេលយកទៅចាក់លើសត្វ
- ការរៀបចំវាមិនសូវងាយស្រួលពេកទេ
- ការរក្សាទុកក្រោយពេលលាយរួចមានកំណត់ :
  - វ៉ាក់សាំងរក្សាទុកបានតែ ២-៣ ម៉ោង
  - បេរេនីល (Berenil) រក្សាបាន ៧ ថ្ងៃ ។




ឱសថសម្រាប់ចាក់មានប្រភេទផ្សេងៗគ្នា

## ២.៣. ប្រភេទម្សៅបញ្ចូកតាមមាត់

- ឱសថប្រភេទនេះភាគច្រើនប្រើសម្រាប់ព្យាបាលសត្វចំនួនច្រើន (ជាហ្វូង)
- ច្រើនប្រើលើជ្រូក បក្សី និងត្រី
- ប្រភេទថង់ថ្នាំដែលមានទម្ងន់ពី ១០០ ក្រាម រហូតដល់ ២៥ គ.ក្រ
- វាងាយស្រួលប្រើ ប្រសិនបើសត្វនៅស៊ីចំណី តែករណីសត្វមិនស៊ីចំណីគេមិនប្រើឱសថប្រភេទជាម្សៅនេះទេ
- ថ្នាំប្រភេទម្សៅមានប្រយោជន៍សម្រាប់ប្រើជាការការពារ ។

## ២.៤. ប្រភេទរាវ/ទឹក

ថ្នាំប្រឆាំងបរាសិត ភាគច្រើនជាប្រភេទរាវ/ទឹក :

- ថ្នាំទាំងនេះត្រូវប្រើបញ្ចូកតាមមាត់ដោយបង្ខំ ហើយចាំបាច់ត្រូវចាប់សត្វឱ្យជាប់ និងនៅនឹងល្អ
- វាងាយខាតបង់ដោយសារសត្វមិនផឹក ឬព្រួសចេញ
- វានឹងគ្រោះថ្នាក់ ប្រសិនបើបញ្ចូកចូលបំពង់ខ្យល់ ។




ឱសថប្រឆាំងបារាសិតគោ

## ២.៥. ប្រភេទគ្រាប់ធំ និង តូច

- ថ្នាំប្រភេទគ្រាប់ គេនិយមប្រើលើឆ្កែ និងឆ្មា ហើយគេកម្រប្រើលើជ្រូក និងគោណាស់
- កសិករខ្លះប្រើថ្នាំគ្រាប់ ជាពិសេសគឺយកថ្នាំសម្រាប់មនុស្សមកប្រើលើសត្វ
- ថ្នាំគ្រាប់ធំ (Bolus) ត្រូវបានគេប្រើ ដើម្បីសុលចូលក្នុងស្បូនដោយផ្ទាល់តែម្តង ជាពិសេសក្រោយពេលមេកើតកូនរួចភ្លាម ។



## ២.៦. ប្រភេទបន្តក់តាមភ្នែក

ឱសថសម្រាប់ព្យាបាលភ្នែកត្រូវបានគេប្រើនៅពេលសត្វមានបញ្ហារលាកកែវភ្នែក ឬ ស្លាកស្នាមកែវភ្នែក។ ការព្យាបាលជម្ងឺភ្នែកទាមទារចាំបាច់នូវការចាប់សត្វឱ្យជាប់ និង ត្រូវ



បន្តក់ ៥ដង ក្នុងមួយថ្ងៃ ទើបវាមានប្រសិទ្ធភាព។ ការថែរក្សាទុកត្រូវមានពេលកំណត់គឺអាចប្រមាណជា ១ សប្តាហ៍។ ដោយឡែកវ៉ាក់សាំងសម្រាប់មាន់ ជាញឹកញាប់គេលាយជាមួយទឹកពណ៌ខៀវដើម្បីងាយពិនិត្យមើលការបន្តក់ឱ្យបានត្រឹមត្រូវ។

## ២.៧. ប្រភេទស្រោចពីលើសត្វ

- ថ្នាំស្រោចពីលើខ្លួនសត្វ គឺជាថ្នាំសម្រាប់សម្លាប់ពួកបរាសិត
- គេប្រើកែវសម្រាប់ស្រោច ហើយប្រើថ្នាំបរិមាណតិចតួច ដោយស្រោចលើខ្នងគោ
- ក្រោយស្រោចរួចថ្នាំជ្រាបចូលតាមស្បែក
- ថ្នាំប្រភេទនេះងាយស្រួលប្រើ ព្រោះគ្មានការឈឺចាប់ និង មិនចាំបាច់ចាប់សត្វខ្លាំងឡើយ ប៉ុន្តែនៅពេលអាកាសធាតុក្តៅ វាអាចបង្កឱ្យមានការរលាក/ក្រហាយ
- ប្រសិនបើស្បែកមានសភាពមិនល្អ (កខ្វក់) ធ្វើឱ្យប្រសិទ្ធភាពរបស់ថ្នាំមានកម្រិតទាប។




*ប្រភេទអុីវើម៉ិចសម្រាប់ប្រើស្រោចពីលើសត្វ* (Ivermec Pour-on)

## ២.៨. ប្រភេទក្រែម និងស្ព្រាយ

គេប្រើប្រាស់ឱសថប្រភេទក្រែម និង ស្ព្រាយ សម្រាប់ព្យាបាលដោយកន្លែង ជាពិសេស សម្រាប់ស្បែករបួស។ ប្រភេទក្រែមមានការលំបាកលាបនៅលើស្បែក ព្រោះដោយសារមាន រោម ឬ ដោយសារដំបៅសើម ប៉ុន្តែវាងាយស្រួលប្រើ ហើយ កសិករអាចរៀបចំដោយខ្លួនឯង ដោយលាយជាមួយប្រេងវ៉ាស៊ីលនី (Vaseline)។ ប្រភេទថ្នាំស្ព្រាយងាយស្រួលប្រើ ប៉ុន្តែ ជួនកាលធ្វើឱ្យសត្វភ័យខ្លាច ឬផ្អើល ។ ដូចនេះមុនពេលប្រើថ្នាំ ប្រភេទក្រែម ឬ ស្ព្រាយ គេចាំបាច់ត្រូវសម្អាតស្បែកជាមួយ នឹងទឹក ឬសាប៊ូ ហើយប្រសិនបើអាចត្រូវកាត់រោមចេញ។



# ៣. ការប្រើប្រាស់បសុឱសថ

## ៣.១. ការប្រើប្រាស់បសុឱសថ

ប្រសិទ្ធភាពរបស់ឱសថមានទំនាក់ទំនងយ៉ាងជិតស្និទជាមួយនឹងភាពត្រឹមត្រូវនៃការប្រើប្រាស់ឱសថ។ ភ្នាក់ងារសុខភាពសត្វភូមិត្រូវគោរពទៅតាមការណែនាំរបស់រោងចក្រផលិតឱ្យបានខ្ជាប់ខ្ជួន។ ការណែនាំទាំងនេះមានពន្យល់យ៉ាងច្បាស់លាស់នៅលើស្លាកដបថ្នាំ។ ចំណុចសំខាន់ ៣ យ៉ាង ដែលត្រូវចងចាំក្នុងពេលប្រើប្រាស់ឱសថ រួមមាន :

- **កម្រិតប្រើប្រាស់ :** គឺជាបរិមាណឱសថដែលត្រូវផ្តល់
- **ផ្លូវបញ្ចូលឱសថ :** គឺជាវិធីសាស្ត្រក្នុងការផ្តល់ឱសថ
- **ពេលវេលា/ចន្លោះពេលប្រើប្រាស់ :** ពេលវេលា និង រយៈពេលប្រើប្រាស់ឱសថ។

## ៣.២. ការអានស្លាកថ្នាំ

រាល់ការណែនាំត្រូវបានគេសរសេរបង្ហាញច្បាស់លាស់នៅលើស្លាកដបថ្នាំ តែៈ

- ស្លាកដបថ្នាំខ្លះសរសេរជាភាសាអង់គ្លេស បារាំង វៀតណាម......
- អ្នកផលិតខ្លះសរសេរអក្សរទំហំតូចពេក
- ខ្លះទៀតមានការណែនាំច្រើនពេក

វាមិនសូវងាយស្រួលទេ ក្នុងការអានស្លាកដបថ្នាំ និង គោរពតាមអ្វីដែលអ្នកផលិតបានណែនាំ។ ដូចនេះភ្នាក់ងារសុខភាពសត្វភូមិ ត្រូវសាកសួរព័ត៌មានបន្ថែមពីអ្នកលក់ ដូចជា : កម្រិតប្រើ ផ្លូវបញ្ចូល កាលបរិច្ឆេទប្រើប្រាស់...) ។




ស្លាកដបថ្នាំសរសេរជាភាសា អង់គ្លេស និង មានទំហំអក្សរតូចពេក

## ៣.៣. ការធ្វើឱ្យថ្នាំរលាយស្មើសាច់

ដើម្បីធ្វើឱ្យថ្នាំរលាយស្មើសាច់ គេចាំបាច់ត្រូវតែក្រឡុកដបថ្នាំឱ្យបានច្រើនដងទើបថ្នាំទាំងនេះរលាយស្មើសាច់បានល្អ ។



ការក្រឡុកដប



ដបថ្នាំមុន និងក្រោយពីក្រឡុក

## ៣.៤. កម្រិតប្រើប្រាស់

### ក- <u>កម្រិតប្រើប្រាស់ថ្នាំអាស្រ័យទៅលើទម្ងន់សត្វ</u>

កម្រិតប្រើប្រាស់ថ្នាំគឺពិតជាមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការព្យាបាលសត្វ។ នៅពេលអ្នកប្រើប្រាស់ថ្នាំត្រូវកម្រិត នោះការព្យាបាលទទួលបានលទ្ធផលជោគជ័យ ផ្ទុយទៅវិញប្រសិនបើអ្នកប្រើថ្នាំមិនត្រូវកម្រិតទេ នោះបណ្តាលឱ្យការព្យាបាលទទួលនូវបរាជ័យ និងខាតបង់លុយកាក់ជាច្រើន ។ ជាញឹកញយណាស់ គេធ្វើការប៉ាន់ប្រមាណទម្ងន់សត្វក្មេង ឬតូចលើសទម្ងន់ពិតរបស់ពួកវា ។



មេជ្រូកអាយុ ២ ឆ្នាំ និងមានទម្ងន់ ប្រហែល ២៥០ គ.ក្រ តែភ្នាក់ងារ សុខភាពសត្វភូមិ ប្រើកម្រិតថ្នាំចាក់ សម្រាប់ជ្រូកទម្ងន់ ១០០ គ.ក្រ ទេវិញ

## ខ- កម្រិតប្រើប្រាស់ថ្នាំអាស្រ័យទៅលើកត្តាផ្សេងទៀត

ក្រៅពីកត្តាទម្ងន់ កម្រិតប្រើប្រាស់ថ្នាំទៅលើសត្វ ក៏អាស្រ័យទៅលើកត្តាផ្សេងៗមួយចំនួន ដូចជា :

- កម្រិតប្រើប្រាស់អាចអាស្រ័យទៅលើអាយុ (**សត្វក្មេងខ្លាំង កម្រិតប្រើ ២ ដង លើសកម្រិតធម្មតា**) ដូចជាកូនជ្រូកអាយុ ១ ថ្ងៃ គេចាក់ឡុងអាម៉ុក 0,៥ សេសេ ដែលកម្រិតនេះស្មើនឹងជ្រូកទម្ងន់ ៥ គ.ក្រ ។
- ក្នុងករណីមាន**ជម្ងឺផ្លូវដង្ហើមធ្ងន់ធ្ងរ** នៅថ្ងៃទី ១ គេចាក់កម្រិត ២ ដង លើសកម្រិតធម្មតា ។
- **កម្រិតប្រើអាស្រ័យទៅនឹងប្រភេទជំងឺ** ដូចជា ថ្នាំបេរេនីល (Berenil) ត្រូវប្រើកម្រិតធម្មតា សម្រាប់ព្យាបាល**បាបេស្យា** (Babesia) ប៉ុន្តែ កម្រិតនេះនឹងទ្វេដងសម្រាប់ព្យាបាល **ទ្រីប៉ាណូសូមា** (Trypanosoma) ។



ពេលជ្រូកមានបញ្ហាមិនស៊ីចំណី កម្តៅឡើង ហួរសំបោរ និង ក្អកខ្លាំង នៅថ្ងៃដំបូង គេត្រូវប្រើអង់ទីប៊ីយ៉ូទិក ក្នុងកម្រិត ២ ដងលើសធម្មតា

## ៣.៥. ពេលវេលាប្រើប្រាស់

### ក- ចន្លោះពេលប្រើប្រាស់

បន្ទាប់ពីចាក់រួច ឱសថខ្លះមានសកម្មភាពក្នុងខ្លួនសត្វពី ២-៣ នាទី ខ្លះរហូតដល់យូរថ្ងៃ ៖

- ២-៣ នាទី ៖ អុកស៊ីតុកស៊ីន (Ocytocine) ...
- ១ ម៉ោង ៖ កាល់ម៉ាហ្ស៊ីន (Calmagine), អាណាល់ហ្សាំង (Analgine) ....
- ១២ ម៉ោង ៖ អំពីដិចសាឡោន (Ampidexalone), ប៊ីយ៉ូកូលីស្ទីន (Biocolistine)...
- ១ ថ្ងៃ ៖ សិបតូទ្រីល (Septotryl), ហ្វ្រេីគរ័ទីល (Frecortyl) ....
- ២ ថ្ងៃ ៖ តុលហ្វេឌីន (Tolfedine), ឡុងហ្គាមុក (Longamox) ....
- ៣ ថ្ងៃ ៖ រីម៉ាស៊ីគ្លីន (Remacycline), ឡុងជីស៊ីន (Longicine) ....
- > ៧ ថ្ងៃ ៖ អាយរ៉ូនដិចស្ត្រាន (Iron Dextran) ....



ការចាក់ជាតិដែកឱ្យកូនជ្រូក ដើម្បីការពារភាពស្លេកស្លាំង មានប្រសិទ្ធភាពយ៉ាងតិច ៧ ថ្ងៃ !

## ខ- ឧទាហរណ៍លើពេលវេលាដ៏ល្អក្នុងការប្រើប្រាស់ឱសថ

- អុកស៊ីតុកស៊ីន (Ocytocine) : ការចាក់លើកទី ២ **ធ្វើឡើងនៅ ៣០ នាទី** ក្រោយពីចាក់លើកទី ១
- អំពីដិចសាឡោន (Ampidexalone) : ត្រូវចាក់នៅ **ពេលព្រឹកម្តង និង ពេលល្ងាចម្តង**
- សិបតូទ្រីល (Septotryl) : ចាក់**មួយថ្ងៃម្តង**
- រីម៉ាស៊ីគ្លីន (Remacycline) : អាចត្រូវបានគេ **ចាក់រៀងរាល់ ៣ ថ្ងៃម្តង**
- អាយរូនដិចស្ត្រាន (Iron Dextran) : អាចត្រូវបានគេចាក់ម្តងទៀតនៅ**មួយអាទិត្យក្រោយ** ។



អុកស៊ីតុកស៊ីនមានសកម្មភាពភ្លាមៗ ហើយបានតែ ២-៣ នាទី ប៉ុណ្ណោះ

គ- <u>**រយៈពេលប្រើប្រាស់**</u>

- ឱសថខ្លះអាចប្រើប្រាស់ **យ៉ាងតិច ៥ថ្ងៃ** ដូចជា អង់ទីប៊ីយ៉ូទិក
- ឱសថខ្លះអាចប្រើប្រាស់បានយូរអាស្រ័យទៅតាមរោគសញ្ញាដែលលេចឡើង ដូចជាអង់ទីប៊ីយ៉ូទិកប្រើសម្រាប់ព្យាបាលករណីរាកកូនជ្រូកក្នុងកំឡុងពេលបៅដោះ
- ឱសថខ្លះត្រូវបានគេប្រើប្រាស់តែមួយដង ប៉ុន្តែ**ទៀតទាត់** ដើម្បីជាការការពារជំងឺផ្សេងៗ ដូចជា : វ៉ាក់សាំង ឬ ថ្នាំប្រឆាំងបរាសិត។

ពេលកូនជ្រូកមានបញ្ហារាក គេត្រូវធ្វើការព្យាបាល ១ ថ្ងៃ ២ ដង ដោយចាក់រហូតដល់វាឈប់រាក



## ៣.៥. ផ្លូវបញ្ចូលឱសថ

ផ្លូវបញ្ចូលឱសថ គឺពិតជាមានសារៈសំខាន់យ៉ាងខ្លាំងនៅក្នុងការព្យាបាលសត្វ ព្រោះប្រសិនបើភ្នាក់ងារសុខភាពសត្វភូមិជ្រើសរើសផ្លូវបញ្ចូលខុស នោះបណ្ដាលឱ្យការព្យាបាលទទួលបរាជ័យ និង ខាតបង់ថវិការជាច្រើន។ ដើម្បីប្រើប្រាស់ផ្លូវបញ្ចូលឱសថឱ្យបានត្រឹមត្រូវភ្នាក់ងារសុខភាពសត្វភូមិត្រូវគោរពទៅតាមការណែនាំ ដែលមាននៅលើស្លាកដបថ្នាំ។ ផ្លូវបញ្ចូលឱសថសំខាន់ៗមាន :

- **ផ្ដល់តាមមាត់ :** លាយជាមួយចំណី ទឹក ឬ បញ្ជ្រកដោយផ្ទាល់
- **ដោយចាក់ :** ចាក់ក្នុងសាច់ដុំ (IM) ចាក់ក្រោមស្បែក (SC) ឬចាក់ក្នុងសរសៃវ៉ែន (IV)
- **ព្យាបាលតាមផ្នែកក្រៅ :** ការលាបលើស្បែក ឬបន្តក់ដាក់ភ្នែក
- **សុលតាមស្បូន :** ឱសថប្រភេទនេះ ត្រូវបានគេសុលចូលតាមស្បូនដោយផ្ទាល់។

### ក- ផ្លូវបញ្ចូលតាមមាត់

មានប្រភេទឱសថជាច្រើន ត្រូវបានគេផ្ដល់តាមមាត់ :

- **ទម្រង់រាវ :** ត្រូវប្រើដប ឬស៊ីរ៉ាំង ហើយត្រូវចាប់សត្វឱ្យជាប់ល្អ ដើម្បីឱ្យសត្វទទួលកម្រិតថ្នាំបានគ្រប់គ្រាន់ (ជានិច្ចកាលវាតែងមានការខាតបង់ ដោយសារសត្វខ្ជាក់ចេញ)
- **ទម្រង់ជាម្សៅ :** យកល្អត្រូវលាយជាមួយចំណី ហើយដើម្បីឱ្យសត្វទទួលកម្រិតថ្នាំបានគ្រប់គ្រាន់ លុះត្រាតែសត្វស៊ីចំណីធម្មតា។





ការព្យាបាលដោយប្រើស៊ីរ៉ាំងផ្តល់ឱសថតាមមាត់ និងការបាញ់បញ្ចូលឱសថតាមមាត់

## ខ- ផ្លូវបញ្ចូលដោយចាក់

បច្ចេកទេសនៃការចាក់ថ្នាំទៅលើសត្វ មានលក្ខណៈខុសគ្នារវាងគោ ជ្រូក និង បក្សី។ ម្យ៉ាងវិញទៀត ការចាក់ត្រូវបានគេប្រើសម្រាប់ការបូមយកឈាម ដើម្បីជាការជំនួយក្នុងការធ្វើតេស្តឈាមរកប្រភេទមេរោគបង្កជំងឺផងដែរ ។ ការចាក់អាចត្រូវបានគេធ្វើឡើងតាម :

- ក្រោមស្បែក
- ក្នុងសាច់ដុំ
- ក្នុងសរសៃវ៉ែន
- ក្នុងពោះ



ការចាក់ថ្នាំចូលតាមសាច់ដុំកូនជ្រូក



ការចាក់ក្រោមស្បែកសម្រាប់មេជ្រូក
(ដោយប្រើអ៊ីវើម៉ិចទីន)



ការចាក់ក្រោមស្បែក (គោ)

## គ- ផ្លូវបញ្ចូលក្នុងស្បូន

វិធីសាស្ត្រនេះមានប្រសិទ្ធភាពណាស់ ព្រោះថ្នាំអង់ទីប៊ីយ៉ូទិកត្រូវបានដាក់ចូលផ្ទាល់ទៅក្នុងស្បូនបន្ទាប់ពីសត្វកើតកូនរួច ប៉ុន្តែការបញ្ចូលថ្នាំតាមស្បូននេះធ្វើបានតែនៅពេលស្បូននៅបើកប៉ុណ្ណោះ ហើយដោយយូរបំផុតក្រោយពេលកើត ២ ថ្ងៃ។ សំខាន់ត្រូវលាងសម្អាតដៃឱ្យស្អាតល្អ មុនបញ្ចូលថ្នាំទៅក្នុងស្បូន ហើយលូកដាក់ថ្នាំដោយសន្សឹមៗ ។



កាន់គ្រាប់ថ្នាំក្នុងដៃ រួចលូកចូលផុតកស្បូន ហើយទម្លាក់ថ្នាំ

## ឃ- ការប្រើប្រាស់ឱសថផ្នែកខាងក្រៅខ្លួនសត្វ

- **ការបាញ់ (ស្ព្រាយ) :** ប្រើសម្រាប់ព្យាបាលបរាសិតខាងក្រៅ
- **ចាក់ស្រោចពីលើ :** ប្រើសម្រាប់ព្យាបាលបរាសិតខាងក្រៅ
- **ក្រែមលាប :** ជាញឹកញាប់ប្រើសម្រាប់ព្យាបាលរបួស
- **ការបន្តក់តាមភ្នែក :** ប្រើសម្រាប់ព្យាបាលបញ្ហារលាកកែវភ្នែក ឬ វ៉ាក់សាំង។



ការបាញ់ថ្នាំសម្លាប់សត្វល្អិតសម្រាប់គោ ១ ក្បាល ប្រើសូលុយស្យុងទឹក ៣ លីត្រ



ព្យាបាលភ្នែក ដោយប្រើថ្នាំបន្តក់ដាក់ភ្នែក

## ៣.៦. សំភារៈចាំបាច់

**ការចាក់ថ្នាំ** ត្រូវការចាំបាច់នូវម្ជុល និងស៊ីរ៉ាំងគ្រប់គ្រាន់ និងត្រឹមត្រូវ ៖

- **ចំណុះស៊ីរ៉ាំង** ត្រូវស៊ីគ្នានឹងបរិមាណថ្នាំដែលប្រើ ដូចជាគេមិនត្រូវប្រើស៊ីរ៉ាំង ២០ សេសេ ដើម្បីបូមចាក់ថ្នាំ ១ សេសេ នោះទេ



ភ្នាក់ងារសុខភាពសត្វភូមិត្រូវមាន ស៊ីរ៉ាំង ១០ សេសេ និង ២០ សេសេ

- **ប្រវែងម្ជុល**ត្រូវតែសមស្រប ជាពិសេសសម្រាប់ចាក់សាច់ដុំជ្រូក ព្រោះជ្រូកទម្ងន់ ២៥០ គីឡូក្រាម សាច់ដុំករបស់វាមានកម្រាស់ ខ្លាញ់លើស ៣០ មីលីម៉ែត្រ ដូចនេះត្រូវប្រើម្ជុល ប្រវែងយ៉ាងតិច ៤០ មីលីម៉ែត្រ
- **ទំហំម្ជុល** ត្រូវស៊ីគ្នាជាមួយនឹងថ្នាំដែលប្រើ ដូចជាថ្នាំមានសភាពជាប្រេង (ផលិតផលមានសកម្មភាពយូរ) មានសភាពខាប់អន្ទិល ហើយត្រូវចាក់ឱ្យបានលឿនក្នុងរយៈពេលខ្លី ។



សម្រាប់កូនជ្រូក មេជ្រូក និងគោ ត្រូវការប្រវែងម្ជុលសម្រាប់ចាក់ផ្សេងគ្នា

## ៤. ការប្រុងប្រយ័ត្ន

### ៤.១. ការលាយឱសថបញ្ចូលគ្នា

ការលាយឱសថបញ្ចូលគ្នានៅក្នុងស៊ីរ៉ាំងតែមួយ អាចធ្វើឱ្យងាយស្រួលក្នុងការព្យាបាល ប៉ុន្តែថ្នាំខ្លះមិនអាចលាយជាមួយគ្នាបានទេ ដូចជា :

- ថ្នាំដែលមានជាតិប្រេង មិនអាចលាយជាមួយថ្នាំដែលមានជាតិខុសគ្នាបានទេ ដូចជា វីតាមីន អាដេ៣អឺ ($AD_3E$) មិនអាចលាយជាមួយ ហ្វេរីដិច (Ferridex) បានទេ
- ថ្នាំដែលលាយជាមួយគ្នាបាន ត្រូវតែមានផ្លូវបញ្ចូលថ្នាំដូចគ្នា។ គេមិនអាចលាយថ្នាំដែលចាក់ក្រោមស្បែកជាមួយថ្នាំដែលចាក់តាមសាច់ដុំបានទេ ដូចជា អ៊ីវ៉ូមិច (Ivomec) ជាមួយអំពីដិចសាឡោន (Ampidexalone)
- ថ្នាំខ្លះមិនអាចបញ្ចូលគ្នាជាមួយថ្នាំផ្សេងទៀតបានទេ ដូចជា កូហ្វាកាល់ស្យូម (Cofa-calcium) មិនអាចលាយជាមួយសិបតូទ្រីល (Septotryl)
- ថ្នាំខ្លះប្រឆាំងគ្នា ហើយមិនអាចចាក់ក្នុងពេលតែមួយបានទេ ដូចជា រីម៉ាស៊ីគ្លីន (Rema-cycline) ជាមួយអំពីដិចសាឡោន (Ampidexalone)។



ត្រូវប្រុងប្រយ័ត្ននៅពេលប្រើថ្នាំច្រើនមុខ ព្រោះថ្នាំខ្លះមិនអាចចាក់ក្នុងពេលតែមួយបានទេ

ថ្នាំខ្លះមិនអាចលាយបញ្ចូលក្នុងសឺរ៉ាំងតែ
មួយបានទេ



## ៤.២. ការចម្លងជម្ងឺ

នៅពេលចាក់ថ្នាំសត្វ ម្ជុលបានចាក់ចូលទៅក្នុងស្បែក សាច់ដុំ និងសរសៃឈាម ហើយអាចឱ្យមេរោគឆ្លងចូលបានដោយងាយស្រួល។ ដូចនេះភ្នាក់ងារសុខភាពសត្វភូមិត្រូវតែប្រុងប្រយ័ត្ន នៅពេលព្យាបាលសត្វច្រើនដោយប្រើម្ជុលរួមគ្នា។ ប្រសិនបើភ្នាក់ងារសុខភាពសត្វភូមិប្រើប្រាស់ម្ជុលប្រលាក់/មិនស្អាត នោះវានឹងបណ្ដាលឱ្យមាន**អាប់សែ** និង **ជំងឺបៅរលួយ**។ ដូចនេះគេចាំបាច់ត្រូវលាងសម្អាត និងសម្លាប់មេរោគលើម្ជុល និង សឺរ៉ាំងជាប្រចាំ ជាពិសេសមុនពេលព្យាបាលសត្វ។



នៅពេលឃើញមានបួសក្រោយពេលចាក់ថ្នាំ ជាការបង្ហាញថាភ្នាក់ងារសុខភាពសត្វភូមិចាក់ថ្នាំមិនបានត្រឹមត្រូវ

## ៤.៣. ភាគសំណល់ឱសថ

សំណល់បសុឱសថ គឺជាបរិមាណតិចតួចរបស់**ថ្នាំដែលអាចមាននៅសល់ក្នុងផលិតផលសត្វ** ក្រោយពេលចាក់ ឬ ផ្តល់ឱ្យសត្វ ដូចជាមានក្នុងនៅសាច់ ស៊ុត ។ល។ គេអាចឃើញមាន **សំណល់ថ្នាំនៅក្នុងសាច់សត្វ** ដែលគេព្យាបាល ២-៣ ថ្ងៃ មុនពិឃាដសត្វ។ ជាទូទៅអ្នកផលិតឱសថបានណែនាំនៅលើស្លាកដបថ្នាំពី**រយៈពេលឱសថបាត់អស់ពីខ្លួនសត្វ** ។ រយៈពេលឱសថបាត់អស់ពីខ្លួនសត្វមានសារៈសំខាន់ណាស់ ព្រោះវាជារយៈពេលដែលត្រូវរងចាំក្រោយការព្យាបាលមុននឹងពិឃាដសត្វ ឬ ប្រើប្រាស់ផលិតផលរបស់វា ដូចជា សាច់ ស៊ុត ទឹកដោះជាដើម ។




ដើម្បីការពារសុខភាពមនុស្ស គេត្រូវគោរពទៅតាមការណែនាំ
ពីរយៈពេលដែលថ្នាំចេញអស់ពីខ្លួនសត្វ ជាពិសេសសម្រាប់សត្វពិឃាដ ឬយកទឹកដោះ

## ៤.៤. ផលវិបាកនៃការប្រើប្រាស់ឱសថ

ឱសថគឺជាសារធាតុសកម្ម ហើយពេលខ្លះវាបង្កផលវិបាកដល់សត្វ ប៉ុន្តែផលវិបាកទាំងនេះមិនបានកាត់បន្ថយប្រសិទ្ធភាពរបស់ថ្នាំទេ។ ផលវិបាករបស់ថ្នាំទាំងអស់ត្រូវបានគេបង្ហាញច្បាស់លាស់នៅលើស្លាកដបថ្នាំ ហើយចំពោះផលវិបាកសំខាន់ៗត្រូវបានគេពន្យល់ និង សសេរយ៉ាងលំអិតនៅលើដបថ្នាំ។ ផលវិបាកនៃការប្រើប្រាស់ថ្នាំអាចត្រូវបានកាត់បន្ថយ ប្រសិនបើភ្នាក់ងារសុខភាពសត្វភូមិគោរពទៅតាមក្បួនច្បាប់ត្រឹមត្រូវ ដែលបានណែនាំដោយអ្នកផលិត ដូចជាកម្រិតប្រើប្រាស់ ផ្លូវបញ្ចូល និងរយៈពេលប្រើប្រាស់ ។ល។



ក្រោយពេលចាក់ថ្នាំរួច កូនជ្រូកមានបញ្ហាអាឡែស៊ី (ស្បែកឡើងក្រហម)

## ក- ហ្សុក

ជាផលវិបាក ដែលភាគច្រើនកើតមាននៅក្រោយពេលចាក់ថ្នាំការពារ ។

**រោគសញ្ញា ៖**

- សត្វចាប់ផ្ដើមពិបាកដកដង្ហើម
- ហូរទឹកមាត់
- ស្បែកឡើងក្រហម
- ទន់ជើង និងស្ទះ/សន្លប់

**ព្យាបាល ៖**

- បាញ់ទឹកដាក់លើខ្លួន
- ចាក់ដិចសាមេតាសូន (Dexamethasone)

**ការពារ ៖** ពេលធ្វើវ៉ាក់សាំង ត្រូវចាក់នៅពេលព្រឹកព្រលឹម និង កុំទាន់ឱ្យចំណី ។




ការចាក់វ៉ាក់សាំងអូហ្យេស្គីត្រូវមានការប្រុងប្រយត្ន័ ព្រោះវាអាចធ្វើឱ្យសត្វហ្សុក

## ខ- កន្លែងចាក់ឡើងរឹង/ក្រិន

ការឡើងរឹង/ក្រិន ត្រង់កន្លែងចាក់អាចបណ្ដាលមកពីការចាក់ថ្នាំខុសទីតាំង។ ប៉ុន្តែថ្នាំខ្លះអាចធ្វើឱ្យក្រហាយខ្លាំង ដូចជា កាល់ម៉ាហ្ស៊ីន (Calmagine), អាណាហ្សាំង (Analgine), រីម៉ាស៊ីគ្លីន (Remacycline), អុកស៊ីតេត្រា អិលអា (Oxytetra LA)។

**រោគសញ្ញា ៖**

- កន្លែងចាក់ថ្នាំមានសភាពឡើងក្រហម ក្ដៅ និងឈឺចាប់
- ការជាសះស្បើយកើតឡើងពី ៣-៥ ថ្ងៃ ដោយមិនចាំបាច់ព្យាបាល

**ការពារ ៖**

ពេលចាក់ថ្នាំក្នុងកម្រិតលើសពី ២០ ម.ល/សេស គេចាំបាច់ត្រូវបែងចែកជា ២ លើក ហើយដោយចាក់នៅកន្លែង ២ ផ្សេងគ្នាផងដែរ។



ប្រសិនបើគ្មានការបង្កជាបូសទេ ការឡើងរឹងត្រង់កន្លែងចាក់នេះនឹងបាត់ទៅវិញ នៅ ២-៣ ថ្ងៃក្រោយ

## គ- រលូតកូន

ថ្នាំខ្លះមិនអាចប្រើបានទៅលើមេផើមបានទេ ដូចជា ដិចសាមេតាសូន (Dexamethasone) មិនអាចចាក់លើមេជ្រូក ឬមេគោ ដែលផើមនៅដំណាក់កាលចុងក្រោយបានទេ។ ការប្រើប្រាស់ប្រូស្តាគ្លង់ឌីន (***លុយតាលីស*** (Lutalyse) ***ឬស៊ូប្រូស*** (Suiprost)) ក្នុងកំឡុងពេលផើមក៏ធ្វើឱ្យរលូតផងដែរ។ *តែការរលូតនេះមិនមែនជាផលវិបាកនៃការប្រើប្រាស់ថ្នាំទេ តែវាជាការប្រើប្រាស់ថ្នាំខុស។*



មេជ្រូកមានបញ្ហារលូតកូន

## ឃ- បញ្ហាដំបៅក្រពះ

ថ្នាំប្រឆាំងការរលាកភាគច្រើនបង្កឱ្យមាន**បញ្ហាដំបៅក្រពះ** ។

### រោគសញ្ញា

- កម្តៅមិនឡើង
- មេជ្រូកឈប់ស៊ីចំណី

### ការពារ/ព្យាបាល

- ដោយសារក្រពះមានបញ្ហាហូរឈាម គេត្រូវចាក់ថ្នាំជំរុញឱ្យសត្វស៊ីចំណី និងចាក់វីតាមីន បេ ១២ ដូចជា កាភាស៊ីល (Carasil), អេមាតូប៉ង់ បេ ១២ (Hematopan $B_{12}$)
- ដើម្បីការពារ សម្រាប់មេជ្រូកគេផ្តល់ចំណីឱ្យស៊ីតិចតួច (តិចជាង ៥០០ក្រាម) ហើយត្រូវលាយជាមួយទឹក និងស្ករ ដើម្បីឱ្យចំណីសើមទន់ ។
- ត្រូវប្រើថ្នាំប្រឆាំងនឹងការរលាក តែក្នុងករណីណាដែលចាំបាច់ប៉ុណ្ណោះ ។



ជ្រូកដំបៅក្រពះអាចមានឈាមហូរនៅខាងក្នុង ជាហេតុធ្វើឱ្យជ្រូកចុះខ្សោយ

## ៤-៥- គុណភាពរបស់ឱសថ

ឱសថមានគុណភាពមានន័យថាវាផលិតចេញយ៉ាងល្អពីរោងចក្រត្រឹមត្រូវ ហើយមានសមាសធាតុផ្សំសុទ្ធល្អ ភាគរយផ្សំត្រឹមត្រូវ ការរៀបចំបានល្អ ប្រអប់ថ្នាំ/ដបថ្នាំរឹងមាំ និងមានបិទស្លាកនៅដបថ្នាំបានច្បាស់លាស់ និងមានព័ត៌មានគ្រប់គ្រាន់។ នៅពេលទិញថ្នាំពីក្រុមហ៊ុនដែលគេទទួលស្គាល់លើពិភពលោក ធ្វើឱ្យយើងអាចជឿទុកចិត្តលើគុណភាពបាន ដោយសារពួកគេគោរពតាមបទដ្ឋានអន្តរជាតិ មានក្រុមហ៊ុនដូចជា (Merial, Intervet, Vetoquinol, Bio, Virbac, Coophavet…) ។

នៅក្នុងតំបន់យើងមានជួបប្រទះបញ្ហាខ្លាំងលើ**ថ្នាំក្លែងក្លាយ** ដែលផលិតដោយមន្ទីរពិសោធន៍អន្តជាតិ។ មន្ទីរពិសោធន៍ខ្លះផលិត**ថ្នាំមានគុណភាពអន់** ប៉ុន្តែមានតម្លៃថោកដែលធ្វើឱ្យកសិករចូលចិត្តប្រើ ដោយឡែកថ្នាំមានគុណភាពល្អ ក៏មានតម្លៃថ្លៃផងដែរ។

## ៤-៦-ការថែរក្សាឱសថ

### ៤-៦-១-ពន្លឺ

ពន្លឺច្រើនតែមានឥទ្ធិពលទៅគុណភាពថ្នាំ ដូចនេះជាទូទៅថ្នាំទាំងនេះត្រូវបានគេដាក់លក់នៅក្នុងដបពណ៌ត្នោត រឺ/និងក្នុងប្រអប់។







## ៤-៦-២-កម្ដៅ

ឱសថភាគច្រើនងាយខូចគុណភាព**ដោយសារកម្ដៅ** ដូចនេះដើម្បីការពារយកល្អគេត្រូវថែរក្សានៅសីតុណ្ហភាព ២០ អង្សាសេ តែនៅប្រទេសយើងវាមិនប្រាកដទេ។ ដោយឡែកនៅក្នុងកសិដ្ឋានត្រូវថែរក្សាថ្នាំ នៅកន្លែងណាដែលត្រជាក់ជាងគេ។ ចំពោះការថែរក្សាវ៉ាក់សាំងត្រូវតែដាក់ក្នុងធុងទឹកកកជាប្រចាំរហូតដល់ពេលប្រើប្រាស់។



*ការថែរក្សាវ៉ាក់សាំងក្នុងទឹកកក*

## ៤-៦-៣-សំណើម

ថ្នាំខ្លះពេលត្រូវសំណើមវាក្លាយជាដុះផ្សិត និងប្រែទៅជាពណ៌បៃតង ឬធំក្លិនអាក្រក់

**ដូចនេះគេមិនត្រូវប្រើប្រាស់វាឡើយ។**





## ៤-៦-៤-ខ្យល់



នៅពេលបូមថ្នាំចេញពីដប ខ្យល់បានជ្រាបចូលទៅក្នុងដប ហើយវាអាចចម្លងមេរោគចូលក្នុងដប ។ ក្នុងខ្យល់មានអុកស៊ីសែនដែលអាចមានឥទ្ធិពលទៅលើថ្នាំ ម្យ៉ាងវិញទៀតប្រសិនបើគេប្រើប្រាស់ថ្នាំ (បូមថ្នាំពីដប) ញឹកញាប់នោះគុណភាពថ្នាំនឹងថយចុះផងដែរ ។

## ៤-៦-៥- កាលបរិច្ឆេទប្រើប្រាស់

ជាធម្មតាថ្នាំត្រូវតែប្រើឱ្យអស់មុន**ផុតកំណត់កាលប្រើប្រាស់** ។ ថ្នាំខ្លះដូចជាវីតាមីនងាយងាយរងការខូចខាត ហើយលំបាកក្នុងការថែរក្សា ដូចនេះត្រូវគោរពទៅតាមកាលបរិច្ឆេទប្រើប្រាស់ ។




កាលបរិច្ឆេទប្រើប្រាស់មានបង្ហាញច្បាស់លាស់ នៅលើស្លាកដបថ្នាំ

## ៥. អង់ទីប៊ីយ៉ូទិក

អង់ទីប៊ីយ៉ូទិក គឺជាប្រភេទថ្នាំដែលគេប្រើញឹកញាប់បំផុតសម្រាប់ព្យាបាលជំងឺសត្វដែលបង្កដោយបាក់តេរី ។ ក្នុងពេលបច្ចុប្បន្ននេះ គេឃើញមានអង់ទីប៊ីយ៉ូទិក និង អង់ទីប៊ីយ៉ូទិកបន្សំជាច្រើនប្រភេទ ។ ត្រូវចងចាំថាអង់ទីប៊ីយ៉ូទិកពុំមានប្រសិទ្ធភាពក្នុងការកម្ចាត់វីរុសបានទេ ។

### ៥.១. អង់ទីប៊ីយ៉ូទិកជាអ្វី?

**អង់ទីប៊ីយ៉ូទិក** គឺជាសារធាតុគីមីដែលអាចសម្លាប់បាក់តេរី ឬបញ្ឈប់ការលូតលាស់របស់បាក់តេរី ។ *គ្មានអង់ទីប៊ីយ៉ូទិកណា ដែលអាចសម្លាប់បាក់តេរីបានគ្រប់ប្រភេទនោះទេ* ពោលគឺអង់ទីប៊ីយ៉ូទិកមានសកម្មភាពតែលើក្រុមបាក់តេរីខ្លះប៉ុណ្ណោះ ។ អង់ទីប៊ីយ៉ូទិកត្រូវបានគេចែកចំណាត់ថ្នាក់**ជាគ្រួសារ** ។




ឡងហ្គាម៉ុកផ្សំចេញពីអាម៉ុកស៊ីលីន វាគឺជាអង់ទីប៊ីយ៉ូទិក

## ៥.២. អ្វីទៅជាបាក់តេរី?

បាក់តេរីគឺជាសរីរាង្គតូចបំផុត ហើយអាចបង្កជំងឺបាននៅពេលវាធ្វើការបំបែកខ្លួន ហើយយើងអាចមើលឃើញតាមរយៈការប្រើមីក្រូទស្សន៍។









ស្ត្រិបតូកុកកូស (Streptococcus)

អ៊ី.កូលី **(E.Coli)**



ជ្រូកប្រកាច់ដោយ
មេរោគស្ត្រិបតូកុកកូស
(Streptococcus)



រាកបង្កឡើងដោយ អ៊ីកូលី (E.Coli)

## ៥.៣. សកម្មភាពរបស់អង់ទីប៊ីយ៉ូទិក



បាក់តេរីមានភ្នាសខាងក្រៅសម្រាប់ការពារខ្លួនវា។ **អង់ទីប៊ីយ៉ូទិកអាចបំផ្លាញភ្នាសនេះ ហើយធ្វើឱ្យបាក់តេរីងាប់**។ ២-៣ថ្ងៃ ក្រោយមកបាក់តេរីភាគច្រើននឹងងាប់ ហើយសត្វចាប់ផ្តើមជាពីជំងឺ។

## ៥.៤. គ្រួសារអង់ទីប៊ីយ៉ូទិក

នៅពេលអង់ទីប៊ីយ៉ូទិក ស្ថិតនៅក្នុងគ្រួសារជាមួយគ្នា ពួកវា :

- មានទម្រង់ដូចគ្នា
- មានសកម្មភាពដូចគ្នាក្នុងការសម្លាប់បាក់តេរី
- មានប្រសិទ្ធភាពចំពោះបាក់តេរីក្នុងក្រុមដូចគ្នា

ក្នុងគ្រួសារអង់ទីប៊ីយ៉ូទិកខ្លះត្រូវបានគេប្រើជាយូរមកហើយ និងខ្លះទៀតថ្មី តែវាមានប្រសិទ្ធភាពលើបាក់តេរីជាច្រើនប្រភេទ។ ការស្គាល់ពីគ្រួសារអង់ទីប៊ីយ៉ូទិកមានសារៈសំខាន់ណាស់ ព្រោះគេអាចដឹងពីប្រភេទថ្នាំណាខ្លះអាចដែលធ្វើការរួមគ្នាក្នុងការសម្លាប់មេរោគ ហើយនិងថ្នាំប្រភេទណាខ្លះដែលមានសកម្មភាពប្រឆាំងគ្នា។

## គ្រួសារអង់ទីប៊ីយ៉ូទិកសំខាន់ៗ ៖

**១- គ្រួសារ បេតា-ឡាតាមីន** (Beta-lactamines)

- ប៉េនីសស៊ីលីន (Penicillin)
- អំពីស៊ីលីន (Ampicillin)
- អាម៉ុកស៊ីស៊ីលីន (Amoxicillin)

**២- គ្រួសារ ហ្វេនីកុល** (Phenicols)

- ក្លរំហ្វេនីកុល (Chloramfenicol) ៖ ហាមប្រើប្រាស់សម្រាប់ព្យាបាលសត្វ
- ផ្លរហ្វេនីកុល (Florfenicol)

**៣- គ្រួសារ តេត្រាស៊ីគ្លីន** (Tetracyclines)

- អុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline)
- ដុកស៊ីស៊ីគ្លីន (Doxycycline)

**៤- គ្រួសារ ម៉ាក្រូលីដ** (Macrolides)

- ទីឡូស៊ីន (Tylosine)
- ស្ពីរ៉ាមីស៊ីន (Spiramycine)
- ឡាំងកូស៊ីន (Lincomycine)

**៥- គ្រួសារ ប៉ូលីប៉ិបទីត** (Polypetptide)

- កូលីស្ទីន (Colistine)

### ៦- គ្រួសារ គីណូឡូន (Quinolones)

- ហ្លួយមេគីន (Flumequine)
- អង់រ៉ូហ្លុកសាស៊ីន (Enrofloxacine)

### ៧- គ្រួសារ ស៊ុលហ្វាមីដ (Sulfamides)

- ស៊ុលហ្វាឌីមីឌីន (Sulfadimidine)
- ស៊ុលហ្វាមេតុកស៊ីន (Sulfamethoxine)




សូណូវីល (Suanovil)មានសមាសធាតុគីមី ស្ពីរ៉ាមីស៊ីន (Spiramycine)

ហើយស្ថិតក្នុងគ្រួសារ ម៉ាក្រូលីត (Macrolides)

## ៥.៥. ការប្រើអង់ទីប៊ីយ៉ូទិករួមគ្នា

ការប្រើអង់ទីប៊ីយូទិករួមគ្នា គឺជាការចាក់នូវអង់ទីប៊ីយ៉ូទិកច្រើនមុខក្នុងពេលជាមួយគ្នា ប៉ុន្តែមិនត្រូវលើស ៣ មុខឡើយ ។ អង់ទីប៊ីយ៉ូទិកខ្លះមានសកម្មភាពប្រឆាំងគ្នា មានន័យថាពេលប្រើជាមួយគ្នា វានឹងបន្ថយប្រសិទ្ធភាពរបស់ថ្នាំ ដូចនេះគេមិនប្រើពួកវាក្នុងពេលតែមួយឡើយ ។

**គ្រួសារថ្នាំដែលប្រើរួមគ្នាបាន:**

- គ្រួសារតេត្រាស៊ីគ្លីន ជាមួយ គ្រួសារម៉ាក្រូលីដ
- គ្រួសារតេត្រាស៊ីគ្លីន ជាមួយ គ្រួសារស៊ុលហ្វាមីដ
- គ្រួសារកូលីស្ទីន ជាមួយ គ្រួសារបេតា-ឡាតាមីន

**គ្រួសារថ្នាំដែលមិនអាចប្រើជាមួយគ្នាបាន:**

- គ្រួសារម៉ាក្រូលីដ ជាមួយ គ្រួសារបេតា-ឡាតាមីន
- គ្រួសារតេត្រាស៊ីគ្លីន ជាមួយ គ្រួសារបេតា-ឡាតាមីន
- គ្រួសារហ្វេនីកុល ជាមួយ គ្រួសារបេតា-ឡាតាមីន និងគ្រួសារម៉ាក្រូលីដ



ភ្នាក់ងារសុខភាពសត្វអាចប្រើឡាំងកូមីស៊ីន (Lincomycin) ជាមួយនឹងអុកស៊ីតេត្រាស៊ីគ្លីន (OTC) ព្រោះវាជួយឱ្យអង់ទីប៊ីយ៉ូទិក មានប្រសិទ្ធភាពខ្លាំងឡើង

## ៥.៦. ការជ្រើសរើសអង់ទីប៊ីយ៉ូទិក

ការកំណត់ជំងឺឱ្យបានច្បាស់លាស់ ពិតជាមានសារៈសំខាន់យ៉ាងណាស់ ព្រោះដើម្បីឱ្យដឹងថាតើវាបង្កដោយវីរុស ឬបាក់តេរី ។ ប្រសិនបើជាបាក់តេរី យើងត្រូវជ្រើសរើសអង់ទីប៊ីយ៉ូទិកណាដែលត្រូវនឹងវា ប៉ុន្តែប្រសិនបើជាវីរុសយើងត្រូវជ្រើសរើសនូវអង់ទីប៊ីយ៉ូទិកណា ដែលមានសកម្មភាពទូលាយ ដើម្បីទប់ស្កាត់ជំងឺឱកាសនិយម ប៉ុន្តែអង់ទីប៊ីយូទិកមិនអាចសម្លាប់វីរុបានទេ ។

*តើការរលាកស្បែកនេះបណ្ដាលមកពី ពួកស្តាហ្វីឡូកុកូស ឬ ក៏ប៉េស្តជ្រូក?*



*ចំលើយគឺជំងឺប៉េស្តជ្រូក*

## ការណែនាំក្នុងការជ្រើសរើសអង់ទីប៊ីយ៉ូទិកសម្រាប់ធ្វើការព្យាបាល

- **បញ្ហាលើស្បែក**
    - អាម៉ុកស៊ីលីន (Amoxicilline)
    - ឡាំងកូមីស៊ីន (Lincomycine)
    - ទ្រីមេតូព្រីម/ស៊ុលហ្វា (TMP + sulfa)
- **ជំងឺផ្លូវដង្ហើម**
    - តេត្រាស៊ីគ្លីន (Tetracyclines)
    - ផ្លរហ្វេនីកុល (Florfenicol)
    - អង់រ៉ូហ្លុកសាស៊ីន (Enrofloxacine)
- **ជំងឺរលាកស្បូន**
    - អង់រ៉ូហ្លុកសាស៊ីន (Enrofloxacine)
    - អាម៉ុកស៊ីស៊ីលីន (Amoxicilline)
- **ជំងឺរលាកប្លោកនោម**
    - អង់រ៉ូហ្លុកសាស៊ីន (Enrofloxacine)
    - ទ្រីមេតូព្រីម/ស៊ុលហ្វា (TMP + sulfa)
- **ជំងឺស្រ្តិបតូកុកកូសកូនជ្រូក**
    - អាម៉ុកស៊ីស៊ីលីន (Amoxicilline)
    - ប៉េនីស៊ីលីន (Penicillin)

- **ជំងឺរាកកូនជ្រូក និងកូនគោ**
  - កូលីស្ទីន (Colistine)
  - អង់រ៉ូហ្លុកសាស៊ីន (Enrofloxacine)
- **ជំងឺរាកជ្រូក (កំឡុងបំប៉នចំណី)**
  - ទីឡូស៊ីន (Tylosin)
- **ជំងឺលាសដោះ**
  - ទ្រីមេតូព្រីម/ស៊ុលហ្វា (TMP + Sulfa) សម្រាប់មេជ្រូក
  - អាម៉ុកស៊ីស៊ីលីន (Amoxicilline) សម្រាប់មេគោ
- **ជំងឺរលាកសន្លាក់**
  - អាម៉ុកស៊ីស៊ីលីន (Amoxicilline)
  - ឡាំងកូមីស៊ីន (Lincomicine)
- **ជំងឺកញ្ជិល**
  - អាម៉ុកស៊ីស៊ីលីន (Amoxicilline)
  - ទីឡូស៊ីន (Tylosin)
- **ការពារប្រឆាំងនឹងការឆ្លងជាទូទៅ ប្រសិនជាជំងឺបង្កដោយវីរុស**
  - ទ្រីមេតូព្រីម/ស៊ុលហ្វា (TMP + sulfa)
  - អុកស៊ីតេត្រាស៊ីគ្លីន (OTC)

## ៦- ការណែនាំ

មុននឹងប្រើប្រាស់ថ្នាំសម្រាប់ព្យាបាលជំងឺសត្វ អ្នកប្រើប្រាស់ត្រូវយកចិត្តទុកដាក់នូវចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- **កម្រិតប្រើប្រាស់ ៖** អាស្រ័យទៅលើការណែនាំដែលមាននៅលើដបថ្នាំ
- **ចំនួនដងនៃការប្រើប្រាស់ ៖** ២ដង ក្នុង ១ថ្ងៃ ឬ ១ដង ក្នុង១ថ្ងៃ... ហើយចាំបាច់ត្រូវធ្វើតាមការណែនាំនៅដប ឬសំបកថ្នាំ
- **រយៈពេលនៃការប្រើប្រាស់ ៖** រយៈពេលប្រើប្រាស់ថ្នាំជាធម្មតាគឺ ៣-៥ ថ្ងៃ។ ជួនកាលការព្យាបាល អាចប្រើរយៈពេល ៧ថ្ងៃ ប៉ុន្តែការព្យាបាលមិនត្រូវឱ្យតិចជាង ៣ថ្ងៃឡើយ ។
- **ផ្លូវនៃការចាក់បញ្ចូលថ្នាំ ៖** ប្រើប្រាស់ផ្លូវបញ្ចូលឱសថឱ្យបានត្រឹមត្រូវតាមការណែនាំ ហើយដោយឡែក ចំពោះជ្រូកការចាក់តាមសាច់ដុំត្រូវប្រុងប្រយត្ន័ ។
- **កាលបរិច្ឆេទប្រើប្រាស់ ៖** ត្រូវត្រួតពិនិត្យមើលឱ្យបានច្បាស់លាស់ពីកាលបរិច្ឆេទនៃការប្រើប្រាស់ថ្នាំ ដើម្បីជៀសវាងយកថ្នាំដែលផុតកំណត់កាលប្រើប្រាស់យកមកប្រើ ។




ការជ្រើសរើសអង់ទីប៊ីយ៉ូទិកមកប្រើ មិនមែនប្រថុយដូចការលេងឆ្នោត ឬល្បែងទេ

គឺជ្រើសរើសអាស្រ័យទៅលើសកម្មភាពរបស់ថ្នាំ !

ត្រូវចងចាំថាថ្នាំមានសកម្មភាពខ្ពស់ ដូច្នេះភ្នាក់ងារសុខភាពសត្វភូមិត្រូវគិតគូរឱ្យបានច្បាស់លាស់មុនចាក់បញ្ចូលថ្នាំទៅក្នុងខ្លួនសត្វ។ ភ្នាក់ងារសុខភាពសត្វភូមិត្រូវចាក់ថ្នាំដែលមានគុណភាពល្អ និង ប្រើប្រាស់ថ្នាំតែ ១ ឬ២ មុខ ហើយចាំបាច់ត្រូវគោរពតាមការណែនាំ ដូចជាកម្រិតនៃការប្រើថ្នាំ និង ផ្លូវនៃការបញ្ចូលថ្នាំ។ ដើម្បីឱ្យការព្យាបាលទទួលបានជោគជ័យ ភ្នាក់ងារសុខភាពសត្វភូមិត្រូវធ្វើរោគវិនិច្ឆ័យជម្ងឺឱ្យបានត្រឹមត្រូវ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# កែលំអជីវសុវត្ថិភាពនៅ
# តាមភូមិ

ឧបត្ថម្ភដោយៈ

គម្រោងចិញ្ចឹមសត្វកម្ពុជា
សហគមន៍អឺរ៉ុប

សហគមន៍អឺរ៉ុប

អង្គការស្បៀង និងកសិកម្ម
នៃអង្គការសហប្រជាជាតិ

# មាតិកា

ទំព័រ

១- សេចក្ដីផ្ដើម ............ ០១

១-១- តើអ្វីទៅជាជីវសុវត្ថិភាព ? ............ ០១

១-២- ជីវសុវត្ថិភាពថ្នាក់ជាតិ ............ ០១

១-៣- ជីវសុវត្ថិភាពថ្នាក់មូលដ្ឋាន ............ ០៣

១-៤- គោលបំណងនៃការអនុវត្តន៍ជីវសុវត្ថិភាព ............ ០៣

២- ជីវសុវត្ថិភាពថ្នាក់មូលដ្ឋាន ............ ០៥

២-១- គ្រោះថ្នាក់ក្នុងភូមិ ............ ០៥

២-២- មូលដ្ឋានគ្រឹះសម្រាប់ការពារ ............ ១១

៣- កត្តានៃការឆ្លងជំងឺចូលទៅក្នុងភូមិ និង វិធានការការពារ ............ ១៤

៣-១-តាមសត្វរស់ ............ ១៤

៣-២- តាមរយៈសាច់សត្វ ............ ២១

៣-៣- មធ្យោបាយដឹកជញ្ជូន ............ ២២

៣-៤- តាមមនុស្ស ............ ២៣

៣-៥- តាមរយៈសំរាម ............ ២៤

**៤- ការសម្លាប់មេរោគ** ............ ២៦

៤-១- និយមន័យ ............ ២៦

៤-២- ការប្រើប្រាស់ត្រឹមត្រូវ ............ ២៧

៤-៣- ប្រភេទថ្នាំសម្លាប់មេរោគ ............ ៣០

**៥- ការចាត់វិធានការនៅពេលមានផ្ទុះជំងឺនៅភូមិជិតខាង (រៀបចំផែនការភូមិទុកជាមុន)** ........ ៣២

៥-១- សេចក្ដីផ្ដើម ........ ៣២

៥-២- ភ្នាក់ងារចម្លងមេរោគ ........ ៣២

៥-៣- ការប្រកាសប្រាប់ព័ត៌មាន ........ ៣៣

៥-៤- ធ្វើការហាមឃាត់ ........ ៣៤

៥-៥- ប្រុងប្រយ័ត្នខ្ពស់ក្នុងការរៀបចំសាច់ ........ ៣៥

៥-៦- ចិញ្ចឹមសត្វនៅកន្លែងមួយច្បាស់លាស់ ........ ៣៥

៥-៧- ការពារនៅច្រកចូល ........ ៣៧

៥-៨- ការពារកុំឱ្យមានការប៉ះពាល់ជាមួយសត្វ ........ ៣៨

៥-៩- ភារៈកិច្ចរបស់ភ្នាក់ងារសុខភាពសត្វភូមិ ........ ៣៩

**៦- បទពិសោធន៍របស់អង្គការ AVSF** ........ ៤០

៦-១- ការរៀបចំគម្រោង ........ ៤០

៦-២- សកម្មភាពអង្គការ ........ ៤០

៦-៣- ស្ថានភាពភូមិមុនអនុវត្តសកម្មភាព ........ ៤៤

៦-៤- សកម្មភាពសម្អាតភូមិ ........ ៤៦

៦-៥- ទិន្នន័យទទួលបាន ........ ៤៨

**៧- សន្និដ្ឋាន** ........ ៤៨

# កែលំអជីវសុវត្ថិភាពនៅតាមភូមិ

## ១.  សេចក្ដីផ្ដើម

### ១.១.  តើអ្វីទៅជាជីវសុវត្ថិភាព ?

**ជីវសុវត្ថិភាពគឺជា**ប្រព័ន្ធ និងសកម្មភាព ដែលអាចជួយ**ទប់ស្កាត់**ការឆ្លងរីករាលដាលជំងឺ និង ជាបទបញ្ជាអនាម័យ ដែលមានមូលដ្ឋានគ្រឹះសម្រាប់ទប់ស្កាត់ការឆ្លងរីករាលដាលជំងឺចូលទៅក្នុងភូមិ ឬការពារកុំឱ្យមានការរាតត្បាតជំងឺពេញទាំងភូមិ។

### ១.២.  ជីវសុវត្ថិភាពថ្នាក់ជាតិ

#### ១.២.១.វិធានការការពារនៅតាមព្រំដែន

ការការពារជំងឺកុំឱ្យឆ្លងចូលមកក្នុងប្រទេសគឺមានសារៈសំខាន់ណាស់ ដូចជាក្នុងករណីមានការផ្ទុះជំងឺនៅប្រទេសជិតខាង រដ្ឋាភិបាលចេញសេចក្ដីប្រកាសជាប្រចាំ ដើម្បីហាមឃាត់ការនាំចូលសត្វមួយចំនួន ដូចជា:

- ក្នុងករណីមានផ្ទុះជំងឺអុតក្ដាម រដ្ឋាភិបាលហាមឃាត់ការនាំចូលគោ-ក្របី
- ក្នុងករណីមានផ្ទុះជំងឺផ្ដាសាយបក្សី រដ្ឋាភិបាលហាមឃាត់ការនាំចូលបក្សី
- ក្នុងករណីមានផ្ទុះជំងឺត្រចៀកខៀវ រដ្ឋាភិបាលហាមឃាត់ការនាំចូលជ្រូក...។




ព្រំដែនគឺជាតំបន់ទប់ស្កាត់ជំងឺដ៏សំខាន់ និងជាកន្លែងត្រួតពិនិត្យចរាចរសត្វនៅក្នុងប្រទេស

## ១.២.២. ត្រួតពិនិត្យចរាចរសត្វក្នុងប្រទេស

ក្នុងកំឡុងពេលផ្ទុះជំងឺផ្តាសាយបក្សី គេត្រូវធ្វើការហាមឃាត់ចរាចរបក្សីក្នុងចំងាយ ១០ គីឡូម៉ែត្រ ជុំវិញតំបន់ផ្ទុះជំងឺ ដើម្បីការពារកុំឱ្យមានការឆ្លងរាលដាលនៃជំងឺនេះទៅភូមិផ្សេងទៀត។ ជាមួយគ្នានេះដែរក្នុងកំឡុងពេលផ្ទុះជំងឺផ្តាសាយបក្សី ពេទ្យសត្វស្រុកត្រូវតែធ្វើការត្រួតពិនិត្យបក្សីមុនអនុញ្ញាតឱ្យដឹកជញ្ជូន ឬមុនចេញលិខិតបញ្ជាក់ផ្សេងៗ។

ការដឹកជញ្ជូនជ្រូកឆ្លងកាត់ខេត្ត៖ តើជ្រូកទាំងនេះមានសុខភាពល្អឬ?



## ១.៣. ជីវសុវត្ថិភាពថ្នាក់មូលដ្ឋាន

ការត្រួតពិនិត្យចរាចរសត្វក្នុងកម្រិតថ្នាក់ជាតិ មានការលំបាកខ្លាំងណាស់ ប៉ុន្តែគេអាចការពារការរីករាលដាលនៃជំងឺនៅថ្នាក់មូលដ្ឋានបាន ដោយអនុវត្តនូវវិធានការសាមញ្ញៗ តែអាចកាត់បន្ថយគ្រោះថ្នាក់នៃការឆ្លងជំងឺពីសត្វឈឺពីភូមិមួយទៅភូមិមួយទៀតបាន។ ជាពិសេសអាចទប់ស្កាត់ និងកាត់បន្ថយការរីកលូតលាស់របស់មេរោគ និង គ្រោះថ្នាក់នៃការឆ្លងជំងឺនៅក្នុងភូមិបាន។



ការទិញមាន់របស់ឈ្មួញកណ្តាល... តើអ្នកប្រាកដថាមាន់នោះវាមិនឈឺឬ?

## ១.៤. គោលបំណងនៃការអនុវត្តន៍ជីវសុវត្ថិភាព

### ១.៤.១. ជួយធ្វើឱ្យសត្វមានសុខភាពល្អ

គោលបំណងសំខាន់គឺ ការពារកុំឱ្យមានសត្វឈឺនៅក្នុងភូមិ (បក្សី គោ ជ្រូក...) តាមរយៈការបង្កើនសុខភាពសត្វ ដើម្បីៈ

- ជួយកាត់បន្ថយការចំណាយលើការព្យាបាលសត្វ ធានាឱ្យសត្វមានការលូតលាស់ និងផលិតកម្មបានល្អ
- កាត់បន្ថយអត្រាស្លាប់ ដើម្បីជួយបង្កើនដើមទុនដល់កសិករ និងបង្កើនចំនួនសត្វ ។

***ចំណុចទាំងពីរខាងលើនេះ ចូលរួមចំណែកដ៏សំខាន់ក្នុងការបង្កើនប្រាក់ចំណូលរបស់កសិករ !***



ដើម្បីចិញ្ចឹមសត្វឱ្យបានចំណេញ លក្ខណៈចំបង គឺត្រូវវិធានាសត្វឱ្យ មានសុខភាពល្អ

## ១.៤.២. ជួយធ្វើឱ្យមនុស្សមានសុខភាពល្អ

- កាត់បន្ថយគ្រោះថ្នាក់ជំងឺឆ្លងពីសត្វទៅមនុស្សតាមរយៈការថែទាំសត្វឱ្យមានសុខភាពល្អ
- បទបញ្ជាអនាម័យសាមញ្ញៗ តែអាចជួយកាត់បន្ថយគ្រោះថ្នាក់នៃការឆ្លងជំងឺពីសត្វទៅមនុស្ស

ប្រជាជននៅតាមភូមិរស់នៅយ៉ាងជិតស្និតជាមួយសត្វ



# ២. ជីវសុវត្ថិភាពថ្នាក់មូលដ្ឋាន

## ២.១. គ្រោះថ្នាក់ក្នុងភូមិ

### ២.១.១. ផ្លូវចូលភូមិ

ផ្លូវចូលភូមិដែលមានតែចរាចរសត្វ និងមនុស្សនៅក្នុងភូមិធ្វើឱ្យអត្រាគ្រោះថ្នាក់នៃការឆ្លងរាលដាលជំងឺមានកម្រិតទាប ។ ផ្ទុយមកវិញផ្លូវដែលធ្វើចរាចរសត្វ និងមនុស្សពីស្រុក ខេត្ត... ឆ្លងកាត់ភូមិគឺធ្វើឱ្យអត្រាគ្រោះថ្នាក់មានកម្រិតខ្ពស់ ។

ផ្លូវចូលភូមិមួយចំនួនមានភាពងាយស្រួលក្នុងការទប់ស្កាត់ការធ្វើចរាចរ ហើយអាចទប់ស្កាត់សកម្មភាពចរាចរឆ្លងកាត់ភូមិដោយមានកំណត់ ។



ផ្លូវក្នុងភូមិមានសភាពស្ងៀមស្ងាត់ ហើយមានតែអ្នកភូមិធ្វើចរាចរ

*ផ្លូវសំខាន់ៗឆ្លងកាត់ភូមិ ផ្លូវជាតិ ឬ ផ្លូវចរាចរសំខាន់ៗពីឃុំ ស្រុក... ធ្វើឱ្យអត្រាគ្រោះថ្នាក់ឆ្លងរាលដាលជំងឺខ្ពស់ ។*



ផ្លូវធំភ្ជាប់ពីភូមិទៅឃុំ.....





សត្វក្នុងភូមិ ដើរលើផ្លូវក្នុងភូមិ គឺមានអត្រាគ្រោះថ្នាក់ឆ្លងរាលដាលជំងឺទាប





ប៉ុន្តែសត្វខ្លះដឹកមកពីឆ្ងាយ (អាចមានជំងឺ) ហើយឆ្លងកាត់ភូមិ នោះអត្រានៃការឆ្លងរាលដាលជំងឺខ្ពស់ ប្រសិនបើមានជំងឺ (ជំងឺដង្កៅ អុតក្តាម...) ផ្ទុះឡើងនៅភូមិជិតខាង

## ២.១.២. ការសាងសង់ទ្រុងសត្វ

សកម្មភាពនៃការចិញ្ចឹមសត្វរបស់កសិករនៅតាមភូមិមានលក្ខណៈផ្សេងៗគ្នា ដូចជា :

- ចិញ្ចឹមព្រលែង មានដូចជាមាន់ ហើយជួនកាលជ្រូកផងដែរ
- ចិញ្ចឹមឱ្យដើរចេញក្រៅភូមិ មានដូចជាគោ ជ្រូក (ការដាក់បា)
- ចិញ្ចឹមក្នុងទ្រុង មានដូចជាជ្រូក ហើយជួនកាលមាន់

**ការការពារជំងឺនឹងមានភាពងាយស្រួល ប្រសិនបើគេចិញ្ចឹមសត្វនៅកន្លែងមួយជាក់លាក់**



ការចិញ្ចឹមមានព្រលែងសេរី ធ្វើឱ្យគេមានការលំបាកក្នុងការការពារ មិនឱ្យប៉ះពាល់ជាមួយមាន់ឈឺផ្សេងទៀតណាស់



មាន់ចិញ្ចឹមនៅជុំវិញផ្ទះដោយមានរបងការពារមិនសូវមានឱកាសប៉ះពាល់ជាមួយមាន់ផ្សេងទៀតទេ



ការសាងសង់ទ្រុងគឺជាដំណោះស្រាយដ៏ល្អក្នុងការការពារជំងឺមាន់

គេពិបាកការពារការឆ្លងរាលដាលនៃជំងឺលើជ្រូកដែលព្រលែងឱ្យដើរសេរីណាស់





ទ្រុងស្អាតល្អធ្វើឱ្យជ្រូកមានសុវត្ថិភាពល្អ

គោ និងសត្វផ្សេងទៀតរស់នៅជាមួយមនុស្សគឺជាលក្ខខណ្ឌសមស្របសម្រាប់ការឆ្លងជំងឺពីសត្វទៅមនុស្ស





គោស៊ីស្មៅជាហ្វូង ជាហេតុធ្វើឱ្យមានការចម្លងមេរោគ និងបរាសិតឱ្យគ្នាទៅវិញទៅមក

## ២.១.៣. ទម្លាប់ក្នុងសង្គម

**ទម្លាប់អ្នកភូមិ ច្រើនតែ :**

- ទិញ ឬលក់មាន់រស់ ជ្រូករស់ពីផ្សារ ហើយសត្វទាំងនោះយកមកពីតំបន់ផ្សេងៗគ្នា រួចយកមកដាក់បញ្ចូលក្នុងហ្វូង ជាហេតុនាំឱ្យមានការបញ្ចេញមេរោគឱ្យគ្នាទៅវិញទៅមក
- យកបក្សីរស់ទៅចូលរួមពិធីផ្សេងៗ ( អាពាហ៍ពិពាហ៍...)
- ធ្លាប់ចូលមើលទ្រុងសត្វ និង ប៉ះពាល់សត្វ នៅពេលទៅលេងអ្នកជិតខាង មិត្តភ័ក្ត គ្រួសារ... ។

## ២.២. មូលដ្ឋានគ្រឹះសម្រាប់ការពារ

### ២.២.១. ភូមិប្រៀបដូចជាកសិដ្ឋានមួយ

- កសិករនៅតាមជនបទភាគច្រើនបានចិញ្ចឹមសត្វ (សត្វរស់នៅក្នុងភូមិ) ដូចនេះការអនុវត្តន៍វិធានការការពារសត្វមិនមានប្រសិទ្ធភាពទេ ប្រសិនបើមានតែមួយគ្រួសារជាអ្នកអនុវត្ត ហើយអ្នកភូមិផ្សេងទៀតមិនបានចូលរួម
- ភូមិប្រៀបដូចជាកសិដ្ឋានដ៏ធំមួយ ដូចនេះ :
  - អ្នកភូមិទាំងអស់គ្នាត្រូវតែចូលរួមកែលំអជីវសុវត្ថិភាព
  - គេត្រូវការពារភូមិទាំងមូល ។



អាពាហ៍ពិពាហ៍នៅតាមភូមិ





ការទិញបក្សីពីទីផ្សារ
គឺមានគ្រោះថ្នាក់ខ្លាំង

ក្រោយពីអ្នកបច្ចេកទេសទាំងនេះ
ចូលមើលកសិដ្ឋានជាច្រើនរួច
តើអ្នកគួរអនុញ្ញាតឱ្យពួកគាត់
ចូលមកមើលជ្រូករបស់អ្នក
ដែរឬទេ?



## ២.២.២. អ្នកភូមិចូលរួមទាំងអស់គ្នា

- គេមិនអាចធានាឱ្យមានជីវសុវត្ថិភាពដោយគ្មានការគាំទ្រពីអ្នកភូមិទាំងអស់គ្នាបានទេ
- ភ្នាក់ងារសុខភាពសត្វភូមិត្រូវពន្យល់អ្នកភូមិឱ្យយល់ច្បាស់ពីសារៈប្រយោជន៍នៃការកែលំអជីវសុវត្ថិភាព ។



អ្នកភូមិរួមគ្នាធ្វើការបោសសម្អាតភូមិ





គោលបំណង និងសារៈប្រយោជន៍របស់ជីវសុវត្ថិភាព
ត្រូវបានគេពន្យល់យ៉ាងច្បាស់លាស់ដល់អ្នកភូមិ

## ២.២.៣. សារៈប្រយោជន៍ក្នុងការដឹងពីព័ត៌មាន

- ជីវសុវត្ថិភាព ត្រូវបានគេធ្វើជាប្រចាំ ហើយវាមានភាពងាយស្រួល ដោយគេគ្រាន់តែផ្លាស់ប្តូរទម្លាប់មិនល្អបន្តិចបន្តួចចោលប៉ុណ្ណោះ

- ប៉ុន្តែក្នុងករណីមានផ្ទុះជំងឺ ច្បាប់របស់ជីវសុវត្ថិភាពត្រូវបានគេរិតត្បិត ហើយមានការលំបាកខ្លាំង ដូចនេះគេត្រូវតែប្រកាសប្រាប់ដល់អ្នកភូមិឱ្យបានដឹងច្បាស់លាស់ពីការផ្ទុះជំងឺឆ្លងនៅក្នុងស្រុក។

*ភ្នាក់ងារសុខភាពសត្វភូមិត្រូវទទួលព័ត៌មានថ្មីៗ ពីភ្នាក់ងារសុខភាពសត្វភូមិផ្សេងទៀត ឬពីពេទ្យសត្វស្រុក !*



បន្ទាប់ពីការបណ្តុះបណ្តាលឡើងវិញរយៈពេល ២ ឆ្នាំ ធ្វើឱ្យភ្នាក់ងារសុខភាពសត្វភូមិស្គាល់គ្នាកាន់តែច្បាស់ ហើយពួកគេងាយស្រួលចែករំលែកព័ត៌មានថ្មីៗស្តីពីការផ្ទុះជំងឺឱ្យគ្នាទៅវិញទៅមក

## ៣. កត្តានៃការឆ្លងជំងឺចូលទៅក្នុងភូមិ និង វិធានការការពារ

### ៣.១. ឆ្លងតាមសត្វរស់

**ក- ការចម្លង :** តាមរយៈ

- សត្វឈឺ ដែលមានរោគសញ្ញាច្បាស់ ឬ មិនបញ្ចេញរោគសញ្ញា
- សត្វមានផ្ទុកមេរោគ សត្វទាំងនេះបញ្ចេញមេរោគមកក្រៅតាមលាមក សំបោរ... ហើយអាចចម្លងទៅសត្វ ឬមនុស្ស ។



ទាអាចមានផ្ទុកវីរុសផ្តាសាយបក្សីដោយមិនបញ្ចេញរោគសញ្ញា តែវាអាចធ្វើការចម្លងទៅដល់មាន់

**ខ- រយៈពេលសម្ងំរបស់មេរោគ**

រយៈពេលសម្ងំរបស់មេរោគ គឺជាចន្លោះពេលពីមេរោគចូលក្នុងខ្លួនសត្វរហូតដល់សត្វបង្ហាញរោគសញ្ញាដំបូង។ ក្នុងដំណាក់កាលនេះសត្វមើលទៅមានសុខភាពល្អ តែវាបញ្ចេញមេរោគ និង ធ្វើការចម្លងទៅសត្វផ្សេងទៀត។ រយៈពេលសម្ងំរបស់មេរោគមានការប្រែប្រួលទៅតាមប្រភេទជំងឺដូចជា:

- ជំងឺដង្កោ មានរយៈពេលពី ២ ថ្ងៃ ទៅ ២ សប្តាហ៍
- ជំងឺប៉េស្តជ្រូក មានរយៈពេលពី ៧ ទៅ ១០ ថ្ងៃ
- ជំងឺអុតក្តាម មានរយៈពេលពី ២ ថ្ងៃ ទៅ ២ សប្តាហ៍
- ជំងឺផ្តាសាយបក្សី មានរយៈពេលពី ២-៣ ម៉ោង ដល់ ២ សប្តាហ៍

មាន់គកនេះមើលទៅមានសុខភាពល្អ
តើអ្នកប្រាកដថាវាមិនមានផ្ទុកវីរុសដង្កោឬ?



ការចម្លងដោយសារការនាំសត្វឈឺមកក្នុងភូមិ មានដូចជា :

- ការទិញសត្វរស់ពីទីផ្សារមកចិញ្ចឹម
- ឈ្មួញកណ្តាលលក់កូនជ្រូក ឬមាន់ដែលមានប្រភពមិនច្បាស់លាស់
- ការដឹកបាជ្រូក មកពីភូមិជិតខាង
- អ្នកភូមិទិញគោពីភូមិជិតខាង
- បក្សីព្រៃដែលឈឺស៊ីចំណីជាមួយមាន់-ទា ។



មាន់នៅទីផ្សារយកមកពីកន្លែងផ្សេង
ៗ គ្នា
ហើយខ្លះមកពីតំបន់ដែលមានជំងឺ

បាជ្រូកអាចចម្លងជំងឺ
ក្រោយពីពាក់មេដែលឈឺ





ជ្រូកបាអាចចម្លងជំងឺដល់មេតាមរយៈ
ទឹកកាម ដូចជាជំងឺប៉េស្តជ្រូក (CSF)

ឈ្មួញកណ្តាលដឹកកូនជ្រូកមកលក់
នៅក្នុងភូមិ តើកូនជ្រូកទាំងនេះ
ចេញមកពីប្រភពណា?





គោទើបតែទិញពីភូមិជិតខាង តើវាអត់មានបរាសិតឬ?

## គ- វិធានការការពារ :

**ទិញសត្វដែលមានសុខភាពល្អគឺ:**

- កុំទិញសត្វណាដែលបង្ហាញអាការៈឈឺ ដូចជា ខ្សោយ ភ្នែកក្រហម រោមបះ...
- ភ្នាក់ងារសុខភាពសត្វភូមិអាចផ្តល់ដំបូន្មានស្តីពីសត្វដែលមានសុខភាពល្អ
- កសិករត្រូវតែប្រុងប្រយ័ត្នលើសត្វដែលមានតម្លៃថោក ។

ទិញកូនជ្រូកមានសុខភាពល្អ វាមានតម្លៃថ្លៃបន្តិចមែន តែល្អសម្រាប់ការចិញ្ចឹម



**ទិញសត្វដែលមានប្រភពច្បាស់លាស់៖**

- ទិញសត្វពីភូមិដែលអ្នកដឹងថាមានសុវត្ថិភាព ដូចជាមិនមានជំងឺអុតក្តាម...
- ទិញកូនជ្រូកពីកសិដ្ឋានតែមួយ ព្រោះការទិញកូនជ្រូកដែលគ្មានប្រភពច្បាស់លាស់ ឬពីកន្លែងច្រើនពេក ធ្វើឱ្យអត្រាគ្រោះថ្នាក់ខ្ពស់។



តើអ្នកប្រាកដថាកូនជ្រូកទាំងនេះ មកពីកសិដ្ឋានប្រទេសជិតខាងដែលគ្មានជំងឺត្រចៀកខៀវឬ?

**ដាក់សត្វថ្មីឱ្យនៅដាច់ពីគេ**

- ដាក់សត្វថ្មីឱ្យនៅដាច់ពីគេ ២ សប្តាហ៍ ដើម្បីការពារការចម្លងមេរោគដល់សត្វផ្សេងទៀត ព្រោះជួនកាលសត្វមានមេរោគ ហើយកសិករត្រូវធ្វើការតាមដានសត្វរាល់ថ្ងៃ ដើម្បីរកមើលរោគសញ្ញាផ្សេងៗ
- បន្ទាប់ពី ២ សប្តាហ៍ ហើយសត្វមានសុខភាពល្អ គេអាចព្រលែងសត្វថ្មីនេះឱ្យទៅក្នុងហ្វូងបាន។

*ការដាក់សត្វថ្មីឱ្យនៅដាច់ពីគេ គឺជាវិធានការការពារជំងឺដ៏មានប្រសិទ្ធភាពបំផុត !*



ការបំបែកសត្វគឺជាវិធានការ
ការពារដ៏ល្អ ហើយត្រូវធ្វើយ៉ាងណា
កុំឱ្យសត្វផ្សេងទៀតមកប៉ះពាល់
ជាមួយ



ការដាក់សត្វថ្មីនៅទ្រុងស្អាតតែឯង
គឺជាវិធានការបំបែកដ៏ល្អ



គេមានការលំបាកក្នុងការបំបែក
គោទិញថ្មីឱ្យនៅដាច់ពីគេណាស់
តែយកល្អ
គួរទម្លាក់បរាសិតឱ្យគោទិញថ្មី
នេះជាមុនសិនទើបប្រសើរ

## បង្កាត់សិប្បនិម្មិត

ការបង្កាត់តាមធម្មជាតិ មានគុណវិបត្តិជាច្រើន ជាពិសេសធ្វើឱ្យមានអត្រាចម្លងជំងឺក្នុងកម្រិតខ្ពស់ ព្រោះ:

- បាជ្រូកអាចបញ្ចេញមេរោគជាច្រើន ដូចជា ជំងឺផ្លូវដង្ហើម បញ្ជូនតាមតាមច្រមុះ បរាសិតចម្លងតាមស្បែក...
- បាជ្រូកអាចបញ្ជូនជំងឺតាមទឹកកាមដូចជាជំងឺប៉េស្តជ្រូក...។

**ដំណោះស្រាយដ៏ល្អ**គឺការបង្កាត់សិប្បនិម្មិត ព្រោះទឹកកាមរបស់បាត្រូវបានត្រួតពិនិត្យច្បាស់លាស់ ហើយលាយជាមួយអង់ទីប៊ីយ៉ូទិក ដែលជាបាតុធ្វើឱ្យគ្រោះថ្នាក់នៃការចម្លងជំងឺមានកម្រិតទាប ។



ការបង្កាត់សិប្បនិម្មិត កាត់បន្ថយគ្រោះថ្នាក់ការចម្លងជំងឺពីជ្រូកបា

## ៣.២. ឆ្លងតាមរយៈសាច់សត្វ

### ក- ការចម្លង

កសិករអាចនាំមេរោគចូលទៅក្នុងផ្ទះ ប្រសិនបើគេទិញសាច់ ឆ្អឹង និងពោះវៀនដែលមាន មេរោគ ដូចជា ៖

- កាកសំណល់សាច់ជ្រូកអាចមាន វីរុស ប៉េស្តជ្រូក...
- សាច់មាន់អាចមានវីរុសដង្កោ និង ផ្តាសាយបក្សី...
- សាច់គោអាចមានមេរោគ ឈាមខ្មៅ... ។



ជ្រូកឈឺជំងឺប៉េស្តសាច់របស់វា អាចចម្លងជំងឺទៅជ្រូកផ្សេងទៀតបាន

### ខ- វិធានការអនាម័យ និងការការពារ



ដើម្បីការពារកុំឱ្យមេរោគឆ្លងមកយើង ចាំបាច់ត្រូវធ្វើការលាងសម្អាតដៃជាប្រចាំ

- កុំបរិភោគសាច់សត្វដែលឈឺ ឬងាប់ដោយជំងឺ
- ដុតសាច់សត្វដែលសង្ស័យថាឈឺចោល
- ធ្វើការចំអិនឱ្យបានឆ្អិនល្អ ព្រោះកម្តៅអាចសម្លាប់វីរុស និងបាក់តេរី (សីតុណ្ហភាព ៧០ អង្សាសេ សម្លាប់វីរុស ផ្តាសាយបក្សី)
- បន្ទាប់ពីប៉ះពាល់ជាមួយសាច់រួច ត្រូវលាងដៃជាមួយសាប៊ូ ។

## ៣~៣~ ឆ្លងតាមមធ្យោបាយដឹកជញ្ជូន

### ក- ការចម្លង

មេរោគអាចរស់នៅបានយូរនៅក្នុងដីលាមក... ហើយអាចធ្វើការចម្លងតាមរយៈមធ្យោបាយដឹកជញ្ជូន ដូចជារថយន្ត ម៉ូតូ... ដែលចេញចូលកសិដ្ឋានច្រើនកន្លែងរបស់ :

- ឈ្មួញកណ្ដាល
- ពេទ្យសត្វ
- អ្នកដឹកជ្រូកបា ។



មេរោគអាចតោងភាប់នៅលើកង់យានជំនិះ

### ខ- ការការពារ

ក្នុងការការពារការចម្លងមេរោគ ត្រូវឱ្យរថយន្ត ម៉ូតូ... របស់ឈ្មួញ ឈប់នៅក្រៅរបងកសិដ្ឋាន ឬផ្ទះ។ តែវិធានការនេះមិនប្រាកដថាល្អនោះទេ។ ក្នុងករណីមានជំងឺផ្ទុះនៅភូមិជិតខាង ឬនៅក្នុងស្រុក សំខាន់ត្រូវ :



កង់ម៉ូតូអាចធ្វើការចម្លងមេរោគបានឆ្ងាយ

- គ្រប់គ្រងលើរថយន្តចេញចូល ជាពិសេសពេលផ្ទុះជំងឺអុតក្ដាម
- រៀបចំកន្លែងសម្លាប់មេរោគនៅមុខច្រកចូលសំខាន់ៗ
- បាញ់ថ្នាំសម្លាប់មេរោគលើមធ្យោបាយដឹកជញ្ជូន ដែលចូលទៅក្នុងភូមិ ( កង់ រទេះ... ) ។

## ៣.៤. ឆ្លងតាមមនុស្ស

### ក- ការចម្លង

- មនុស្សជាអ្នកនាំ  និងធ្វើការចម្លងមេរោគតាមរយៈសំភារៈមួយចំនួនដែលជាប់មេរោគក្រោយពីចូលកន្លែងចិញ្ចឹមសត្វរួច ដូចជា ស្បែកជើង ខោ អាវ.........
- មនុស្សក៏អាចចម្លងមេរោគតាមដៃ ឬ សួត ( អុតក្តាម)



មនុស្សយើងគឺជាភ្នាក់ងារចម្លងជំងឺដ៏សំខាន់ ដូចជាជំងឺញ៉ូវកាស និងអុតក្តាម តាមរយៈសកម្មភាពព្យាបាលសល់ភ្នាក់ងារសុខភាពសត្វភូមិ ហើយមេរោគតោងជាប់ស្បែកជើង ដៃ សំលៀកបំពាក់ និង ធ្វើការចម្លងទៅកន្លែងផ្សេងទៀត

## ខ- ការការពារ

- មិនត្រូវអនុញ្ញាតឱ្យអ្នកផ្សេងចូលទៅក្នុងទ្រុងសត្វ ឬ កន្លែងចិញ្ចឹមសត្វ
- ស្នើរភ្នាក់ងារសុខភាពសត្វភូមិ ឈ្មួញ ឱ្យធ្វើការលាងសម្អាតដៃ ផ្លាស់ប្តូរស្បែកជើង សំលៀងបំពាក់....



ឱ្យស្បែកជើងក្នុងគ្រួសារដល់ភ្នាក់ងារសុខភាពសត្វភូមិ មុនអនុញ្ញាតឱ្យចូលទ្រុងសត្វ

## ៣-៥- ឆ្លងតាមរយៈសំរាម

## ក- ការចម្លង

- មេរោគជាច្រើននឹងងាប់នៅពេលត្រូវកម្តៅ និងពន្លឺ ហើយមេរោគខ្លះទៀតអាចរស់នៅបានយូរនៅទីកន្លែងដែលសើម ងងឹត...
- កន្លែងកខ្វក់ដូចជាមានសំរាម គ្រលុក គឺជាមជ្ឈដ្ឋានអំណោយផលសមស្របសម្រាប់មេរោគរស់នៅ
- កន្លែងកខ្វក់ និងដីសើម ធ្វើឱ្យបាក់តេរីប៉ាស្ទឺរេឡា (អាសន្នរោគបក្សី) វីរុសប៉េស្តទា... លូតលាស់លឿន ។

សំរាមគឺជាមជ្ឈដ្ឋានអំណោយផល ល្អសម្រាប់មេរោគលូតលាស់



## ខ- ការការពារ

- បោសសម្អាត និងប្រមូលសំរាមយកទៅចោល ៖ សំរាមមានមេរោគច្រើន ដូចនេះ ត្រូវប្រមូល និង ដុតសំរាមចោល
- លុបគ្រលុកចោល ៖ ភក់ ឬ ទឹកកខ្វក់ ជាកន្លែងដែលមេរោគ និងមូសលូតលាស់លឿន ដូចនេះត្រូវលុបគ្រលុកចោល
- ដុតកំទេចសាកសពសត្វ ៖ ព្រោះមេរោគនឹងលូតលាស់នៅក្នុងសាច់ ហើយដង្កូវវិវត្តទៅជារុយ ដែលអាចធ្វើឱ្យមេរោគកាន់តែរីករាលដាលខ្លាំង ។



ភូមិស្អាតមេរោគមានតិចតួច

សំរាមគឺជាមជ្ឈដ្ឋានអំណោយផល
ល្អសម្រាប់មេរោគលូតលាស់



## ខ- ការការពារ

- បោសសម្អាត និងប្រមូលសំរាមយកទៅចោល : សំរាមមានមេរោគច្រើន ដូចនេះ ត្រូវប្រមូល និង ដុតសំរាមចោល
- លុបគ្រលុកចោល : ភក់ ឬ ទឹកកខ្វក់ ជាកន្លែងដែលមេរោគ និងមូសលូតលាស់លឿន ដូចនេះត្រូវលុបគ្រលុកចោល
- ដុតកំទេចសាកសពសត្វ : ព្រោះមេរោគនឹងលូតលាស់នៅក្នុងសាច់ ហើយដង្កូវវិវត្តទៅជារុយ ដែលអាចធ្វើឱ្យមេរោគកាន់តែរីករាលដាលខ្លាំង ។



ភូមិស្អាតមេរោគមានតិចតួច

## ៤. ការសម្លាប់មេរោគ

### ៤.១. និយមន័យ

ការសម្លាប់មេរោគគឺជាការប្រើប្រាស់នូវសារធាតុគីមីដែលអាចសម្លាប់មេរោគផ្សេងៗ។ តែសារធាតុសម្លាប់មេរោគអាចមានគ្រោះថ្នាក់ ដូចនេះត្រូវប្រើដោយប្រុងប្រយ័ត្ន។

សារធាតុសម្លាប់មេរោគ អាចសម្លាប់បានដូចជា:

- បាក់តេរី
- វីរុស
- ផ្សិត

*បច្ចុប្បន្ននេះមានសារធាតុតិចតួចដែលអាចសម្លាប់បានទាំងបាក់តេរី និង វីរុស!*




សារធាតុសម្លាប់មេរោគចេញថ្មី ដែលមានសកម្មភាពខ្លាំង
ហើយមានសុវត្ថិភាពសម្រាប់មនុស្ស

## ៤.២. ការប្រើប្រាស់ត្រឹមត្រូវ

### ៤.២.១. គោលការណ៍ប្រើប្រាស់

- សារធាតុសម្លាប់មេរោគមិនមានប្រសិទ្ធភាពទេ ប្រសិនបើទីកន្លែងដែលបាញ់ថ្នាំនោះមិនត្រូវបានគេសម្អាតជាមុន
- ដូចនេះមុននឹងប្រើថ្នាំបាញ់សម្លាប់មេរោគ គេត្រូវធ្វើការលាងសម្អាតទីកន្លែងនោះជាមុនសិន
- គេមិនអាចធ្វើការបាញ់សម្លាប់មេរោគនៅដី ភក់បានទេ ព្រោះសារធាតុសរីរាង្គតែងតែបង្អាក់សកម្មភាពរបស់ថ្នាំ
- ត្រូវប្រើប្រាស់ថ្នាំទៅតាមការណែនាំរបស់រោងចក្រ
- យើងអាចធ្វើការបាញ់សម្លាប់មេរោគលើសំភារៈ ដូចជា ស្នូកទឹក ស្នូកចំណី...។

អ្នកនឹងចំណាយលុយឥតប្រយោជន៍ ប្រសិនបើអ្នកធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅលើដី



## ៤.២.២. ការសម្អាត

***ការសម្អាតមាន ២ ដំណាក់កាល***

### ក- បោសសម្អាត (សម្អាតមិនប្រើទឹក) :

- បោសប្រមូលយកកាកសំណល់ (ជាសារធាតុ សរីរាង្គ) ចេញ ដូចជា ដី លាមក ចំបើង ចំណីសល់...

### ខ- សម្អាតដោយប្រើទឹក :

- ត្រាំ
- ដុសលាង
- លាងសម្អាតជាមួយសាប៊ូ
- រួចសម្ងួត ឬទុកឱ្យស្ងួត



ប្រមូលយកសារធាតុសរីរាង្គសំខាន់ៗចេញ



បាញ់ទឹកលាងសម្អាត



ហើយធ្វើការលាងសម្អាតទ្រុងជាមួយនឹងសាប៊ូ មុននឹងធ្វើការបាញ់ថ្នាំសម្លាប់មេរោគ

## ៤.២.៣. ការបាញ់ថ្នាំសម្លាប់មេរោគ

- សារធាតុសម្លាប់មេរោគត្រូវបានគេប្រើនៅពេលទ្រុងទំនេរ ឬមិនមានសត្វ
- កំហាប់ថ្នាំសម្លាប់មេរោគ ត្រូវលាយទៅតាមការណែនាំរបស់ផលិតផលនីមួយៗ
- ការសម្លាប់មេរោគដ៏ល្អ គឺក្រោយពីបាញ់ថ្នាំរួចត្រូវទុកចោល ២០ នាទី មុនធ្វើការលាងសម្អាតថ្នាំចោល
- មិនត្រូវធ្វើការបាញ់ថ្នាំសម្លាប់មេរោគទៅលើសត្វឡើយ ។

មុននឹងលាយជាមួយទឹក ត្រូវគិតគូរកម្រិតប្រើប្រាស់ឱ្យត្រឹមត្រូវ!





ហើយធ្វើការលាងសម្អាតទ្រុងជាមួយ នឹងសាប៊ូ មុននឹងធ្វើការបាញ់ថ្នាំសម្លាប់មេរោគ

## ៤.២.៣. ការបាញ់ថ្នាំសម្លាប់មេរោគ

- សារធាតុសម្លាប់មេរោគត្រូវបានគេប្រើនៅពេលទ្រុងទំនេរ ឬមិនមានសត្វ
- កំហាប់ថ្នាំសម្លាប់មេរោគ ត្រូវលាយទៅតាមការណែនាំរបស់ផលិតផលនីមួយៗ
- ការសម្លាប់មេរោគដ៏ល្អ គឺក្រោយពីបាញ់ថ្នាំរួចត្រូវទុកចោល ២០ នាទី មុនធ្វើការលាងសម្អាតថ្នាំចោល
- មិនត្រូវធ្វើការបាញ់ថ្នាំសម្លាប់មេរោគទៅលើសត្វឡើយ ។

មុននឹងលាយជាមួយទឹក ត្រូវគិតគូរកម្រិតប្រើប្រាស់ឱ្យត្រឹមត្រូវ!



## ៤.៣. ប្រភេទថ្នាំសម្លាប់មេរោគ

### ៤.៣.១. គ្រេស៊ីល (Cresyl)




- មានសកម្មភាពប្រឆាំងបានទាំងបាក់តេរី និងវីរុស
- វាមានប្រសិទ្ធភាពបានយូរថ្ងៃ
- តែក្លិនឆួលខ្លាំង

### ៤.៣.២. អ៊ីយ៉ូឌីន (Iodine)

- ជាថ្នាំសម្លាប់មេរោគដ៏ល្អ ហើយមិនមានគ្រោះថ្នាក់
- វាមិនមានប្រសិទ្ធភាពទេ ប្រសិនបើទីកន្លែងដែលត្រូវបាញ់ថ្នាំនោះមិនត្រូវបានគេសម្អាតនោះ
- ពន្លឺព្រះអាទិត្យបង្អាក់សកម្មភាពរបស់ថ្នាំ

### ៤.៣.៣. លី (Lye)

- មានសកម្មភាពខ្លាំងប្រឆាំងនឹងវីរុស (អុតក្តាម)
- មានសភាពកាត់ខ្លាំង ដូចនេះត្រូវកាន់ដោយប្រុងប្រយ័ត្ន
- មានប្រសិទ្ធភាពរយៈពេលខ្លី

### ៤.៣.៤. កំបោរ (Lime)

- មានសភាពកាត់សារធាតុសរីរាង្គ ហើយអាចបំផ្លាញកាកសំណល់ និងមេរោគ
- អាចប្រើលើសាកសពសត្វ (ក្នុងស្ថានភាពសើម)
- មានគ្រោះថ្នាក់ខ្លាំងសម្រាប់អ្នកប្រើ

## ៥. ការចាត់វិធានការនៅពេលមានផ្ទុះជំងឺនៅភូមិជិតខាង (រៀបចំផែនការភូមិទុកជាមុន)

### ៥.១. សេចក្តីផ្តើម

ការអនុវត្តន៍ជីវសុវត្ថិភាពនៅតាមភូមិគឺជា**ការងារដែលធ្វើរាល់ថ្ងៃ** និង សាមញ្ញ ប៉ុន្តែនៅពេលមាន**ផ្ទុះជំងឺ**ឆ្លងរាតត្បាតនៅក្នុងស្រុក ឬភូមិជិតខាង នោះការអនុវត្តន៍វិធានការជីវសុវត្ថិភាពត្រូវតែពង្រឹងឱ្យបានខ្លាំង។ កិច្ចការសំខាន់គឺត្រូវ**រៀបចំផែនការ**ភូមិមុនពេលជំងឺមកដល់ដោយធ្វើការប្រកាស និង បែងចែកការទទួលខុសត្រូវដល់អ្នកភូមិ។

### ៥.២. ភ្នាក់ងារចម្លងមេរោគ

ភ្នាក់ងារចម្លងមេរោគសំខាន់ៗរួមមាន :

- **សត្វរស់ :** ជំងឺអុតក្តាម ជំងឺប៉េស្តជ្រូក ជំងឺដង្កៅ ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ...
- **សាកសពសត្វ ( ផ្ទាំងសាច់) :** ជំងឺដង្កៅ ជំងឺផ្តាសាយបក្សី...
- **មធ្យោបាយដឹកជញ្ជូន :** ជំងឺអុតក្តាម ជំងឺដង្កៅ...
- **ស្បែកជើង និងសំលៀកបំពាក់ :** អុតក្តាម ដង្កៅ ផ្តាសាយបក្សី ប៉េស្ត...



វីរុសធ្វើការរាតត្បាតតាមខ្យល់ (អុតក្តាម)

## ៥.៣. ការប្រកាសប្រាប់ព័ត៌មាន

- ភូមិរបស់អ្នកគឺជាកសិដ្ឋានមួយ ដូចនេះអ្នកត្រូវ**ការពារ**ភូមិរបស់អ្នកកុំឱ្យមានជំងឺចូល
- ប្រកាសប្រាប់ដល់អ្នកភូមិ**ទាំងអស់**ពីគ្រោះថ្នាក់ និង វិធានការការពារផងដែរ
- ប្រធានភូមិ និង ភ្នាក់ងារសុខភាពសត្វភូមិគឺជាអ្នកទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មានដល់អ្នកភូមិ។



រៀបចំការប្រជុំភូមិដើម្បីប្រកាសព័ត៌មាន

## ៥.៤. ធ្វើការហាមឃាត់

- ក្នុងកំឡុងពេល និង ក្រោយពេលផ្ទុះជំងឺ ២ សប្តាហ៍ ត្រូវហាមឃាត់មិនឱ្យយកសត្វរស់ចូលក្នុងភូមិ

- សំខាន់ត្រូវធ្វើការហាមឃាត់:

  - ការទិញដូរសត្វរស់ : មាន់ (ពេលផ្ទុះជំងឺដង្កោ ឬផ្តាសាយបក្សី) គោ និងជ្រូក (ពេលមានផ្ទុះជំងឺអុតក្តាម)...

  - ការដឹកបាជ្រូកមកពីភូមិផ្សេងៗសម្រាប់ការបង្កាត់ពូជ (ពេលមានផ្ទុះជំងឺអុតក្តាម ឬ ប៉េស្តជ្រូក)

  - ការដឹកសត្វឆ្លងកាត់ភូមិ ជាពិសេសឈ្មួញ ។



ហាមឃាត់ការទិញ ឬដឹកជញ្ជូនជ្រូក នៅពេលមានផ្ទុះជំងឺអុតក្តាម ឬ ប៉េស្តជ្រូក

## ៥.៥. ប្រុងប្រយ័ត្នខ្ពស់ក្នុងការរៀបចំសាច់

- ពេលយកសាច់ពីផ្សារត្រូវដាក់នៅក្នុងថង់ផ្លាស្ទិច
- ក្រោយពីរៀបចំសាច់រួច ត្រូវលាងសម្អាតដៃ និងសំភារៈផ្សេងៗ
- ដុត ឬកប់កាកសំណល់ឱ្យបានល្អ
- ចំអិនសាច់ឱ្យបានឆ្អិនល្អ។



## ៥.៦. ចិញ្ចឹមសត្វនៅកន្លែងមួយច្បាស់លាស់

- ត្រូវដាក់ចំណីឱ្យមាន់ និងជ្រូក ដើម្បីជៀសវាងកុំឱ្យពួកវាដើរសេរី
- គួរធ្វើរបងការពារមាន់កុំឱ្យវាដើរមកក្បែរផ្ទះ
- សម្រាប់ជ្រូកប្រសិនបើគ្មានទ្រុង គេត្រូវចងវា
- នៅពេលមានផ្ទុះជំងឺមិនត្រូវយកគោទៅវាលឡើយ ព្រោះដើម្បីជៀសវាងកុំឱ្យប៉ះពាល់ជាមួយសត្វផ្សេង ឬ កុំឱ្យវាប្រឡាក់ប្រឡូកនៅវាលស្មៅ (វីរុសអុតក្តាម អាចរស់នៅក្នុងដីបាន ២ ថ្ងៃ)។



ជ្រូកដែលចិញ្ចឹមគ្មានទ្រុង ត្រូវចងវាដើម្បីកុំឱ្យដើរពាសវាលពាសកាល



ត្រូវចិញ្ចឹមមាន់នៅកន្លែងមានសុវត្ថិភាពមួយ



ត្រូវចងគោនៅក្រោមផ្ទះ និងផ្តល់ចំណីឱ្យវា

របងការពារកុំឱ្យសត្វ ឬមនុស្ស
ចេញ-ចូល សេរី





របងសាមញ្ញធ្វើពីឬស្សី
តែអាចការពារកុំឱ្យជ្រូកដើរសេរី

## ៥.៧. ការពារនៅច្រកចូល

- បាញ់ថ្នាំសម្លាប់មេរោគនៅលើ កង់ កង់ម៉ូតូ កង់រថយន្ត កង់រទេះ...
- រៀបចំអាងជ្រលក់ជើងនៅពីមុខច្រកចូលភូមិសំខាន់ៗ។ មុនចូលទៅក្នុងភូមិត្រូវជ្រលក់ស្បែកជើងឱ្យជ្រៅទៅក្នុងថ្នាំសម្លាប់មេរោគ។



អាងសម្លាប់មេរោគសាមញ្ញ ដែលមាន
នៅច្រកចូលសំខាន់ៗទៅក្នុងភូមិ

## ៥.៨. ការពារកុំឱ្យមានការប៉ះពាល់ជាមួយសត្វ

មនុស្ស ជាពិសេសអ្នកចិញ្ចឹមសត្វ ពេទ្យសត្វ (ដែលតែងតែព្យាបាលសត្វឈឺ) និង ឈ្មួញទិញសត្វ (ដែលភាគច្រើនទិញសត្វឈឺមានតម្លៃថោក ជាពិសេសនៅពេលផ្ទុះជំងឺ) គឺជាភ្នាក់ងារចម្លងជំងឺដ៏សំខាន់មួយ ព្រោះ :

- ពួកគេពាំនាំមេរោគនៅលើស្បែកជើង សំលៀកបំពាក់...
- បន្ទាប់មកធ្វើការចម្លងមកសត្វរបស់អ្នក

ក្នុងកំឡុងពេលផ្ទុះជំងឺ មិនត្រូវអនុញ្ញាតឱ្យអ្នកផ្សេងចូលទៅក្នុងកសិដ្ឋានរបស់អ្នកឡើយ ហើយបើក្នុងករណីចាំបាច់ត្រូវឱ្យពួកគេផ្លាស់ប្តូរស្បែកជើង និងសំលៀកបំពាក់។



តើអ្នកប្រាកដថាអ្នកទាំងនេះ មិនបាននាំមេរោគទៅឱ្យសត្វរបស់អ្នកឬ ?

## ៥.៩. ភារៈកិច្ចរបស់ភ្នាក់ងារសុខភាពសត្វភូមិ

ក្នុងករណីមានផ្ទុះជំងឺ ភ្នាក់ងារសុខភាពសត្វភូមិមានការទទួលខុសត្រូវខ្ពស់លើ :

- ការកំណត់បញ្ជាក់រោគសញ្ញាជំងឺដែលកើតមាននៅក្នុងភូមិ
- ប្រកាសប្រាប់ដល់អ្នកភូមិពីការផ្ទុះជំងឺ និង វិធានការជីវសុវត្ថិភាព
- ជូនដំណឹងដល់ពេទ្យសត្វស្រុក
- ព្យាបាលតែសត្វក្នុងភូមិរបស់ខ្លួន ហើយមិនត្រូវទៅមើលកន្លែងចិញ្ចឹមសត្វនៅភូមិជិតខាងឡើយ ។




ភ្នាក់ងារសុខភាពសត្វភូមិ គឺជាមនុស្សសំខាន់ សម្រាប់ការពារកុំឱ្យមានផ្ទុះជំងឺនៅក្នុងភូមិ

## ៦. បទពិសោធន៍របស់អង្គការ AVSF

### ៦.១. ការរៀបចំគម្រោង

អង្គការ AVSF ចុះហត្ថលេខាលើកិច្ចសន្យាជាមួយអង្គការ FAO ដើម្បីរៀបចំការធ្វើបង្ហាញមួយហៅថា "ការធ្វើអនាម័យនៅតាមភូមិ" ហើយបានធ្វើការវិភាគពីឥទ្ធិពលរបស់វាទៅលើសុខភាពសត្វ។ អង្គការ AVSF បានរៀបចំសកម្មភាពធ្វើការបង្ហាញក្នុងរយៈពេល ៦ខែ នៅភូមិ ចំនួន ៣ ក្នុង ខេត្តតាកែវ។

### ៦.២. សកម្មភាពរបស់អង្គការ

#### ៦.២.១. បណ្តុះបណ្តាលអ្នកភូមិ

- បង្ហាញពីគោលបំណងរបស់គម្រោង
- បង្ហាញពីតួនាទីរបស់ជីវសុវត្ថិភាពក្នុងការការពារភូមិ
- បង្ហាញពីគោលការណ៍គ្រឹះនៃការធ្វើអនាម័យ
- ក្នុងនោះមានអ្នកភូមិចូលរួមទទួលការបណ្តុះបណ្តាលចំនួន ១៨១ នាក់។



ការបណ្តុះបណ្តាលដល់អ្នកភូមិស្តីពីជីវសុវត្ថិភាពរបស់អង្គការ VSF





ការរៀបចំជីវសុត្ថិភាព ទាមទារចាំបាច់ឱ្យមានការចូលរួមពីអ្នកភូមិទាំងអស់



ប្រសិនបើមានពេលទំនេរកូនក្មេង
គួរតែចូលរួមក្នុងការបណ្តុះ
បណ្តាលនេះដែរ ព្រោះពួកគេគឺ
ជាអ្នកបន្តវេននៅក្នុងភូមិ



## ៦.២.២. ការបង្ហាញវិធីសត្វ

- អង្គការបានចែកអង្រុតសម្រាប់ក្រុងមាន់ដល់អ្នកចូលរួមទាំងអស់ (មុនធ្វើការបង្ហាញ មានគ្រួសារតែ ៣,៨ % ប៉ុណ្ណោះដែលមានអង្រុត)
- មានគ្រួសារចំនួន ៧៩,៧៥ % បានអនុវត្តការក្រុងមាន់ថ្មី ២ សប្តាហ៍មុនដាក់បញ្ចូលក្នុងហ្វូង
- តម្លៃអង្រុតមួយគឺ ៨000 រៀល ។



ការចែកអង្រុតសម្រាប់ក្រុងមាន់ដល់អ្នកភូមិ





ផ្ទះមួយទទួលអង្រុតមួយសម្រាប់អនុវត្តការក្រុងមាន់

## ៦.២.៣. ការបំបែកសត្វទៅតាមប្រភេទ

- មុនធ្វើការបង្ហាញមានកសិករចំនួន ៩១,២ % បានចិញ្ចឹមមាន់ និងទាលាយជាមួយគ្នា
- ក្រោយពីធ្វើការបង្ហាញមាននៅសល់កសិករ តែ ៤៥,៥% ប៉ុណ្ណោះ ដែលនៅបន្តសកម្មភាពចិញ្ចឹមមាន់លាយជាមួយទាដដែល ។



ទាអាចជាអ្នកផ្ទុកជំងឺ ដែលអាចចម្លង និងធ្វើឱ្យមាន់ងាប់





ត្រពាំងស្អាត និងការបង្ខាំងដោយប្រើសំណាញ់ គឺជាការការពារកុំឱ្យមានការរាតត្បាតជំងឺរវាងមាន់ និងទា

## ៦.២.៤. សម្អាតភូមិ

ដើម្បីឱ្យភូមិស្អាតល្អគេត្រូវ ៖

- បោសសម្អាត និងដុតសំរាមចោល
- លុបគ្រលុកចោល
- សម្អាតត្រពាំង។



លំនៅដ្ឋានកខ្វក់ ជាប្រភពមេរោគ

## ៦.៣. ស្ថានភាពភូមិមុនអនុវត្តសកម្មភាព







ស្ថានភាពភូមិមុនធ្វើការបង្ហាញ




ស្ថានភាពភូមិក្រោយពេលអ្នកភូមិរួមគ្នាធ្វើការសម្អាត !

## ៦.៥. លទ្ធផលទទួលបាន

| មុនពេលធ្វើបង្ហាញ | ក្រោយពេលធ្វើបង្ហាញ |
|---|---|
| អត្រាសត្វឈឺ | |
| មាន់ ៦៥,៧% | មាន់ ១៩,៧% |
| ទា ២៩,៧ % | ទា ៤,៨ % |
| អត្រាសត្វងាប់ | |
| មាន់ ២៩,៧ % | មាន់ ៣ % |
| ទា ២៩,៧ % | ទា 0,១៥ % |

## ៧. សន្និដ្ឋាន

- ជីវសុវត្ថិភាពគឺជាកិច្ចការងាយស្រួលអនុវត្ត
- ចំណាយលុយតិច ដូចជាអង្រុត និងពេលសម្អាត
- សកម្មភាពធ្វើឡើងនៅកម្រិតមូលដ្ឋាន (ភូមិ) ដោយមានការចូលរួមពីអ្នកភូមិទាំងអស់គ្នា
- កាត់បន្ថយអត្រាឈឺ និងស្លាប់របស់សត្វ :
  - ចំនួនសត្វមុនពេលចាប់ផ្តើមធ្វើបង្ហាញមាន **២៨០២ ក្បាល**
  - ចំនួនសត្វក្រោយពេលធ្វើបង្ហាញកើនដល់ **៤៤៨៣ ក្បាល**។